# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដី នៅក្នុងឃុំ ទ្រា
# ស្រុកស្ទោង ខេត្តកំពង់ធំ
# ឆ្នាំ២០១៧ ដល់ ២០៣២




រៀបចំដោយ : ក្រុមហ៊ុនផ្តល់សេវាកម្មSBK R&D

សម្របសម្រួលដោយ : ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីស្រុកស្ទោង

គាំទ្របច្ចេកទេសដោយ : អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ(NIO-MLMUPC) និងថ្នាក់ខេត្ត(PIO)

ឧបត្ថម្ភថវិកាដោយ : រាជរដ្ឋាភិបាលកម្ពុជា (RGC) , ADB_Loan , GAFSP_Grant និងSCF_ADB

# មាតិកា


**អារម្ភកថា** ............ VIII

**សេចក្តីផ្តើម** ............ 1

**ជំពូក ១៖ ព័ត៌មានស្តីពីស្ថានភាពឃុំទ្រា** ............ 3

**១.១. ស្ថានភាពឃុំ** ............ 3

១.១.១.ទីតាំងរដ្ឋបាលឃុំ ............ 3

១.១.២.ប្រជាសាស្ត្រ ............ 6

ក. ចំនួនប្រជាជន ............ 6

ខ. អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន ............ 8

គ. ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់ ............ 8

ឃ. របររកទទួលទាន ............ 8

ង. ចំណូលស្រុក និងចំណាកស្រុក ............ 10

១.១.៣.ស្ថានភាពសេដ្ឋកិច្ច ............ 11

ក. ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ ............ 11

ខ. កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ ............ 12

គ. ស្ថានភាពបំណុល និងអាត្រាការប្រាក់ ............ 13

ឃ. ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ ............ 14

ង. ចំណូលពីប្រភពផ្សេងៗ ............ 14

១.១.៤.ស្ថានភាពអប់រំ និងសិក្សាធិការ ............ 14

ក. ស្ថានភាពអប់រំ ............ 14

ខ .ស្ថានភាពអក្ខរកម្ម ............ 15

គ. ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត ............ 16

១.១.៥.ស្ថានភាពសុខាភិបាល ............ 17

១.១.៦.ស្ថានភាពយេនឌ័រ ............ 20

**១.២. ស្ថានភាពភូមិសាស្ត្រ** ............ 22

១.២.១.ទីតាំងភូមិសាស្ត្រ ............ 22

១.២.២.អាកាសធាតុ (ពិពណ៌នាតាមរដូវកាល)....28
១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន....29
១.២.៤.បរិក្ខាសាធារណៈ....32
ក. ស្ថានភាពប្រើប្រាស់អគ្គិសនី....32
ខ. ប្រព័ន្ធទឹកស្អាត....32
**១.៣.ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន....33**
១.៣.១.ស្ថានភាពការកាន់កាប់ និងគ្រប់គ្រងដី....33
ក. ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ....36
ខ. ដីកសិកម្ម៖....38
ខ.១. ដីស្រែវស្សា....38
ខ.២. ដីចម្ការ....39
គ. ដីព្រៃ/តម្របព្រៃ៖....40
ឃ. ផ្ទៃទឹក និងខ្សែទឹក៖....42
១.៣.២.ផលិតកម្មកសិកម្ម....43
ក. ផលិតកម្មដំណាំស្បៀង....43
ខ. ផលិតកម្មដំណាំរួមផ្សំ....44
គ. ផលិតកម្មខ្វស្សាហកម្ម....45
១.៣.៣.ធនធានធម្មជាតិ....45
ក. ធនធានព្រៃឈើ....45
ខ. ធនធានជលផល....46
**១.៤. ទីផ្សារ និងខ្សែសង្វាក់ផលិតផល....47**
១.៤.១.ទីផ្សារ និងតម្លៃកសិផល ផល-អនុផលព្រៃឈើ និងផលនេសាទ....47
១.៤.២.ខ្សែសង្វាក់ និងចរាចរផលិតផល....48
១.៤.៣.ឧបសគ្គ និងឱកាស....50

**ជំពូក ២៖ ការវិភាគ តម្រូវការ សក្ដានុពល និងឧបសគ្គសម្រាប់អនាគត**........51
**២.១. តម្រូវការសម្រាប់អនាគត**........51
២.១.១.ផែនការអភិវឌ្ឍន៍ឃុំ........51
ក. ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ (២០១៧-២០២២)........51
ខ. គម្រោងអភិវឌ្ឍន៍ផ្សេងៗទៀតដែលបានអនុម័តរួច........54
២.១.២.ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២........56
២.១.៣.តម្រូវការដីធ្លីជាមូលដ្ឋាន........57
ក. ដីលំនៅឋាន........57
ខ. ដីកសិកម្ម........58
គ. ដីព្រៃឈើ........59
ឃ. ធនធានទឹក........59
ង. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត........60
ង.១. វិស័យអប់រំ........60
ង.២. វិស័យសុខាភិបាល........62
ង.៣. អគ្គិសនី........62
ង.៤. ទីលានចាក់សំរាម........62
ង.៥. ដីកប់ខ្មោច........63
ង.៦. ស្រះ និងអណ្ដូងទឹក........63
**២.២.តំបន់សេរីប**........63
**២.៣. ការប្រឈម**........65
២.៣.១.ការប្រឈមដោយធម្មជាតិ........65
ក. កំណើនប្រជាជន........65
ខ. គ្រោះធម្មជាតិ ការប្រែប្រួលនៃធម្មជាតិ........65
២.៣.២.ការប្រឈមដោយ ការអភិវឌ្ឍន៍ដែលពុំមាននិរន្តរភាព........65
**២.៤. ឱកាស**........66

២.៤.១.ដោយអំណោយផលពីធម្មជាតិ ..... 66

២.៤.២.ដោយបច្ចេកវិទ្យាថ្មីៗ ..... 66

២.៤.៣.ដោយគម្រោងវិនិយោគ ..... 67

**២.៥. បញ្ហា មូលហេតុ និងដំណោះស្រាយ** ..... 67

**ជំពូក ៣៖ ផែនការប្រើប្រាស់ដីអនាគតឆ្នាំ២០១៧-២០៣២** ..... 71

**៣.១. តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង** ..... 71

៣.១.១.តម្រូវការដីទៅតាមប្រភេទ ..... 71

៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល ..... 71

**៣.២. ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់** ..... 72

៣.២.១.ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ ..... 72

៣.២.២.ផែនទីប្រើប្រាស់ដីអនាគត ..... 74

៣.២.៣.សេចក្តីអត្ថាធិប្បាយ ..... 76

ក. ដីលំដីលំនៅឋាន ភូមិ ..... 76

ខ. កន្លែងកប់ខ្មោច ..... 77

គ. ទីលានចាក់សំរាម ..... 77

ឃ. ដីស្រែវស្សា ..... 77

ង. ដីចម្ការ ..... 78

ច. ព្រៃជាមួយចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២ ..... 79

ឆ. ព្រៃជាមួយដីស្រែ ..... 79

ជ. ព្រៃជាមួយដីស្រែក្នុងតំបន់ការពារសត្វខ្សឹបត្រួតគ្នាគម្របព្រៃឈើឆ្នាំ២០០២ ..... 79

ឈ. ព្រៃល្បោះ ..... 80

ញ. ព្រៃតាមដងស្ទឹង ..... 80

ដ. ស្ទឹងមានទឹកតាមរដូវ ..... 80

ឋ. ស្រះទឹក ..... 81

**៣.៣. ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី** ..... 81

**៣.៤. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព** ........ 81
៣.៤.១.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព........ 81
ក. ការគ្រប់គ្រងប្រព័ន្ធកសិកម្ម ........ 82
ខ. ការគ្រប់គ្រងព្រៃឈើ ផលផល និង ធនធានសំខាន់ៗផ្សេងៗទៀត ........ 83
៣.៤.២.គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព........ 84
**៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត** (**២០១៧ ដល់ ២០៣២**) ........ 85

## បញ្ជីតារាង

តារាង 1៖ ស្ថានភាពទូទៅនៃឃុំ........ 3
តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ ........ 6
តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ........ 7
តារាង 4៖ ស្ថិតិប្រជាជនតាមបណ្តាឆ្នាំ  និងការគណនាអត្រាកំណើនមធ្យម ........ 8
តារាង 5៖ តារាងមុខរបរ........ 9
តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ ........ 10
តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧ ........ 11
តារាង 8៖ ស្ថិតិប្រជាជនចំណាកស្រុក........ 11
តារាង 9៖ តារាងកម្រិតជីវភាពរបស់ប្រជាជន ........ 12
តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧ ........ 15
តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ ........ 16
តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត ........ 17
តារាង 13៖ សុខភាពមាតានិងទារក........ 18
តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព ........ 19
តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ ឃុំទ្រា........ 20
តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹង ឃុំទ្រា ស្រុកស្ទោង........ 25
តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ ........ 27
តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ ........ 29
តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន ........ 30
តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី........ 32
តារាង 21៖ ស្ថិតិប្រភពទឹកប្រើប្រាស់........ 32
តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្នឃុំទ្រា ........ 35
តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស........ 44
តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស........ 44
តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស........ 45

តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស....46
តារាង 27៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស....46
តារាង 28៖ ស្ថិតិផលិតផលស្រូវ និងតម្លៃ....48
តារាង 29៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស....50
តារាង 30៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងជម្រើសនៃការប្រើប្រាស់ដីធ្លីអនាគត....51
តារាង 31៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ)....56
តារាង 32៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ)....57
តារាង 33៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២....58
តារាង 34៖ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២....59
តារាង 35៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១៨ ដល់ ឆ្នាំ ២០៣២....61
តារាង 36៖ បញ្ហាប្រឈម និងសក្តានុពល(ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ)....67
តារាង 37៖ តារាងប្រើប្រាស់ដីនាពេលអនាគតឃុំទ្រា....73
តារាង 38៖ តារាងផែនការផ្អែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត....73
តារាង 39៖ តារាងផែនការផ្អែកសេវាកម្មនាពេលអនាគត....74

## បញ្ជីដ្យាក្រាម

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ ២០១៨....7
ដ្យាក្រាម 2៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព....19
ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ....29
ដ្យាក្រាម 4៖ គំនូសតាងនៃការលំហូរផលិតផលកសិកម្ម នៅក្នុងភូមិ និងការប្រើប្រាស់....49

## បញ្ជីផែនទី

ផែនទី 1៖ ផែនទីទីតាំងឃុំទ្រា ស្រុកស្ទោង....4
ផែនទី 2៖ ព្រំប្រទល់រដ្ឋបាលឃុំទ្រា....5
ផែនទី 3៖ ផែនទីសណ្ឋានដីឃុំទ្រា....23
ផែនទី 4៖ តំបន់ក្សេត្រ-បរិស្ថាន ឃុំទ្រា....24
ផែនទី 5៖ ផែនទីប្រព័ន្ធធារាសាស្ត្រនៅក្នុងឃុំទ្រា....28
ផែនទី 6៖ ផែនទីហេដ្ឋារចនាសម្ព័ន្ធនៅក្នុងឃុំទ្រា....31
ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញនៅក្នុងឃុំទ្រា....33
ផែនទី 8៖ ផែនទីប្រើប្រាស់ដីលម្អិតក្នុងនៅក្នុងឃុំទ្រា....34
ផែនទី 9៖ គម្រោងវិនិយោគជាអាទិភាព ឃុំទ្រា....55
ផែនទី 10៖ ផែនទីតំបន់រសើប ឃុំទ្រា....64
ផែនទី 11៖ បញ្ហា មូលហេតុ និងដំណោះស្រាយ....70
ផែនទី 12៖ ផែនទីប្រើប្រាស់ដីអនាគតឃុំទ្រា....75

## បញ្ជីរូបភាព


រូបភាព 1៖ សាលារៀន ....................................................................................................... 15
រូបភាព 2៖ មណ្ឌលសុខភាព ឃុំទ្រា ..................................................................................... 18
រូបភាព 3៖ ប្រឡាយទឹកនៅក្នុងឃុំទ្រា................................................................................... 27
រូបភាព 4៖ ប្រព័ន្ធគមនាគមន៍.............................................................................................. 30
រូបភាព 5៖ ដីលំនៅឋាន ភូមិ .............................................................................................. 37
រូបភាព 6៖ កន្លែងកប់ខ្មោចនៅក្នុងឃុំទ្រា .............................................................................. 37
រូបភាព 7៖ ដីស្រែវស្សានៅក្នុងឃុំទ្រា .................................................................................... 39
រូបភាព 8៖ ដីចម្ការនៅក្នុងឃុំទ្រា ....................................................................................... 40
រូបភាព 9៖ ព្រៃជាមួយដីចម្ការ និងស្រែ................................................................................. 41
រូបភាព 10៖ ព្រៃល្បោះ ...................................................................................................... 41
រូបភាព 11៖ ព្រៃតាមដងស្ទឹងនៅក្នុងឃុំទ្រា............................................................................ 42
រូបភាព 12៖ ស្ទឹងមានទឹកតាមរដូវនៅក្នុងឃុំទ្រា ..................................................................... 42
រូបភាព 13៖ ស្រះទឹក......................................................................................................... 43
រូបភាព 14៖ ផលនេសាទនៅក្នុងឃុំទ្រា ................................................................................. 47
រូបភាព 15៖ ផលិតផលកសិកម្ម.......................................................................................... 48

# អារម្ភកថា

ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ គឺ ជាឧបករណ៍មួយដ៏សំខាន់ក្នុងការជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ផ្ទាល់ ក៏ដូចជាដល់អ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងសមធម៌ ជាពិសេសការគ្រប់គ្រងនិងប្រើប្រាស់ដី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ ដូច្នេះក្រោយពេលមានផែនការប្រើប្រាស់ដីនេះអាជ្ញាធរគ្រប់ផ្នែកនៅថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរដែនដី នឹងមានមូលដ្ឋានកាន់តែគ្រប់ជ្រុងជ្រោយ ក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់នៅក្នុងឃុំ / សង្កាត់នេះទៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយធ្វើសមាហរណកម្មផែនការនៅថ្នាក់ស្រុក និងការអនុម័តនៅថ្នាក់រាជធានី ខេត្ត តាមនីតិវិធី ដូចដែលធ្លាប់អនុវត្តក្នុងការកសាង ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច កន្លងមក ដោយមានគ្រប់ភាគីពាក់ព័ន្ធចូលរួមធ្វើការសម្រេច ។ ក្នុងទឹកចិត្តសោមនស្សរីករាយជាអនេក ខ្ញុំមានកិត្តិយសសូមបង្ហាញនូវរបាយការណ៍បច្ចេកទេសស្តីពីផែនការប្រើប្រាស់ដីនៅក្នុងឃុំទ្រាមានចក្ខុវិស័យរហូតដល់ឆ្នាំ២០៣២ ដែលក្រុមការងារបានប្រឹងប្រែងសិក្សាស្រាវជ្រាវ និងរៀបចំឡើងអស់រយៈពេលជាងពីរឆ្នាំកន្លងមកនេះ ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)និងកម្មវិធីកសិកម្មនិងសន្តិសុខស្បៀងពិភពលោក (GAFSP) ដែលបានគាំទ្រឧបត្ថម្ភថវិកា ក្រុមហ៊ុនផ្តល់សេវាកម្មមកជួយសិក្សារៀបចំផែនការនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានទទួលគ្រប់គ្រងគម្រោងនិងគាំទ្របច្ចេកទេស រដ្ឋបាលខេត្តកំពង់ធំ និងរដ្ឋបាលស្រុកស្ទោង ដែលបានសម្របសម្រួលដល់កិច្ចដំណើរការរបស់គម្រោង និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនៅក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំទ្រានេះ ។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ផែនការប្រើប្រាស់ដីនៅក្នុងឃុំទ្រា នេះនឹងបានចូលរួមចំណែកដល់ការអភិវឌ្ឍន៍ឃុំទ្រាប្រកបដោយចីរភាព ថែមទាំងត្រូវបានប្រើប្រាស់ដោយមានការចូលរួម និងគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ។

ថ្ងៃ [illegible] ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ទ្រា ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០២០

ប្រធានក្រុមប្រឹក្សាឃុំ

មិន_ជាតិ

# សេចក្តីផ្តើម

ស្ថិតនៅក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាល ដែលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា ។ រាជរដ្ឋាភិបាលបានបន្តធ្វើការជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ នៅក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបទៅដោយគុណភាព ប្រសិទ្ធិភាព និងស័ក្តិសិទ្ធិភាព ។

ផ្អែកតាមយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជា នៅក្រោមការដឹកនាំប្រកបទៅដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនូវគោលនយោបាយជាតិ ស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជាសំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍ តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្រ្តរៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាន ឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្រ្តនីមួយៗ ។

ឃុំទ្រាជាឃុំមួយក្នុងចំណោមឃុំចំនួន១៣ ស្ថិតក្នុងស្រុកស្ទោង ខេត្តកំពង់ធំ ជាតំបន់ជនបទ មានផ្ទៃដីសរុបចំនួន ១២ ៣៥៥,៤៣ ហិកតា មានព្រំប្រទល់ខាងជើងជាប់នឹងឃុំពពក ស្រុកស្ទោង និងឃុំសាមគ្គីស្រុកប្រាសាទបល្ល័ង្គ ខាងត្បូងជាប់នឹងឃុំកំពង់ចិនត្បូង ឃុំសំព្រោជ ស្រុកស្ទោង ខេត្តកំពង់ធំ ខាងកើតជាប់នឹងឃុំបន្ទាយស្ទោង ស្រុកស្ទោង ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ និងខាងលិចជាប់នឹងឃុំកំពង់ចិនជើង ឃុំប្រឡាយ ស្រុកស្ទោង ដែលមានប្រជាជនសរុបចំនួន ១២ ៨៩៣នាក់ នៅក្នុងនោះស្រ្តី ៦ ៦១៩នាក់ ហើយមានប្រជាពលរដ្ឋ ៧៣,២ % ជាកសិករ ។ ឃុំទ្រាមានផ្ទៃដីស្រែសរុបទំហំ ៥ ០០០ ហិកតា គឺជាផ្ទៃដីដែលមានទំហំធំទូលាយមានវិសាលភាពស្រូបអស់ ៤០,៤៧ % នៃផ្ទៃដីសរុបរបស់ឃុំ ដែលជាបង្អែកដ៏មានសក្តានុពលតែមួយគត់សម្រាប់ការអភិវឌ្ឍន៍ឃុំទ្រាប្រកបដោយចីរភាព ។

ក្នុងគោលដៅធានាការគ្រប់គ្រង និងអភិវឌ្ឍន៍ឃុំទ្រាប្រកបដោយចីរភាពនេះ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ និងស្រុកស្ទោង ព្រមទាំងក្រុមប្រឹក្សាឃុំទ្រាក្រោមការទទួលសិទ្ធិផ្តល់សេវាកម្មរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំទ្រាដោយក្រុមហ៊ុន SBK Co.LTd និងមានការគ្រប់គ្រងគាំទ្របច្ចេកទេសដោយអង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត (PIO) និងអង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIO) នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងមានការគាំទ្រ និងឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍ន៍អាស៊ី បានរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំទ្រា ចក្ខុវិស័យឆ្នាំ ២០៣២ សម្រាប់តម្រង់ទិសដល់ការអភិវឌ្ឍន៍ឃុំពាក់ព័ន្ធការប្រើប្រាស់ដីនៅក្នុងឃុំទ្រា ឆ្លើយតបទៅនឹងកំណើនប្រជាសាស្រ្ត ដើម្បីជាមូលដ្ឋានជួយដល់ក្រុមប្រឹក្សាឃុំទ្រាផ្ទាល់ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងសមធម៌ ដែលក្នុងនោះមានការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍន៍ឃុំ ធ្វើឱ្យជីវភាពប្រជាពលរដ្ឋមានភាពប្រសើរឡើងរួចផុតពីភាពក្រីក្រ ជាពិសេសប្រើប្រាស់ដីកសិកម្មនៅក្នុងឃុំទ្រាឱ្យអស់សក្តានុពលដែលមាន ក្នុងការផលិតស្រូវ ដើម្បីបង្កើនការនាំចេញអង្ករឱ្យបានច្រើននៅពេលខាងមុខ ដើម្បីឆ្លើយតបបានទៅនឹងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្កររបស់រាជរដ្ឋាភិបាលនៅសល់ពីការហូបចុក តាមរយៈការប្រើប្រាស់ផែនការប្រើប្រាស់ដីនៅក្នុងឃុំទ្រានេះ ធ្វើជាមូលដ្ឋានបង្អែកសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ឃុំនៅតាមអណត្តិនីមួយៗរបស់ខ្លួន។ ផែនការប្រើប្រាស់ដីនៅក្នុងឃុំទ្រា ត្រូវបានរៀបចំឡើងដោយមានការសិក្សាស្រាវជ្រាវច្បាស់លាស់ លើកត្តាភូមិសាស្រ្ត សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ បរិស្ថាន ព្រមទាំងគោលនយោបាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

សំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ។ ចំពោះនីតិវិធីនៃការរៀបចំផែនការនេះវិញ ត្រូវបានរៀបចំឡើងដោយផ្អែកលើអនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ ព្រមទាំងប្រកាសរួមស្តីពីនីតិវិធីលម្អិតសម្រាប់ការរៀបចំ និងអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ និងឯកសារណែនាំអនុវត្ត ស្តីពីការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ មានដំណើរការរៀបចំផែនការដូចមានសង្ខេបក្នុងដ្យាក្រាមខាងក្រោម៖

ដ្យាក្រាម៖ ដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់




សម្គាល់៖ ប្រអប់បង្ហាញទំហំការងារដែលត្រូវអនុវត្តតាមឯកសារណែនាំ

# ជំពូក ១៖ ព័ត៌មានស្តីពីស្ថានភាពឃុំទ្រា

## ១.១. ស្ថានភាពឃុំ

ឃុំទ្រា កាលដើមឡើយមានភូមិមួយឈ្មោះថា “ទ្រា” ជាឈ្មោះរបស់ភូមិមួយតាំងពីសម័យអាណានិគមនិយមបារាំង ហើយរហូតមកបច្ចុប្បន្ននេះ ក៏នៅតែមានឈ្មោះជាភូមិទ្រាដដែល លុះក្រោយមកទៀតក៏បានក្លាយពីភូមិទ្រានេះទៅជា **“ឃុំទ្រា”** វិញ រហូតដល់សព្វថ្ងៃនេះតាមប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ៤៩៣ប្រ.ក/ចុះថ្ងៃទី៣០-មេសា-២០០១ ។

### ១.១.១.ទីតាំងរដ្ឋបាលឃុំ

ឃុំទ្រា គឺជាឃុំមួយដែលស្ថិតនៅភាគខាងកើត និងមានចម្ងាយប្រហែល១,៥គីឡូម៉ែត្រពីរួមស្រុក ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលស្រុកស្ទោង ខេត្តកំពង់ធំ។ ហើយនៅក្នុងឃុំទ្រានេះមានផ្ទៃដីសរុបចំនួន ១២ ៣៥៥,៤៣ហិកតា( ប្រភពទិន្នន័យ៖ ក្រុមការងារGIS អេស ប៊ី ខេ ) មានព្រំប្រទល់ជាប់នឹង៖

- ខាងជើង ជាប់នឹង ឃុំ ពពក ស្រុកស្ទោង និងឃុំសាមគ្គី ស្រុកប្រាសាទបល្ល័ង្គ
- ខាងត្បូង ជាប់នឹង ឃុំ កំពង់ចិនត្បូង និងឃុំ សំព្រោជ ស្រុកស្ទោង
- ខាងកើត ជាប់នឹង ឃុំបន្ទាយស្ទោង ស្រុកស្ទោង និងឃុំដូង ស្រុកប្រាសាទបល្ល័ង្គ
- ខាងលិច ជាប់នឹង ឃុំកំពង់ចិនជើង និងឃុំប្រឡាយ ស្រុកស្ទោង (ភ្ជាប់ជាមួយផែនទីរដ្ឋបាលឃុំ)។

ឃុំនេះមានចំនួន១៦ភូមិ គឺ ភូមិទទា ភូមិកោះ ភូមិហប់ ភូមិវាល ភូមិសាមក្អោក ភូមិច្រាំងស ភូមិទ្រា ភូមិបុសតាឯក ភូមិតាចរ ភូមិលាបទង ភូមិផ្ទះវាល ភូមិស្លា ភូមិក្រសាំង ភូមិកុចទីទុយ ភូមិពពាយ ភូមិទំពេជ ។

តារាង 1៖ ស្ថានភាពទូទៅនៃឃុំ

| | | |
|---|---|---|
| **ខេត្ត** | កំពង់ធំ | លេខកូដខេត្ត:៦ |
| **ស្រុក** | ស្ទោង | លេខកូដស្រុក: ៦០៨ |
| **ឃុំ** | ទ្រា | លេខកូដឃុំ: ៦០៨១៣ |
| ចំនួន១៦ភូមិ | ១. ភូមិទទា | លេខកូដភូមិ: ៦០៨១៣០១ |
| | ២. ភូមិកោះ | លេខកូដភូមិ: ៦០៨១៣០២ |
| | ៣. ភូមិហប់ | លេខកូដភូមិ: ៦០៨១៣០៣ |
| | ៤. ភូមិវាល | លេខកូដភូមិ: ៦០៨១៣០៤ |
| | ៥. ភូមិសាមក្អោក | លេខកូដភូមិ: ៦០៨១៣០៥ |
| | ៦. ភូមិច្រាំងស | លេខកូដភូមិ: ៦០៨១៣០៦ |
| | ៧. ភូមិទ្រា | លេខកូដភូមិ: ៦០៨១៣០៧ |
| | ៨. ភូមិបុសតាឯក | លេខកូដភូមិ: ៦០៨១៣០៨ |
| | ៩. ភូមិតាចរ | លេខកូដភូមិ: ៦០៨១៣០៩ |
| | ១០. ភូមិលាបទង | លេខកូដភូមិ: ៦០៨១៣១០ |
| | ១១. ភូមិផ្ទះវាល | លេខកូដភូមិ: ៦០៨១៣១១ |
| | ១២. ភូមិស្លា | លេខកូដភូមិ: ៦០៨១៣១២ |

| | | |
|---|---|---|
| | ១៣. ភូមិក្រសាំង | លេខកូដភូមិៈ ៦០៨១៣១៣ |
| | ១៤. ភូមិកុចទីទុយ | លេខកូដភូមិៈ ៦០៨១៣១៤ |
| | ១៥. ភូមិពពាយ | លេខកូដភូមិៈ ៦០៨១៣១៥ |
| | ១៦. ភូមិទំពេជ | លេខកូដភូមិៈ ៦០៨១៣១៦ |

ប្រភពទិន្នន័យៈ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

ផែនទី 1៖ ផែនទីទីតាំងឃុំទ្រា ស្រុកស្ទោង



ផែនទី 2៖ ព្រំប្រទល់រដ្ឋបាលឃុំទ្រា



## ១.១.២.ប្រជាសាស្ត្រ

### ក. ចំនួនប្រជាជន

នៅក្នុងឃុំទ្រា ចែកចេញជា ១៦ភូមិ ដែលមានគ្រួសារសរុបចំនួន ២៨៧៤គ្រួសារ មានប្រជាជនសរុប ១៤៨០៦នាក់ ក្នុងនោះស្ត្រី ៧ ១៧២នាក់ ហើយប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងចំនួន ៨ ៣៥៨នាក់ ក្នុងនោះដែរស្ត្រីមានចំនួន ៤ ៦៣៩នាក់ ។ ភូមិដែលមានប្រជាជនច្រើនជាងគេ គឺភូមិលាបទង ដែលមានគ្រួសារសរុបចំនួន២៨៥គ្រួសារ ស្មើនឹង ១០,៩ភាគរយ ប្រជានជនសរុបចំនួន ១ ១៨៦នាក់ ស្ត្រីចំនួន ៦១៦នាក់ ហើយប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ មានចំនួន ៧៧៦នាក់ ក្នុងនោះស្ត្រីចំនួន ៤៦៧នាក់ ចំណែកឯភូមិ ដែលមានប្រជាជនតិចជាងគេ  គឺភូមិកោះមានចំនួន ៧៩គ្រួសារ ស្មើនឹង ២,៩ភាគរយ ប្រជាជនសរុបចំនួន ៣៦២នាក់ ស្ត្រីចំនួន ១៨១នាក់ ហើយប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន ២៥៤នាក់ ក្នុងនោះស្ត្រីមានចំនួន ១៤៥នាក់ ។  ទន្ទឹមនេះ ក៏សង្កេតឃើញប្រជាជននៅក្នុងឃុំ ស្ត្រីមានចំនួនច្រើនជាងបុរស ដូចមានក្នុងតារាងដែលក្រុមការងារបានរៀបចំសង្ខេបខាងក្រោម ។

តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ

| ឈ្មោះភូមិ | គ្រួសារ | គិតជា% | មនុស្ស | | | ១៨ឆ្នាំឡើង | | |
|---|---|---|---|---|---|---|---|---|
| | | | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ទទា | ១១៥ | ៤,៣ | ៥៨២ | ២៥៩ | ៣២៣ | ៤២៥ | ១៨៧ | ២៣៨ |
| កោះ | ៧៩ | ២,៩ | ៣៦២ | ១៨១ | ១៨១ | ២៥៤ | ១០៩ | ១៤៥ |
| ហប់ | ៩១ | ៣,៤ | ៣៦៨ | ១៧៧ | ១៩១ | ២៥៦ | ១១៣ | ១៤៣ |
| វាល | ១១១ | ៤,១ | ៥៤៨ | ២៦៥ | ២៨៣ | ៣០៩ | ១៨៨ | ១២១ |
| សាមក្អោក | ១៤២ | ៥,៣ | ៦៩៨ | ៣២៨ | ៣៧០ | ៤៦៧ | ២២២ | ២៤៥ |
| ច្រាំងសរ | ១៤៩ | ៥,៦ | ៦៦៤ | ៣២៨ | ៣៣៦ | ៤៥២ | ២០៥ | ២៤៧ |
| ទ្រា | ១៩១ | ៧,១ | ១១០០ | ៥៤៨ | ៥៥២ | ៦៦១ | ២៧៥ | ៣៨៦ |
| បុស្សតាឯក | ១៨៤ | ៦,៩ | ៨៧៦ | ៤១៧ | ៤៥៩ | ៥០៣ | ២៣១ | ២៧២ |
| តាចរ | ១២៧ | ៤,៧ | ៦៤៥ | ៣១៥ | ៣៣០ | ៣៨៧ | ១៧៦ | ២១១ |
| លាបទង | ២៨៥ | ១០,៦ | ១១៨៦ | ៥៧០ | ៦១៦ | ៧៧៦ | ៣០៩ | ៤៦៧ |
| ផ្ទះវាល | ២៨៣ | ១០,៦ | ១២៥៨ | ៦២០ | ៦៣៨ | ៨៣០ | ៣១៤ | ៥១៦ |
| ស្លា | ២០៤ | ៧,៦ | ១០៣៦ | ៥៣៥ | ៥០១ | ៧១៨ | ៣៥៤ | ៣៦៤ |
| ក្រសាំង | ៩៣ | ៣,៥ | ៤១៦ | ២០៤ | ២១២ | ២៨២ | ១៣៧ | ១៤៥ |
| កុចទីទុយ | ១៣៣ | ៥ | ៦៥៤ | ៣១៥ | ៣៣៩ | ៤៦៧ | ២១០ | ២៥៧ |
| ពពាយ | ២៦១ | ៩,៧ | ១២៥៨ | ៦០៩ | ៦៤៩ | ៨៤៣ | ៣៧៥ | ៤៦៨ |
| ទំពេជ | ២៣២ | ៨,៧ | ១២៤២ | ៦០៣ | ៦៣៩ | ៧២៨ | ៣១៤ | ៤១៤ |
| **សរុប** | **២ ៨៧៤** | **១០០** | **១៤ ៨០៦** | **៦ ២៧៤** | ៧ ១៧២ | **៨ ៣៥៨** | **៣ ៧១៩** | **៤ ៦៣៩** |

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ ២០១៨




*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

បើយោងទៅតាមតារាងស្ថិតិប្រជាជនតាមក្រុមអាយុនៅឆ្នាំ២០១៧ ក្នុងឃុំទ្រា បាបនបង្ហាញឱ្យឃើញថា ប្រជាជនពេញកម្លាំងពលកម្ម ដែលមានអាយុចាប់ពី ២៥ឆ្នាំ ដល់ ៦០ឆ្នាំ មានចំនួន ៤ ៣៤៩នាក់ ស្មើនឹង ៥៧% នៃប្រជាជនសរុបគឺលើស១/២បន្តិច ក្រៅពីនេះមានអាយុចាប់ពីកើតដល់ ២៤ឆ្នាំ មានចំនួន ២ ៦៤១នាក់ ស្មើប្រហាក់ប្រហែល ៣២ភាគរយ នៃប្រជាជនសរុប និងប្រជាជនមានអាយុចាប់ពី ៦១ឆ្នាំឡើង ដែលជាអ្នកបានចូលនិវត្តន៍បាត់បង់សមត្ថភាពការងារមានចំនួន ១ ១០០នាក់ ស្មើប្រហាក់ប្រហែល ១១ភាគរយ នៃប្រជាជនសរុប ។ ដូច្នេះសន្និដ្ឋានបានថា នៅក្នុងឃុំទ្រា មានមនុស្សពេញកម្លាំងពលកម្មមួយនាក់ ដែលរកចំណូលបានគិតជាមធ្យមត្រូវចិញ្ចឹមមនុស្សជិតពីរនាក់បន្ថែម ។

តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ

| តាមក្រុមអាយុ | ២០១៧ | | | ផ្សេងៗ |
|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | |
| អាយុពី០-២ឆ្នាំ | ៨៧៤ | ៣៨៤ | ៤៩០ | កុមារ |
| អាយុពី៣-៤ | ៧៣១ | ៣៩៩ | ៣៣២ | អាយុចូលរៀនសាលាមត្តេយ្យ |
| អាយុពី៥ឆ្នាំ | ៥០៧ | ៣១១ | ១៩៦ | អាយុចូលរៀនសាលាមត្តេយ្យ |
| អាយុពី៦ឆ្នាំ | ៤៨១ | ២៧៨ | ២០៣ | អាយុចូលរៀនសាលាបឋម |
| អាយុពី៧-១១ឆ្នាំ | ១៣០៩ | ៧២៧ | ៥៨២ | អាយុចូលរៀនសាលាបឋម |
| អាយុពី១២-១៤ឆ្នាំ | ៨៧៧ | ៤៨២ | ៣៩៥ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី១៥-១៧ឆ្នាំ | ៩១២ | ៤៩៦ | ៤១៦ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី១៨-២៤ឆ្នាំ | ១៧៦៧ | ៩០២ | ៨៦៥ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី២៥-៣៥ឆ្នាំ | ២៤៨៨ | ១២៨៣ | ១២០៥ | អាយុពេញពលកម្ម |
| អាយុពី៣៦-៤៥ឆ្នាំ | ១៨៩៩ | ៩៥៣ | ៩៤៦ | អាយុពេញពលកម្ម |
| អាយុពី៤៦-៦០ឆ្នាំ | ១៨៦១ | ៩០៨ | ៩៥៣ | អាយុពេញពលកម្ម |
| អាយុពី៦១ឆ្នាំឡើង | ១១០០ | ៥១១ | ៥៨៩ | អាយុចូលនិវត្តន៍ |
| **សរុប** | **១៤ ៨០៦** | **៧ ៦៣៤** | **៧ ១៧២** | |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៧*

### ខ. អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន

ដោយយោងតាមប្រភពទិន្នន័យ ឆ្នាំ២០១៧ បានឱ្យដឹងថា អត្រាកំណើនប្រជាជនពីចន្លោះឆ្នាំ២០១៣ ដល់ឆ្នាំ ២០១៧ បង្ហាញឱ្យឃើញថា អត្រាកំណើនប្រជាជននៅក្នុងឃុំទ្រា មានការធ្លាក់ចុះនៅឆ្នាំ ២០១៥ មានអត្រាកំណើនប្រជាជនចំនួន -0,៨៤ភាគរយ ដែលមានប្រជាជនចំនួន ១២ ៨១៥នាក់ ហើយកត្តានៃការធ្លាក់ចុះចំនួនប្រជាជននេះ ដោយសារគ្រួសារខ្លះបានយល់ដឹងពីកម្មវិធីពន្យាកំណើតជាបណ្តើរៗម្យ៉ាងវិញទៀតដោយសារមានការធ្វើចំណាកស្រុក ដើម្បីប្រកបរបរចិញ្ចឹមជីវិត និងការផ្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ប៉ុន្តែអត្រាកំណើននេះមានកើនឡើងខ្ពស់នៅឆ្នាំ២០១៧ ដែលមានអត្រាកំណើនប្រជាជនមានចំនួន ១២,៥១ភាគរយ ស្មើនឹង ១៤ ៨០៦នាក់ មូលហេតុនៃការកើនឡើងនេះដោយសារ កម្រិតជីវភាពល្អប្រសើរ ចំណូលស្រុក អត្រាកំណើតច្រើន អត្រាមរណៈទាប ហើយនៅក្នុងនោះអត្រាកំណើនប្រជាជនជាមធ្យម ៣,៥៣ភាគរយ ដែលមានដង់ស៊ីតេប្រជាជនជាមធ្យមមាន ១០៤នាក់/គ.ម២។ ប្រជាជនភាគច្រើនចូលចិត្តរស់នៅជាលក្ខណៈប្រមូលផ្តុំគ្នាតាមនៅជងផ្លូវ ឬតាមទីប្រជុំជន ជាពិសេលនៅតាមបណ្តោយផ្លូវជាតិលេខ៦ និងផ្លូវសំខាន់ៗនៅក្នុងឃុំ ។

តារាង 4៖ ស្ថិតិប្រជាជនតាមបណ្តាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម

| ចំនួន | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | កំណើនមធ្យម |
|---|---|---|---|---|---|---|---|
| ចំនួនប្រជាជនសរុប | ១២៥១១ | ១២៨៧៧ | ១២៩២៣ | ១២៨១៥ | ១៣១៦០ | ១៤៨០៦ | |
| កំណើនមធ្យម(%) | | **២,៩៣** | **០,៣៦** | **-0,៨៤** | **២,៦៩** | **១២,៥១** | **៣,៥៣** |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំទ្រា ខែសីហា ឆ្នាំ២០១៨*

**☞ចំណាំ**

- អត្រាកំណើនសម្រាប់ចន្លោះឆ្នាំនិមួយៗ៖ (ឆ្នាំចុងក្រោយ-ឆ្នាំដំបូង)x១០០/ឆ្នាំដំបូង
- អត្រាកំណើនមធ្យមប្រចាំឆ្នាំ៖ (បូកសរុបអត្រាកំណើនតាមឆ្នាំនិមួយ/ចំនួនឆ្នាំ)

### គ. ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់

នៅក្នុងឃុំទ្រាមានជនជាតិខ្មែរ និងខ្មែរកាត់ចិន ហើយភាគច្រើនកាន់សាសនាព្រះពុទ្ធ និងចំនួនតិចតួចកាន់សាសនាគ្រឹស្ត ហើយប្រជាជនភាគច្រើននៅក្នុងឃុំគោរពប្រពៃណី និងទំនៀមទម្លាប់បែបខ្មែរដូចជា ពិធីរៀបមង្គលការប្រារព្ធពីធីបុណ្យទាននៅតាមវត្តអារាមនិងតាមផ្ទះ និមន្តព្រះសង្ឃសូត្រមន្តតាមផ្ទះ ពិធីបូជាសព និងមួយចំនួនតិចមានទំនៀមទម្លាប់បែបចិនដូចជាពិធីសែនព្រេនដូនតា ពីធីបញ្ចុះសព និងភាគតិចបំផុតមានទំនៀមទម្លាប់បែបសាសនាគ្រឹស្ត ដូចជា មានប្រារព្ធពិធីចូលព្រះវិហារគ្រឹស្តនៅរៀងរាល់ថ្ងៃអាទិត្យជាដើម។ល។ និយាយរួមប្រជាជនក្នុងឃុំទ្រា តែងតែប្រារព្ធពិធីបុណ្យទានតាមប្រពៃណីទំនៀមទំលាប់ពីបុរាណរៀងមក តាមជំនឿបែបខ្មែរ បែបចិន និងបែបគ្រឹស្តសាសនា ។

### ឃ. របររកទទួលទាន

បើយោងទៅតាមទិន្នន័យពីមន្ទីរផែនការនៅឆ្នាំ២០១៧ ក្នុងតារាងខាងក្រោម បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំទ្រា អ្នកមានមុខរបរចម្បងចំនួន ៦ ៥២៧នាក់ ស្មើនឹង ៨១,៤ភាគរយ ហើយនៅក្នុងនោះប្រជាពលរដ្ឋភាគច្រើនប្រកបរបរកសិកម្មជាចម្បងចំនួន ៤ ៧៧៨ នាក់ ស្មើនឹង ៧៣,២ ភាគរយ អ្នកប្រកបមុខរបរសិប្បកម្ម ចំនួន ៦៥នាក់ ស្មើនឹង ១ភាគរយ និងអ្នកប្រកបមុខរបរសេវាកម្មមានចំនួន ១៦៨៤នាក់ ស្មើនឹង ២៥,៨ភាគរយ

មុខរបរទាំងអស់នោះមានដូចជា៖ នេសាទត្រី ធ្វើស្រែ ចិញ្ចឹមសត្វ ចិញ្ចឹមក្រពើ ឡើងត្នោត ដាំដំណាំបន្លែ កម្មករសំណង់ ស៊ីឈ្នួលដកស្ទូងតិចតួច លក់ដូរ ជាងជួសជុលកង់ ម៉ូតូ រថយន្ត ជាងកាត់សក់ ជាមន្ត្រីរាជការ អាជីវករលក់ដូរធ្វើការជាមួយវិស័យឯកជន និងអង្គការនានា ហើយភាគច្រើនធ្វើការមានជំនាញច្បាស់លាស់ ។

តារាង 5៖ តារាងមុខរបរ

| បរិយាយ | | ២០១៦ | ២០១៧ |
|---|---|---|---|
| សរុបអ្នកមានមុខរបរចម្បង | | ៦ ០២៧ | ៦ ៥២៧ |
| %សរុបអ្នកមានមុខរបរចម្បង | | ៨២,0 | ៨១,៤ |
| %ស្រីមានមុខរបរចម្បង(គិតក្នុងស្រី១៨-៦0ឆ្នាំ) | | ៦៥,៤ | ៦៥,៨ |
| %ប្រុសមានមុខរបរចម្បង(គិតក្នុងប្រុស១៨-៦0ឆ្នាំ) | | ៧៩,៩ | ៧៧,៤ |
| **សរុបអ្នកមានមុខរបរចម្បងក្នុងផ្នែកកសិកម្ម** | | **៤ ៥២១** | **៤ ៧៧៨** |
| **%អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម(គិតក្នុងមុខរបរចម្បង)** | | **៧៥,0** | **៧៣,២** |
| **%ស្រីមានមុខរបរចម្បងផ្នែកកសិកម្ម(គិតក្នុងមុខរបរចម្បង)** | | **៣៨,៤** | **៣២,៨** |
| ក្នុងនោះ: | %អ្នកមានមុខរបរធ្វើស្រែ | ៦៦,៥ | ៦៥,១ |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលវែង | 0,៧ | ១,១ |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលខ្លី | ១,៨ | ១,៦ |
| | %អ្នកមានមុខរបរដាំដំណាំបន្លែ | ២,៣ | ២,៣ |
| | %អ្នកមានមុខរបរនេសាទ | 0,៥ | 0,៥ |
| | %អ្នកមានមុខរបរចិញ្ចឹមសត្វ | ២,0 | ១,៦ |
| | %អ្នកមានមុខរបរពីអនុផលព្រៃឈើ | ១,៣ | ១,0 |
| **សរុបអ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសិប្បកម្ម** | | **៤៤** | **៦៥** |
| **%អ្នកបម្រើការងារក្នុងផ្នែកសិប្បកម្ម** | | **0,៧** | **១,0** |
| **%ស្រីបម្រើការងារក្នុងផ្នែកសិប្បកម្ម** | | **0,៤** | **0,៤** |
| ក្នុងនោះ: | %អ្នកបម្រើការងារសិប្បកម្មត្បាញរវៃ | 0,0 | 0,0 |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីផ្តៅ វល្លិ ល្ពាក់... | 0,0 | 0,0 |
| | %អ្នកបម្រើការងារសិប្បកម្មផលិតគ្រឿងសង្ហារឹម | 0,0 | 0,១ |
| | %អ្នកបម្រើការងារសិប្បកម្មចម្លាក់ធ្វើពីឈើ ថ្ម ស្ពាន់.. | 0,0 | 0,0 |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីដែក អាលុយមីញ៉ូម | 0,0 | 0,0 |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីជ័រ ផ្លាស្ទិក ...l | 0,0 | 0,0 |
| | %អ្នកបម្រើការងារសិប្បកម្មកែច្នៃ ឬ វិចខ្ចប់គ្រាប់ធញ្ញជាតិ | 0,0 | 0,0 |
| | %អ្នកបម្រើការងារសិប្បកម្មផលិតផ្សេងៗ | 0,៦ | 0,៩ |
| **សរុបអ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម** | | **១ ៤៦២** | **១ ៦៨៤** |
| **%អ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម** | | **២៤,៣** | **២៥,៨** |
| **%ស្រីបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម** | | **១0,១** | **១២,៦** |

| បរិយាយ | | ២០១៦ | ២០១៧ |
|---|---|---|---|
| ក្នុងនោះ | %អ្នកបម្រើការងារលក់ដូរ និងជំនួញ | ៥,៥ | ៥,៣ |
| | %អ្នកបម្រើការងារជាជាងជួសជុល | ០,៣ | ០,៣ |
| | %អ្នកបម្រើការងារក្នុងផ្នែកដឹកជញ្ជូន | ១,៣ | ០,៥ |
| | %អ្នកបម្រើការងារស៊ីឈ្នួលក្នុងវិស័យកសិកម្ម កម្មករសំណង់ | ៦,៥ | ៨,៦ |
| | %អ្នកបម្រើការងារក្នុងវិស័យឯកជន(កម្មកររោងចក្រ បុគ្គលិក អង្គការ) | ៩,៨ | ៩,៧ |
| | %អ្នកបម្រើការងារជាមន្ត្រីរាជការ | ០,៩ | ១,៤ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

ប្រជាពលរដ្ឋក្នុងឃុំទ្រា ពួកគាត់បានបង្កើតមុខរបរបន្ទាប់បន្សំបន្ថែមទៀត ក្រៅពីមុខរបរចម្បង គឺដើម្បីទ្រទ្រង់ជីវភាពក្នុងគ្រួសារឱ្យកាន់តែប្រសើរឡើង។ យោងទៅតាមទិន្នន័យមន្ទីរផែនការឆ្នាំ២០១៧ បានបង្ហាញឱ្យឃើញថា ប្រជាជនដែលមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្មចំនួន ១៧៥៦នាក់ ស្មើនឹង ៦៧,០ភាគរយ ក្នុងនោះមានស្ត្រីចំនួន ៧៦៣នាក់ ស្មើនឹង ២៩,១ភាគរយ ហើយអ្នកដែលមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្មមានចំនួន ៣៣,០ភាគរយ ក្នុងនោះមានស្រី ១២,៤ភាគរយ និងមិនមានអ្នកប្រកបមុខរបរសិប្បកម្មនៅក្នុងឃុំនោះទេ ។

តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ

| បរិយាយ | ២០១៧ | ២០១៧ចំនួន(នាក់) |
|---|---|---|
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម | ៦៧,0% | ១ ៧៥៦នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម | ២៩,1% | ៧៦៣នាក់ |
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម | 0,0% | 0នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម | 0,0% | 0នាក់ |
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម | ៣៣,0% | 0នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម | ១២,4% | ៣២៥នាក់ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

### ង. ចំណូលស្រុក និងចំណាកស្រុក

កត្តាដែលធ្វើឱ្យមានការផ្លាស់ប្តូរលំនៅឋាន គឺដោយសារនៅភូមិចាស់ដែលគាត់បានរស់នៅពិបាកក្នុងការរកស៊ី និងគ្មានការងារធ្វើនៅក្នុងភូមិ ព្រមទាំងមូលហេតុមួយចំនួនទៀត ដូចជា៖ ស្ថានភាពដី នៅក្នុងតំបន់មូលដ្ឋានមួយចំនួនមានការប្រែប្រួលខូចដី ងាប់សារជាតុបម្រុង ហើយឡើងខ្សោះជីជាតិ ឬដីហិរ ខ្វះប្រភពទឹក ធ្វើឱ្យទទួលបានទិន្នផលទាប តម្លៃផលិតផលកសិកម្មមិនទៀងទាត់ និងគ្មានទីផ្សារផលិតផល ចំណែកសមាជិកគ្រួសារកើនឡើង និងមួយចំនួនជាប់បំណុលធនាគារ និងមីក្រូហិរញ្ញវត្ថុជាដើម ។ល។ ការផ្លាស់ប្តូរលំនៅឋានរបស់ប្រជាជនមួយចំនួនទៅរស់នៅទីប្រជុំជនឃុំ/សង្កាត់ ស្រុក/ក្រុង រាជធានី/ខេត្ត និងទៅធ្វើការងារនៅប្រទេសផ្សេងៗ ។ មូលហេតុចម្បងនៃការធ្វើចំណាកស្រុកគ្រប់ប្រភេទ គឺក្នុងគោលបំណងលើកស្ទួយតម្លៃសេដ្ឋកិច្ចគ្រួសារ ។ តាមរបាយការណ៍របស់រដ្ឋបាលឃុំ នៅក្នុងឃុំទ្រា មានគ្រួសារផ្លាស់លំនៅឋានចូលចំនួន ៤៥គ្រួសារ ប្រជាជនសរុបមានចំនួន ៩០នាក់ ស្រី ៤៥នាក់ និងគ្រួសារផ្លាស់លំនៅឋានចេញមាន ០៥គ្រួសារ ប្រជាជនសរុប ១០នាក់ ក្នុងនោះស្រី ០៥នាក់ ។

តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧

| ល.រ | បរិយាយ | ចំនួនគ្រួសារ | ចំនួនប្រជាជនសរុប | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| ១ | ចំនួនគ្រួសារផ្លាស់លំនៅឋានចូល | ៤៥ | ៩០ | ៤៥ |
| ២ | ចំនួនគ្រួសារផ្លាស់លំនៅឋានចេញ | ៥ | ១០ | ៥ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ នឹងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

បើយោងទៅតាមទិន្នន័យមន្ទីរផែនការខេត្តឆ្នាំ ២០១៧ បានបង្ហាញថានៅក្នុងឃុំទាំងមូលមានប្រជាជនក្នុងឃុំទ្រាមានការប្រែប្រួលថយចុះ ដោយសារប្រជាជនមួយចំនួនធ្វើចំណាកស្រុកចេញទៅរកស៊ីនៅស្រុកផ្សេងៗ ឬទៅប្រទេសជិតខាង ដូចជា៖ ប្រទេសថៃ ម៉ាឡេស៊ី ជប៉ុន សិង្ហបុរី កាណាដា អូស្ត្រាលី និងកូរ៉េជាដើម ។ នៅក្នុងឃុំទាំងមូលប្រជាពលរដ្ឋធ្វើចំណាកស្រុកមានចំនួន ២ ៥៤៣នាក់ ស្រីចំនួន ៩៦៦នាក់ នៅក្នុងនោះចំនួនអ្នកធ្វើចំណាកស្រុកក្នុងប្រទេសមានចំនួន ១៣៨៧នាក់ ស្រីមានចំនួន ៥៩៧នាក់ និងចំនួនអ្នកធ្វើចំណាកស្រុកក្រៅប្រទេសមានចំនួន ១១៥៦នាក់ និងស្រីចំនួន ៣៦៩នាក់ ហើយកត្តាដែលបណ្តាលឱ្យមានចំណាកស្រុកបែបនេះដោយសារ៖

- គ្មានដីបង្កបង្កើនផលសម្រាប់វិស័យកសិកម្ម និងមួយចំនួនមានដីកសិកម្មតិចតួចធ្វើស្រែមិនសូវបានផលល្អ
- ការធ្វើស្រែចម្ការបានតែមួយរដូវ និងតម្លៃទីផ្សារមិនទៀងទាត់
- មិនមានការងារគ្រប់គ្រាន់នៅក្នុងស្រុក
- ជំពាក់បំណុលធនាគារ ឬឯកជនមិនមានលិទ្ធភាពសង
- គ្មានមុខរបរច្បាស់លាស់ និងមានប្រាក់ចំណូលប្រចាំថ្ងៃទាប
- ដើម្បីរកចំណូលបន្ថែមនៅស្រុកផ្សេង
- លក់ដីនៅក្នុងឃុំ ហើយទៅទិញនៅកន្លែងដែលមានតម្លៃទាប

តារាង ៨៖ ស្ថិតិប្រជាជនចំណាកស្រុក

| បរិយាយ | ២០១៦ | | | ២០១៧ | | |
|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ចំនួនអ្នកធ្វើចំណាកស្រុកក្នុងប្រទេស | ១០៨៣ | ៦២៣ | ៤៦០ | ១៣៨៧ | ៧៩០ | ៥៩៧ |
| ចំនួនអ្នកធ្វើចំណាកស្រុកក្រៅប្រទេស | ៨៩៤ | ៦២០ | ២៧៤ | ១១៥៦ | ៧៨៧ | ៣៦៩ |
| **សរុប** | **១ ៩៧៧** | **១ ២៤៣** | **៧៣៤** | **២ ៥៤៣** | **១ ៥៧៧** | **៩៦៦** |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំទ្រា ខែមិថុនា ឆ្នាំ២០១៨*

### ១.១.៣.ស្ថានភាពសេដ្ឋកិច្ច

#### ក. ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ

បើយោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន នៅត្រង់ចំណុចនៃការវិភាគចំណាត់ថ្នាក់ទ្រព្យធនបានឱ្យដឹងថា គ្រួសារដែលមានជីវភាពគ្រាន់បើ មធ្យម ក្រ និងក្រណាស់ មានប្រភពចំណូលទី១ គឺ

ដំណាំស្រូវ  ប្រភពចំណូលទី២ គឺចំណាកស្រុក (ភ្នំពេញ និងប្រទេសថៃ) និងប្រភពចំណូលទី៣ គឺលក់ដូរ ក្រៅពីនោះមានកម្មកររោង ចក្រលក់ដូរ សំណង់។ ចំណែកគ្រួសារក្រណាស់មានប្រភពចំណូលតែមួយគត់ គឺលក់ពលកម្ម។

### ខ. កម្រិតជីវរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ

បើយោងទៅតាមតារាងចំណាត់ថ្នាក់ទ្រព្យធននៅក្នុងឆ្នាំ២០១៧ដែលទទួលបានមកពីរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានខាងលើ បានបង្ហាញឱ្យឃើញថា នៅក្នុងឆ្នាំ២០១៧ ប្រជាពលរដ្ឋក្នុងឃុំទ្រា មានកម្រិតជីវភាពរស់នៅចែកចេញជាបួនកម្រិតគឺ  ១)គ្រួសារបង្គួរ/គ្រាន់បើ មានចំនួន ២០ភាគរយ ដែលជាគ្រួសារមានកម្រិតជីវភាពធូរធាជាងគេមានដីកាន់កាប់ពី  ៣ហិកតា  ២)គ្រួសារមធ្យមមានចំនួន  ៤០ភាគរយ  ជាចំនួនច្រើនជាងគេមានដីកាន់កាប់ពី ០១ហិកតា ៣)គ្រួសារក្រមានចំនួន ៣០ភាគរយ មានដីកាន់កាប់ពី ០,៤០ហិកតា និង ៤)គ្រួសារក្រណាស់ដែលជាគ្រួសារក្រីក្របំផុត និងមានចំនួនតិចជាងគេត្រឹមតែ១០ភាគរយ មានដីកាន់កាប់ ០,២០ហិកតាចុះក្រោមរហូតដល់អ្នកគ្មានដី ។

តាមរយៈការសាកសួរជាមួយនឹងក្រុមប្រឹក្សាឃុំទ្រា  បានបង្ហាញថាចំណូលប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ជាមធ្យមចាប់ពី ១៥០០០ ទៅ ២០០០០រៀល ១គ្រួសារ/ថ្ងៃ និងចាប់ពី៥៤៧៥០០០រៀល ទៅ៧៣០០០០០រៀល ១គ្រួសារ/ឆ្នាំ  ចំណែកការចំណាយប្រចាំឆ្នាំដូចជា៖  ស្បៀងអាហារ  សម្លៀកបំពាក់  ឧបករណ៍ប្រើប្រាស់  សម្ភារសិក្សា និងថ្នាំសង្កូវព្រមទាំងចំណាយផ្សេងៗចាប់ពី៥ ៤៧៥ ០០០រៀល ទៅ ៦ ៥៧០០០០រៀល/គ្រួសារ/ឆ្នាំ។

តារាង ១៖ តារាងកម្រិតជីវភាពរបស់ប្រជាជន

| ចំណាត់ថ្នាក់ធនធាន | បង្គួរ/គ្រាន់បើ | មធ្យម | ក្រ | ក្រណាស់/គ្មានដី | សរុប |
|---|---|---|---|---|---|
| **ប្រៀបធៀបជា**(%) **តំបន់ទីI** | ២០% | ៤០% | ៣០% | ១០ | ១០០% |
| **តំបន់ទីII** | ២០% | ៤១% | ២៧% | ១២% | ១០០% |
| **តំបន់ទីIII** | ១៥% | ៤២% | ១៨% | ២៥% | ១០០% |
| **ទូទាំងឃុំ** | **១៨,៣៣%** | **៤១%** | **២៥%** | **១៥,៦៧%** | **១០០%** |
| **ទំហំគ្រួសារ** | ៤នាក់/គ្រួសារ | ៤នាក់/គ្រួសារ | ៥នាក់/គ្រួសារ | ៦នាក់/គ្រួសារ | |
| **កម្លាំងពលកម្ម** | ៣នាក់/គ្រួសារ | ៣នាក់/គ្រួសារ | ២នាក់/គ្រួសារ | ២នាក់/គ្រួសារ | |
| **ទំហំដីកាន់កាប់សរុប**(ហ.ត) | ៣ | ១ | ០,៤០ | ០,២០ | |
| **ចំនួននិងប្រភេទក្បាលដី** | ៥ | ៣ | ២ | ១ | |
| **ដីលំនៅឋាន**(ហ.ត) | ០,១០ | ០,០៧ | ០,០៥ | ០,០២ | |
| **ដីស្រែ**(ហ.ត) | ៣ | ១ | ០,៤០ | គ្មាន | |
| **ដីផ្សេងៗទី១បន្លែ**(ហ.ត) | ០,១០ | ០,១០ | ០,១០ | គ្មាន | |
| **ប្រភេទពូជស្រូវដាំដុះ** | រំដួល ម្លិះ | រំដួល ម្លិះ | រំដួល ម្លិះ | គ្មាន | |
| **ដំណាំទី១៖** ស្រូវ (ហ.ត) | ៣ | ១ | ០,៤០ | គ្មាន | |
| **ដំណាំទី២៖** បន្លែ(ហ.ត) | ០,១០ | ០,១០ | ០,១០ | គ្មាន | |

| | | | | | |
|---|---|---|---|---|---|
| **ការចិញ្ចឹមត្រីគ្រួសារ** | ១០ | ២០ | គ្មាន | គ្មាន | |
| **ចំនួនគោក្បាល/គ្រួសារ** | ២ | ២ | ១ | គ្មាន | |
| **ចំនួនក្របីក្បាល/គ្រួសារ** | ២ | ២ | ១ | គ្មាន | |
| **ចំនួនជ្រូក** | មានតិចតួច | មានតិចតួច | គ្មាន | គ្មាន | |
| **ការប្រើប្រាស់ឧបករណ៍នេសាទ** | | មងសំណាញ់ ទ្រូ សន្ទូច ឈឹប/អន្ទង សាបត្រី ...... | បង់សំណាញ់ ដាក់ទ្រូ ចងសន្ទូច អូស.ឈឹប /អន្ទង ដាក់សាបត្រី | | |
| **ប្រភពចំណូលទី១៖** | ដំណាំស្រូវ | ស្រូវ | កម្លាំងពលកម្ម | កម្លាំងពលកម្ម | |
| **ប្រភពចំណូលទី២៖** | ចំណាកស្រុក (ភ្នំពេញ និងប្រទេសថៃ) | ចំណាកស្រុក (ភ្នំពេញ និងប្រទេសថៃ) | ចំណាកស្រុក (ភ្នំពេញ និងប្រទេសថៃ) | ចំណាកស្រុក (ភ្នំពេញ និងប្រទេសថៃ) | |
| **ប្រភពចំណូលទី៣៖** | លក់ដូរ | លក់ដូរ និងកម្លាំងពលកម្ម | លក់ដូរតិចតួច | គ្មាន | |
| **ការងារក្រៅពីកសិកម្ម** (**ប្រភេទពលកម្ម**) | កម្មកររោងចក្រ លក់ដូរ សំណង់ | កម្មកររោងចក្រ លក់ដូរ សំណង់ | កម្មកររោងចក្រ លក់ដូរសំណង់ | គ្មាន | |
| **ការប្រើប្រាស់ឥណទាន** | ៨០% | ៧០% | ៦៥% | ៤៨% | |

ប្រភពទិន្នន័យ៖ *របាយការណ៍ក្បេត្របរិស្ថា និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

### គ. ស្ថានភាពបំណុល និងអាត្រាការប្រាក់

ប្រជាពលរដ្ឋនៅក្នុងឃុំទ្រាមានចំនួន ៦៨៤គ្រួសារ ស្មើនឹងប្រមាណ ៤,៦២ភាគរយ ដែលមានបំណុលពីមីក្រូហិរញ្ញវត្ថុ និងធនាគារ ដូចមានរាយខាងក្រោម៖

- អ្នកមានជីវភាពបង្គួរ៖ មានលទ្ធភាពខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ។ល។
- អ្នកមានជីវភាពមធ្យម៖ មានលទ្ធភាពខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ។ល។
- អ្នកមានជីវភាពខ្សត់ខ្សោយក្រ៖ ពុំអាចមានលទ្ធភាពខ្ចីប្រាក់ពីធនាគារ ឬមីក្រូហិរញ្ញវត្ថុឯកជនដោយសារគ្មានទ្រព្យប្រចាំ តែត្រូវខ្ចីប្រាក់បន្តពីអ្នកមានជីវភាពបង្គួរ និងមធ្យម។
- ចំណែកអ្នកក្របំផុត៖ ប្រកបរបរដោយលក់កម្លាំងពលកម្ម និងធ្វើចំណាកស្រុក។

នៅក្នុងឃុំទ្រា មិនមានទីតាំងមីក្រូហិរញ្ញវត្ថុ ឬក៏សាខាធនាគារទេ ហើយក្នុងនោះដែរប្រជាពលរដ្ឋបានទទួលសេវាកម្ចីលុយពីមីក្រូហិរញ្ញវត្ថុ និងធនាគារមួយចំនួននៅក្រៅឃុំមានដូចជា៖ ធនាគារអេស៊ីលីដា ធនាគារស្ថាបនា ធនាគារប្រៃសណីយ៍ និងមីក្រូហិរញ្ញវត្ថុអម្រឹត មីក្រូហិរញ្ញវត្ថុហត្ថាកសិករ មីក្រូហិរញ្ញវត្ថុប្រាសាក់ មីក្រូហិរញ្ញវត្ថុអេអឹមខេ មីក្រូហិរញ្ញវត្ថុវីសិនហ្វាន់ មីក្រូហិរញ្ញវត្ថុក្រេឌីត មីក្រូហិរញ្ញវត្ថុសហគ្រិន មីក្រូហិរញ្ញវត្ថុ អិលអូ

អិលស៊ី និងសហគមន៍សន្សំប្រាក់៣ភូមិអត្រាកាប្រាក់៣ភាគរយ ហើយសម្រាប់អត្រាការប្រាក់ អាស្រ័យទៅលើចំនួនទឹកប្រាក់ដែលខ្ចី បើចំនួនប្រាក់កាន់តែច្រើន អត្រាការប្រាក់កាន់តិច ០,៩៩ភាគរយ តែបើទឹកប្រាក់កាន់តិច អត្រាការប្រាក់កាន់តែច្រើន ១,៨ភាគរយ ។

### ឃ. ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ

ជាទូទៅនៅក្នុងឃុំទ្រា ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់សុទ្ធ ដើម្បីយកទៅប្រើប្រាស់ពង្រីកមុខរបរ ចងការបន្ត ទិញសម្ភារៈកសិកម្ម ទិញជី និងប្រើប្រាស់តាមតម្រូវការចាំបាច់ផ្សេងៗទៀត ក៏នៅមានក្រោមរូបភាពប្រជាពលរដ្ឋមួយចំនួនទៅទទួលយកជីដាក់ស្រូវមុននិងសន្យាសងប្រាក់នៅពេលប្រមូលផលស្រូវផងដែរ។

### ង. ចំណូលពីប្រភពផ្សេងៗ

ប្រជាពលរដ្ឋនៅក្នុងឃុំទ្រា ពួកគាត់អាចទទួលបានប្រភពចំណូលពីប្រភពផ្សេងៗដូចជា៖

- លក់កម្លាំងពលកម្ម( ស៊ីឈ្នួលស្ទូង ច្រូត ដកស្មៅ ដឹកជញ្ជូន )
- ចំណាកស្រុកក្នុងប្រទេស( ជាជាងសំណង់ រោងចក្រ ក្រុមហ៊ុន )
- ចំណាកស្រុកក្រៅប្រទេស( ពលករផ្នែក កសិកម្ម ឧស្សាហកម្ម )
- គ្រួសារឬបងប្អូនរស់នៅជាអចិន្ត្រៃយ៍នៅបរទេស។

## ១.១.៤.ស្ថានភាពអប់រំ និងសិក្សាធិការ

### ក. ស្ថានភាពអប់រំ

យោងតាមផែនការអភិវឌ្ឍន៍ឃុំទ្រា៥ឆ្នាំ (២០១៧-២០២២) បានឱ្យដឹងថា ជារៀងរាល់ឆ្នាំកុមារាកុមារីគ្រប់អាយុចូលរៀន បានចុះឈ្មោះចូលរៀនគ្រប់គ្នា ទោះបីជាកុមារ ស្ថិតនៅក្នុងស្ថានភាពគ្រួសារក្រីក្រ គ្រួសារដែលជាស្ត្រីមេម៉ាយឬក្មេងកំព្រា កុមារពិការក៏ដោយក្តី ។ មកដល់ពេលបច្ចុប្បន្ន វិស័យអប់រំនៅក្នុងឃុំទ្រា មានការរីកចម្រើនដូចជា៖ អគារសិក្សាត្រូវបានសាងសង់ថ្មីៗ និងមានការកែលម្អបន្ទប់រៀនថែមទៀត នៅតាមសាលារៀនគ្រប់កម្រិត ដែលផ្តល់លទ្ធភាពឱ្យសិស្សបានរៀនសូត្រគ្រប់ពេលពុំមានការខ្វះខាតឡើយ ។ ចំណុចអវិជ្ជមានក៏មាននៅក្នុងឃុំផងដែរដូចជា៖ ខ្វះគ្រូបង្រៀន មិនទាន់មានសាលាមត្តេយ្យសហគមន៍គ្រប់គ្រាន់នៅតាមតាមភូមិនៅឡើយ មានអ្នកមិនចេះអក្សរ(អនក្ខរជន) ជាពិសេសមនុស្សមានវ័យចំណាស់ ពួកគាត់ពុំសូវមានស្មារតីសិក្សារៀនសូត្រ ទោះបីមានការយកចិត្តទុកដាក់ជម្រុញលើកទឹកចិត្តពីអាជ្ញាធរមូលដ្ឋានយ៉ាងណាក៏ដោយ ។

រូបភាព 1៖ សាលារៀន


សាលាបឋមសិក្សា


សាលាវិទ្យាល័យ

នៅក្នុងឃុំទ្រា មានកម្រិតសិក្សាចាប់ពីមត្តេយ្យសិក្សារហូតដល់វិទ្យាល័យ ។ ហើយឃុំនេះមានសាលាមត្តេយ្យចំនួន ០៣កន្លែង ០៣បន្ទប់ ០៥ថ្នាក់ គ្រូបង្រៀនចំនួន ២នាក់ជាស្ត្រី និងសិស្សកំពុងរៀនចំនួន ៩៦នាក់ ស្រីចំនួន ៤២នាក់ ។ សាលាបឋមសិក្សាវិញមានចំនួន ០៦កន្លែង ៤២បន្ទប់ ៥០ថ្នាក់ គ្រូបង្រៀនចំនួន ៤១នាក់ មានស្ត្រី ២០នាក់ ហើយសិស្សដែលកំពុងរៀនមានចំនួ ១៨១៥នាក់ ដែលមានសិស្សស្រីចំនួន ៩៣៥នាក់ ។ ចំណែកឯសាលាអនុវិទ្យាល័យមានចំនួន ០១កន្លែង ១១បន្ទប់ ១១ថ្នាក់ ហើយគ្រូបង្រៀនមានចំនួន ២៩នាក់ ក្នុងនោះស្ត្រី ១៤នាក់ សិស្សដែលកំពុងរៀនមានចំនួន ៦១០នាក់ ស្រីចំនួន ៣២៥នាក់ និងវិទ្យាល័យមានចំនួន ០១កន្លែង ១៦បន្ទប់ ១៦ថ្នាក់ សិស្សដែលកំពុងរៀនចំនួន ៧៥៨នាក់ ស្រីចំនួន ៤៣៣នាក់ និង គ្រូបង្រៀនមានចំនួន ១៨នាក់ ក្នុងនោះស្រី ០៨នាក់ ។

តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧

| ស្ថានភាពសាលា | ចំនួនសាលារៀន | | | ចំនួនសិស្សកំពុងសិក្សា | | គ្រូបង្រៀន | |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | សរុប | ស្រី | សរុប | ស្រី |
| ១. សាលាមត្តេយ្យ | ៣ | ៣ | ៥ | ០ | ០ | ០ | ០ |
| ២. សាលាបឋមសិក្សា | ៦ | ៤២ | ៥០ | ១ ៨១៥ | ៩៣៥ | ៤១ | ២១ |
| ៣. អនុវិទ្យាល័យ | ១ | ១១ | ១១ | ៦១០ | ៣២៥ | ២៩ | ១៤ |
| ៤. វិទ្យាល័យ | ១ | ១៦ | ១៦ | ៧៥៨ | ៤៣៣ | ១៨ | ៦ |
| **សរុប** | **១១** | **៧២** | **៨២** | **៣ ១៨៣** | **១ ៦៩៣** | **៨៨** | **៤១** |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

### ខ .ស្ថានភាពអក្ខរកម្ម

ដោយយោងទៅតាមទិន្ន័យពីមន្ទីរផែនការឆ្នាំ២០១៧ នៅក្នុងឃុំទ្រា ប្រជាជនដែលមានអាយុពី ១៥ ទៅ ៤៥ឆ្នាំ មានចំនួន ៧ ០៦៦នាក់ នៅក្នុងចំណោមអ្នកទាំងនោះ អ្នកដែលមិនចេះអក្សរមានចំនួន ១៦,៥ភាគរយ ហើយបើគិតទៅតាមក្រុមអាយុវិញយើងឃើញថា នៅក្នុងឃុំនេះមានអ្នកមិនចេះអក្សរអាយុចាប់ពី ១៥ ទៅ២៤ឆ្នាំ ចំនួន ៣០០នាក់ ស្មើនឹង ១១,២ភាគរយ អាយុពី ២៥ ទៅ៤៥ឆ្នាំ ចំនួន ៨៦៤នាក់ ស្មើនឹង ១៩,៧១ភាគរយ។

ប្រជាជនភាគច្រើន មិនបានចូលរៀនដោយសារសាលារៀននៅឆ្ងាយពីភូមិឃុំ ប្រជាពលរដ្ឋនៅតែមានកង្វះមធ្យោបាយធ្វើដំណើរទៅសាលារៀន ខ្វះថវិកាសម្រាប់ទិញសម្ភារសិក្សា សម្លៀកបំពាក់ និងផ្នត់គំនិតរបស់ឪពុកម្តាយចាស់គំរិល ឬមិនជឿនលឿន ហើយនៅក្នុងឃុំនៅមានថ្នាក់អក្ខរកម្មជាប្រចាំ តែពួកគាត់ពុំទាន់មានពេលសិក្សាព្រោះជាប់រវល់ប្រកបរបរចិញ្ចឹមជីវិត ជាហេតុនាំមកនូវការភ្លេចអក្សរ នៅក្នុងចំណោមអ្នកដែលបានចូលមកសិក្សាក្នុងថ្នាក់អក្ខកម្មករន្លងមក ។

**-អនុវិស័យអប់រំក្រៅប្រព័ន្ធ**

ក្របខ័ណ្ឌស្ថាប័ន និងគោលនយោបាយត្រូវបានពង្រឹង តាមរយៈការពិនិត្យឡើងវិញគោលនយោបាយអប់រំក្រៅប្រព័ន្ធ ការបង្កើតអនុក្រុមការងារអប់រំក្រៅប្រព័ន្ធនិងមានភារកិច្ចច្បាស់លាស់ ការវាយតម្លៃសមត្ថភាពអប់រំក្រៅប្រព័ន្ធនិងការកសាងផែនទី ក៏ដូចជាការពិនិត្យឡើងវិញកម្មវិធីចូលរៀន ឡើងវិញនិងការរៀបចំសេចក្តីណែនាំស្តីពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធនិងកម្មវិធីសមមូល ។ ដើម្បីជម្រុញអោយផែនការយុទ្ធសាស្រ្តអនុវិស័យអប់រំក្រៅប្រព័ន្ធបានទទួលជោគជ័យ ត្រូវបន្តអនុវត្តសកម្មភាពដូចខាងក្រោម៖

១.បន្តពង្រឹងសកម្មភាពមជ្ឈមណ្ឌលសិក្សាសហគមន៍ បណ្ណាល័យ និងមណ្ឌលអានដែលមានស្រាប់

២.បន្តពង្រឹងការអនុវត្តកម្មវិធីសមមូលបឋមសិក្សា និងមធ្យមសិក្សា

៣.អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ

៤.បន្តអនុវត្តការងារអក្ខរកម្មតាមការជាក់ស្តែង

៥.បន្តអនុវត្តកម្មវិធីចូលរៀនឡើងវិញ

តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ

| បរិយាយ | ២០១៦ | ២០១៧ |
|---|---|---|
| ចំនួនអ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ | ២៦៥ | ៣០០ |
| %អ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ | ១០,៦ | ១១,២ |
| ចំនួនអ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ | ៨៦២ | ៨៦៤ |
| %អ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ | ២១,៩ | ១៩,៧ |
| សរុបមនុស្សអាយុ១៥-៤៥ឆ្នាំ | ៦៤៣១ | ៧០៦៦ |
| %អ្នកមិនចេះអក្សរអាយុ១៥-៤៥ឆ្នាំ | ១៧,៥ | ១៦,៥ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

## គ. ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

បើយោងទៅតាមប្រភពទិន្នន័យមន្ទីរផែនការខេត្តឆ្នាំ២០១៧បានបង្ហាញឱ្យឃើញថាលទ្ធភាពក្នុងការបន្តការសិក្សារបស់សិស្សនៅក្នុងឃុំប្រឡាយទៅថ្នាក់ខ្ពស់ទៀតមានដូចខាងក្រោម៖

- អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ១៤២ នាក់ ស្រីមានចំនួន ៦៤នាក់
- អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ១៥៥នាក់ ស្រីមានចំនួន៧០នាក់
- អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ៥២នាក់ ស្រីមានចំនួន ២៧ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ៥២ នាក់ ស្រីមានចំនួន៣២នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ២៤ នាក់ ស្រីមានចំនួន ១៤នាក់។

- អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន១៥នាក់ ស្រីចំនួន៧នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសរុបចំនួន៩នាក់ ស្រីចំនួន៦នាក់
- អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសរុបចំនួន៧នាក់ ស្រីចំនួន៥នាក់

តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

| ការអប់រំតាមក្រុមអាយុ | សរុប | ស្រី |
|---|---|---|
| អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យ | ១៤២ | ៦៤ |
| អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យ | ១៥៥ | ៧០ |
| អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យ | ៥២ | ២៧ |
| អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យ | ៥២ | ៣២ |
| អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យ | ២៤ | ១៤ |
| អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យ | ១៥ | ៧ |
| អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ៩ | ៦ |
| អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ៧ | ៥ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

### ១.១.៥.ស្ថានភាពសុខាភិបាល

មណ្ឌលសុខភាព គឺជាកន្លែងផ្តល់សេវាអប់រំសុខភាព ថែទាំនិងព្យាបាលអ្នកជម្ងឺផ្សេងៗ ដែលជាកន្លែងសាធារណៈរបស់រដ្ឋ ។ ឃុំទ្រាមានមណ្ឌលសុខភាពចំនួន ០១កន្លែង ដែលស្ថិតនៅភូមិកោះ ខាងជើងសាលាឃុំចម្ងាយ ៦៣ម៉ែត្រ ។ មណ្ឌលសុខភាពនេះមានគ្រូពេទ្យចំនួន ០៨នាក់ ក្នុងនោះស្រី ០៦នាក់ ឆ្មបចំនួន ០៣នាក់ បន្ទប់ចំនួន ០៦ គ្រែចំនួន ០៥ តែនៅក្នុងឃុំមិនទាន់មានគ្លីនិកឯកជននោះទេ។ ប្រភេទជម្ងឺដែលកាចសាហាវ ឬជម្ងឺឆ្លង ដែលកើតញឹកញាប់ គឺជម្ងឺរលាកផ្លូវដង្ហើម ។ ស្ថានភាពមាតា និងទារកនៅក្នុងឃុំទ្រា មានស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅចំនួន៣៥នាក់ ស្ត្រីសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង១ឆ្នាំកន្លងទៅ មានចំនួន ៣៤៧នាក់ ទារកដែលបានកើតរស់ដោយឆ្មបបុរាណចំនួន៤៩នាក់ ចំនួនទារកដែលបានកើតរស់ដោយឆ្មបពេទ្យមានចំនួន៣៤៧នាក់ ចំនួនមរណៈភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ ០-១ខែ ដោយឆ្មបបុរាណមិនមាននោះទេ មរណៈភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ ០-១ខែ ដោយឆ្មបពេទ្យមិនមានទេ ចំនួនមរណៈភាពទារកក្នុងចន្លោះអាយុ ០-១ខែ ដោយឆ្មបបុរាណមិនមែននោះទេ ចំនួនមរណៈភាពទារកក្នុងចន្លោះអាយុ០-១ខែដោយឆ្មបពេទ្យមានចំនួនមិនមែន ទារកដែលបានចុះសំបុត្រកំណើតមានចំនួន២១៧នាក់ ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែមានចំនួន ២០៤នាក់ ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន ២០៤នាក់ សម្រាប់ការចាក់ថ្នាំបង្ការជម្ងឺផ្សេងៗ នេះធ្វើនៅមណ្ឌលសុខភាព និងតាមភូមិជូនប្រជាពលរដ្ឋ មានជម្ងឺមួយចំនួនដូចជា៖ ជម្ងឺកញ្ជ្រិល ស្វិតដៃជើង ក្អកមាន់ របេង តេតាណូស រលាកថ្លើមប្រភេទបេ ផ្តាសាយបក្សី គ្រុនចាញ់ រាករូស និងគ្រុនឈាម ។ ករណី ជម្ងឺធ្ងន់ធ្ងរការបញ្ជូនអ្នកជម្ងឺដោយមធ្យោបាយខ្លួនឯងផ្ទាល់មកមណ្ឌលសុខភាព ព្រោះមណ្ឌលសុខភាពស្ថិតនៅជិតពួកគាត់ ឯការបញ្ជូនទៅមន្ទីរពេទ្យបង្អែក ដោយមធ្យោបាយផ្ទាល់ខ្លួន និងរថយន្តសង្គ្រោះរបស់ពេទ្យបង្អែក ទាំងការចំណាយវាយផ្សេងៗ ជាបន្ទុករបស់អ្នកជម្ងឺ ក្នុងករណីអ្នកជម្ងឺមិនមានប័ណ្ណក្រីក្រ ។

តារាង 13៖ សុខភាពមាតានិងទារក

| ល.រ | សុខភាពមាតានិងទារក | ឆ្នាំ២០១៧ |
|---|---|---|
| ១ | ចំនួនបុគ្គលិកពេទ្យនៅមណ្ឌលសុខភាព | ៨ |
| ២ | ចំនួនពេទ្យឆ្មបនៅមណ្ឌលសុខភាព | ៣ |
| ៣ | ចំនួនឆ្មបបុរាណនៅមណ្ឌលសុខភាព | ០ |
| ៤ | ចំនួនបន្ទប់នៅមណ្ឌលសុខភាព | ៦ |
| ៥ | ចំនួនគ្រែនៅមណ្ឌលសុខភាព | ៥ |
| ៦ | ចំនួនឆ្មបដែលបានបណ្ដុះបណ្ដាលមានក្នុងភូមិ | ៧ |
| ៧ | ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅ | ៣៥ |
| ៨ | ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបមានការបណ្ដុះបណ្ដាលក្នុង ១ឆ្នាំកន្លងទៅ | ៣៤៧ |
| ៩ | ចំនួនទារកដែលបានកើតរស់ដោយឆ្មបបុរាណ | ៤៩ |
| ១០ | ចំនួនទារកដែលបានកើតរស់ដោយឆ្មបពេទ្យ | ៣៤៧ |
| ១១ | ចំនួនមរណៈភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ ០-១ខែដោយឆ្មបបុរាណ | ០ |
| ១២ | ចំនួនមរណៈភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ ០-១ខែដោយឆ្មបពេទ្យ | ០ |
| ១៣ | ចំនួនមរណៈភាពទារកក្នុងចន្លោះអាយុ ០-១ខែដោយឆ្មបបុរាណ | ០ |
| ១៤ | ចំនួនមរណៈភាពទារកក្នុងចន្លោះអាយុ ០-១ខែដោយឆ្មបពេទ្យ | ០ |
| ១៥ | ចំនួនទារកដែលបានចុះសំបុត្រកំណើត | ២១៧ |
| ១៦ | ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែ | ២០៤ |
| ១៧ | ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន | ២០៤ |

*ប្រភពទិន្នន័យ៖ CDB ២០១៧ និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

រូបភាព 2៖ មណ្ឌលសុខភាព ឃុំទ្រា



យោងតាមពីទិន្នន័យមន្ទីរផែនការខេត្ត ឆ្នាំ ២០១៧ បានឱ្យដឹងថា ចម្ងាយពីភូមិនីមួយៗទៅកាន់មណ្ឌលសុខភាពភាគច្រើន មិនឆ្ងាយណាស់ណានោះទេ គឺឆ្ងាយបំផុតត្រឹមពី ១៤គីឡូម៉ែត្រប៉ុណ្ណោះ ដូចមានក្នុងតារាងសង្ខេបខាងក្រោម ។ ចំណែកស្ថានភាពផ្លូវទៅកាន់មណ្ឌលសុខភាពក៏មិនពិបាកនៅក្នុងការធ្វើដំណើរដែរ ដែលអំណោយផលដល់ការបញ្ជូនអ្នកជម្ងឺទៅកាន់មណ្ឌលសុខភាពបានទាន់ពេលវេលា ។

តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព

| ល.រ | ឈ្មោះភូមិ | ចម្ងាយជាមធ្យម ពីភូមិទៅមណ្ឌលសុខភាព | ផ្សេងៗ |
|---|---|---|---|
| ១ | ទទា | ០,៤ គីឡូម៉ែត |  |
| ២ | កោះ | ០,៧ គីឡូម៉ែត |  |
| ៣ | ហប់ | ០,៨ គីឡូម៉ែត |  |
| ៤ | វាល | ១គីឡូម៉ែត |  |
| ៥ | សាមក្អោក | ១,៥ គីឡូម៉ែត |  |
| ៦ | ច្រាំងស | ១,៥ គីឡូម៉ែត |  |
| ៧ | ទ្រា | ២ គីឡូម៉ែត |  |
| ៨ | បុស្សតាឯក | ៤,៣ គីឡូម៉ែត |  |
| ៩ | តាចរ | ៣,៥ គីឡូម៉ែត |  |
| ១០ | លាបទង | ២ គីឡូម៉ែត |  |
| ១១ | ផ្ទះវាល | ៣ គីឡូម៉ែត |  |
| ១២ | ស្លា | ៥គីឡូម៉ែត |  |
| ១៣ | ក្រសាំង | ៤ គីឡូម៉ែត |  |
| ១៤ | កុចទីទុយ | ៧គីឡូម៉ែត |  |
| ១៥ | ពពាយ | ៨ គីឡូម៉ែត |  |
| ១៦ | ទំពេជ | ១៤ គីឡូម៉ែត |  |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

ដ្យាក្រាម 2៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព




*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

### ១.១.៦.ស្ថានភាពយេនឌ័រ

តាមផែនការអភិវឌ្ឍន៍ឃុំទ្រារយៈពេល៥ឆ្នាំ(២០១៨-២០២២) បានឱ្យដឹងថា សមភាពការងាររបស់ស្ត្រី និងបុរសក្នុងឃុំទ្រា នាពេលបច្ចុប្បន្នគ្មានការរើសអើង ឬគាបសង្កត់ទៅលើស្ត្រីនោះទេ ។ ផ្ទុយទៅវិញការងារយេនឌ័រកំពុងមានការគាំទ្រយ៉ាងពេញទំហឹង ជាក់ស្តែងក្នុងការងារមានថ្នាក់ដឹកនាំជាស្ត្រីនៅថ្នាក់ភូមិ និងនៅថ្នាក់ឃុំកំពុងត្រូវបានលើកកម្ពស់ និងលើកទឹកចិត្តស្ត្រីឱ្យមានការចូលរួមយ៉ាងសកម្មក្នុងការកសាងផែនការអភិវឌ្ឍន៍ឃុំក៏ដូចជាផែនការវិនិយោគផងដែរ ។ ទោះជាយ៉ាងនេះក្តី បញ្ហាប្រឈមនៅតែកើតមានឡើងទៅលើសមត្ថភាពស្ត្រីដោយមានមួយចំនួននៅតែមានកម្រិតជីវភាពក្រីក្រ ខ្លះបោះបង់ការសិក្សា ដើម្បីរកចំណូលមកទ្រទ្រង់ជីវភាពក្នុងគ្រួសារ អ្នកខ្លះចំណាកស្រុកទៅភ្នំពេញដើម្បីធ្វើកម្មកររោងចក្រ។ ដើម្បីដោះស្រាយបញ្ហានេះក្រុមប្រឹក្សាឃុំបានសហការជាមួយមន្ទីរការិយាល័យជំនាញជំនាញ និងដៃគូរអភិវឌ្ឍន៍នានាជុំវិញ និងលើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាលបច្ចេកទេសនានា និងជំនាញវិជ្ជាជីវៈបង្កើនមុខរបរថ្មីៗ ដើម្បីបង្កើនប្រាក់ចំណូល និងកាត់បន្ថយការចំណាកស្រុក។ ប៉ុន្តែបើតាមរយៈរបាយការណ៍នៃការវិភាគប្រព័ន្ធក្សេត្របរិស្ថានឃុំទ្រា ឆ្នាំ២០១៧ បានឱ្យដឹងអំពីតួនាទីយេនឌ័រនៅក្នុងការចូលរួមសកម្មភាពការងារផលិតកម្មកសិកម្ម និងការងារទូទៅក្នុងជីវភាពគ្រួសាររបស់កសិករក្នុងឃុំទ្រា មានលម្អិតក្នុងតារាងខាងក្រោម ។

តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ ឃុំទ្រា

| សកម្មភាព | បុរស | ស្ត្រី | យោបល់បន្ថែម |
|---|---|---|---|
| **ស្រូវវស្សា** | | | |
| ការរៀបចំដីលើកទី១ | ១០០% | | គឺការភ្ជួរដោយត្រាក់ទ័រធ្វើតែបុរស |
| ការរៀបចំដីលើកទី២ | ១០០% | | គឺការភ្ជួរដោយត្រាក់ទ័រធ្វើតែបុរស |
| ការត្រាំពូជ | ៥០% | ៥០% | |
| ព្រួស | ៨០% | ២០% | |
| ការដាក់ជីបំប៉ន | ៨០% | ២០% | ធ្វើការងារស្រាល |
| គ្រប់គ្រងទឹកស្រែ | ៨០% | ២០% | ធ្វើការងារស្រាល |
| ការបាញ់ថ្នាំសម្លាប់ស្មៅ | ១០០% | | |
| ការច្រូតកាត់ | ៥០% | ៥០% | |
| ការដឹកជញ្ជូន | ៧០% | ៣០% | លើកដាក់ធុន់ៗច្រើន |
| ហាលសំងួតសំងួត | ៥០% | ៥០% | |
| ទុកដាក់ស្រូវ | ៥០% | ៥០% | |
| លក់ស្រូវ | ៥០% | ៥០% | |
| **សកម្មភាពមុខរបរចិញ្ចឹមជីវិតសំខាន់ផ្សេងទៀត** | | | |
| សួនបន្លែ | ៥០% | ៥០% | |
| ចិញ្ចឹមជ្រូក | ៥០% | ៥០% | |
| ចិញ្ចឹមគោ ក្របី | ៥០% | ៥០% | |
| ចិញ្ចឹមមាន់ ទា | ៥០% | ៥០% | |

| | | | |
|---|---|---|---|
| ការប្រមូលអនុផលព្រៃឈើ | ៧៥% | ២៥% | ចាកចេញឆ្ងាយពីភូមិពេលខ្លះទៅតាមប្តី |
| រកត្រី | ៨៥% | ១៥% | ទៅរកទីតាំងឆ្ងាយៗ |
| ជំនួញទូទៅ | ៥០% | ៥០% | |
| ការថែទាំប្រព័ន្ធធារាសាស្ត្រ | ៥០% | ៥០% | |
| ដំណាំបន្លែ | | | |
| ការរៀបចំដី | ១០០% | | |
| ភ្ជួរ | ១០០% | | |
| រាស់ | ១០០% | | |
| ឆ្មូតរង | ៨០% | ២០% | ជួយរើសស្មៅ |
| ដាក់ជី | ៣៥% | ៦៥% | |
| ផ្ដុំរង | ១០០% | | |
| ដាំគ្រាប់ | ៥០% | ៥០% | |
| ដាក់ជីបំប៉ន | ៤០% | ៦០% | |
| ពូនរង | ១០០% | | |
| បូមទឹក | ៧០% | ៣០% | |
| ថែទាំ | ៥០% | ៥០% | |
| លក់ដោយម៉ៅ | ១៥% | ៨៥% | |

ប្រភពទិន្នន័យ៖ *របាយការណ៍ក្សេត្របរិស្ថាន*

បើយោងទៅតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំទ្រា ក្នុងឆ្នាំ២០១៧ បានរកឃើញពីការវិភាគតួនាទីយេនឌ័រក្នុងឃុំម្យាក្រងដូចខាងក្រោម៖

១.រាល់ដំណោះស្រាយផ្សេងៗ បុរស់មានសិទ្ធិច្រើនជាងស្ត្រីក្នុងការសម្រេចចិត្ត

២.ការងារក្នុងផ្ទះភាគច្រើនស្ត្រីជាអ្នកធ្វើ

៣.បុរស់ភាគច្រើនមិនទាន់សូវបានជួយការងារផ្ទះជនួសស្ត្រី

៤.បុរស់នៅមិនទាន់ផ្តល់ឱកាស និងឱ្យតម្លៃស្ត្រីស្មើភាពនៅឡើយ

៥.ស្ត្រីមួយចំនួននៅទទួលរងអំពើហឹង្សាក្នុងគ្រួសារនៅឡើយ

យេនឌ័រ គឺជាប្រធានបទដ៏ស្មុគស្មាញមួយដែលគួរតែត្រូវបានដាក់បញ្ចូលទៅគ្រប់មាតិកានិងដំណើរការទាំងអស់នៃកម្មវិធីបំណិនជីវិតក្នុងតំបន់។ ក្នុងពេលជាមួយគ្នានេះ ការលើកទឹកចិត្តសិស្សឱ្យផ្តោតការយកចិត្ត ទុកដាក់ទៅលើក្តីបារម្ភ អំពីយេនឌ័រជាក់លាក់មួយ នៅក្នុងកម្រិតមូលដ្ឋានគួរតែជាផ្នែកមួយដ៏សំខាន់នៅក្នុងបទពិសោធន៍នៃការសិក្សា។ តាមប្រភពពត៌មានដែលទទួលបាន ដូចមានរៀបរាប់ខាងលើពាក់ព័ន្ធការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីនៅក្នុងឃុំទ្រា យើងសង្កេតឃើញថា បុរស និងស្ត្រីមិនមានការរើសអើង ជាពិសេសការងាររៀបចំដីស្រែគ្នាធ្ងន់ធ្ងរនោះទេ គឺមានភាពលំអៀងតិចតួចប៉ុណ្ណោះ ដូចជាការងារធ្វើស្រែឃើញបុរសមានការចូលរួមច្រើនជាងស្ត្រី ការងារនេះបុរសទទួលរ៉ាប់រងទាំងស្រុងដែលស្ត្រីមានកម្លាំងទន់ខ្សោយជាង ជាអ្នកចម្អិនអាហារនៅផ្ទះ ហើយក៏ឃើញការងារដឹកជញ្ជូនគ្រាប់ស្រូវ បាញ់ថ្នាំសម្លាប់សត្វល្អិតនិងដាក់ជី ច្រូតកាត់ និងការងារទុកដាក់ស្រូវជាដើមគឺ បុរសបានចូលរួមច្រើនជាងស្ត្រី ប៉ុន្តែការងារក្នុងផ្ទះនិងនៅជិតផ្ទះឃើញស្ត្រីបានចូលរួមច្រើន

ជាងបុរសវិញ តែក្នុងនោះក៏បានរកឃើញថា ការសម្រេចចិត្តក្នុងគ្រួសារបុរសនៅមានសិទ្ធិច្រើនជាងស្ត្រី និងមានស្ត្រីមួយចំនួននៅទទួលរងអំពើហឹង្សាក្នុងគ្រួសារនៅឡើយ។ ប៉ុន្តែទោះបីមានបញ្ហាប្រឈមខ្លះក្នុងការលើកកម្ពស់សមភាពយេនឌ័រនិងសិទ្ធិអំណាចស្ត្រីក៏ដោយ ក៏យើងឃើញកិច្ចការនេះមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលទៅថ្ងៃអនាគតនឹងឈានទៅកាន់តែប្រសើរឡើង ។

## ១.២. ស្ថានភាពភូមិសាស្ត្រ

### ១.២.១.ទីតាំងភូមិសាស្ត្រ

ឃុំទ្រា ជាឃុំមួយនៅក្នុងស្រុកស្ទោង ខេត្តកំពង់ធំ ដែលស្ថិតនៅទិសពាយព្យទីរួមខេត្ត និងមានចម្ងាយផ្លូវប្រហែល៥១គីឡូម៉ែត្រ មានទីតាំងផ្ដែកលើនិយាមកាផែនទី (អាប់ស៊ីស) ៤៥៤ ១១៣,៥៩ និង (អ័រដោនេ) ១ ៤៣០ ៦៣២,៤៦ ។ បើយោងតាមសណ្ឋានដីនៅក្នុងឃុំទ្រា នៃរបាយការណ៍ក្សេត្រ-បរិស្ថានបានឱ្យដឹងថាជាដីមិនរាបស្មើមានទាបមានខ្ពស់ទៅតាមស្ថានដីដោយបានបែងចែកជាបីតំបន់ខុសៗគ្នាដូចក្រោមនេះ៖

**តំបន់ទី១៖ តំបន់វាលទំនាបដំណាំចម្រុះ និងលំនៅឋាន** ដីមានរាងជម្រាលមកខាងត្បូងឈាងខាងលិចស្រោចស្រពទឹកភ្លៀង និងទឹកស្ទឹងស្ទោង ពុំមានភ្លឺស្រែគ្រប់គ្រាន់ ជាតំបន់លំនៅឋានដំណាំចម្រុះ ដំណាំស្រូវ ដំណាំឈើហូបផ្លែ និងហេដ្ឋារចនាសម្ព័ន្ធ ។ តំបន់នេះមានផលិតភាពខ្លាំងដោយអាស្រ័យទៅលើជីជាតិដី និងទឹកស្រោចស្រពដោយប្រើប្រាស់ទឹកស្ទឹងស្ទោង ។ ទោះជាយ៉ាងណាការប្រើប្រាស់ត្រឹមតែពូជមានគុណភាពទាប គឺពូជស្រូវពូជផ្ការំដួល IR ៥០៤ និង ៨៥ ដែលបានរក្សាទុកតៗគ្នា ដែលបច្ចុប្បន្នជាពូជស្រូវផលិតជាលក្ខណៈពាណិជ្ជកម្ម ហើយពុំទាន់មានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់នៅឡើយ ការដាំដុះដំណាំស្រូវបានតែមួយដងក្នុងមួយឆ្នាំ តែប្រសិនមានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ ជាតំបន់ដែលអាចជាលក្ខណៈពាណិជ្ជកម្មបាន ។

**តំបន់ទី២៖ តំបន់វាលទំនាបមធ្យមដំណាំចម្រុះ និងលំនៅឋាន** ដីមានរាងជម្រាលរាបស្មើ មានលំនៅឋានស្រោចស្រពដោយទឹកភ្លៀង និងទឹកប្រឡាយ យកមកពីប្រឡាយ៣០កញ្ញា នៅរដូវវស្សាពុំមានភ្លឺស្រែគ្រប់គ្រាន់ ផ្ទៃដីភាគច្រើនដាំដំណាំស្រូវពូជផ្ការំដួល ។ តំបន់នេះមានផលិតភាពយ៉ាងខ្លាំងដោយអាស្រ័យទៅលើជីជាតិដីមធ្យម និងពុំទាន់មានប្រឡាយទឹកស្រោចស្រព បឹង និងត្រពាំងមួយចំនួនមានទំហំតូចហើយរាក់ ។ ហើយបច្ចុប្បន្នមានប្រើប្រាស់ត្រឹមតែពូជមានគុណភាពទាបគឺពូជស្រូវ IR ៥០៤ និង៨៥ ដែលគឺជាពូជស្រូវផលិតជាលក្ខណៈគ្រួសារ តែប្រសិនមានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ជាតំបន់ដែលអាចជាលក្ខណៈពាណិជ្ជកម្មបាន ។

**តំបន់ទី៣៖ តំបន់វាលទំនាបខ្ពស់ដំណាំចម្ការនិងព្រៃរបោះ** ដីមានរាងជម្រាលរាបស្មើ ជាដីចម្ការ និងព្រៃល្បោះ ស្រោចស្រពដោយទឹកភ្លៀង មានដីស្រែតិចតួចវាលស្រែ ។ ដីមានជីជាតិកម្រិតមធ្យម និងមានបញ្ហាកត្តាចង្រៃលើដំណាំស្រូវចម្ការ ជាពិសេសពូជស្រូវផ្ការំដួល និងមានការយាយីពីសត្វកណ្ដុរសត្វល្អិតជម្ងឺបំផ្លាញនិងពុំមានប្រព័ន្ធស្រោចស្រព ប៉ុន្តែបើសិនបញ្ហាទាំងនេះត្រូវបានដោះស្រាយ គឺតំបន់នេះមានសក្ដានុពល សម្រាប់ផលិតកម្មដំណាំចម្ការស្វាយចន្ទីរ ចម្ការស្វាយកែវល្មៀត និងដំណាំឈើហូបផ្លែផ្សេងៗទៀត ហើយភាគច្រើនជាព្រៃល្បោះ និងព្រៃសហគមន៍ចំនួន ២៣៩(ហ.ត) មិនអាចយកមកធ្វើទីកន្លែង សម្រាប់ផលិតកម្មជាលក្ខណៈពាណិជ្ជកម្មបានទេ ។

ផែនទី 3៖ ផែនទីសណ្ឋានដីឃុំទ្រា



ផែនទី 4៖ តំបន់កេ្សត្រ-បរិស្ថាន ឃុំទ្រា



តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹង ឃុំទ្រា ស្រុកស្ទោង

| រូបថត |  |  |  |
|---|---|---|---|
| **ឈ្មោះតំបន់** | **តំបន់ទី I**<br>**តំបន់ដីវាលទំនាបដំណាំចម្រុះ និងលំនៅឋាន** | **តំបន់ទី II**<br>**តំបន់ដីវាលទំនាបមធ្យមដំណាំចម្រុះ និងលំនៅឋាន** | **តំបន់ទី I I I**<br>**តំបន់ដីវាលទំនាបខ្ពស់ដំណាំចម្ការ និងព្រៃល្បោះ** |
| **រៀបរាប់ដោយសង្ខេប** | -ដីមានរាងជម្រាលទាបមកខាងត្បូងឈាងខាងលិច<br>-ស្រោចស្រពទឹកភ្លៀង និងទឹកស្ទឹងស្ទោង<br>-ពុំមានភ្លឺស្រែគ្រប់គ្រាន់<br>-មានលំនៅឋាន<br>-ផ្ទៃដីភាគច្រើនដាំដំណាំស្រូវពូជផ្ការំដួល | -ជម្រាលរាបស្មើ<br>-មានលំនៅឋាន<br>-ស្រោចស្រពដោយទឹកភ្លៀងនិងទឹកប្រឡាយ យកមកពី៣០កញ្ញានៅរដូវវស្សា<br>-ពុំមានភ្លឺស្រែគ្រប់គ្រាន់<br>-ផ្ទៃដីភាគច្រើនដាំដំណាំស្រូវពូជផ្ការំដួល | -ជម្រាលរាបស្មើ<br>-ជាដីចម្ការ និងព្រៃរបោះ<br>-ស្រោចស្រពដោយទឹកភ្លៀង<br>-មានដីស្រែតិចតួចវាលស្រែ |
| **ឋានលេខា** | ជម្រាលទាប | ជម្រាលមធ្យម | ជម្រាលខ្ពស់ |
| **ប្រភេទដី** | កណ្តេងលាយល្បាប់<br>(ពណ៌លឿង) | ខ្សាច់លាយកណ្តែង | ខ្សាច់ច្រើនជាងល្បាយ<br>(សរលាយក្រហម) |
| **ជលសាស្ត្រ** | ស្ទឹងស្ទោង.ប្រឡាយ.អណ្តូង.ភ្លៀង .ស្រះ | ប្រឡាយ.ត្រពាំង.អណ្តូង.ភ្លៀង.ស្រះ | អូរផ្អុង.អូរគោលង់អូរភ្នាស.អូរកំបុត.ប្រឡាយ.ភ្លៀង.ស្រះ.អណ្តូង |
| **ធនធានទឹក** | ស្ទឹងស្ទោង.ប្រឡាយ.អណ្តូង.ភ្លៀង.ស្រះ | ប្រឡាយ.ត្រពាំង.អណ្តូង.ភ្លៀង.ស្រះ | អូរភ្នាស.អូរកំបុត អូរផ្អុង.អូរគោលង់.ភ្លៀង |
| **គម្របដីនិងការប្រើប្រាស់ដី** | លំនៅឋាន.ដំណាំចម្រុះ.ដំណាំស្រូវ.ដំណាំឈើហូបផ្លែ. | លំនៅឋាន.ដំណាំចម្រុះ.ដំណាំស្រូវ.ឈើហូបផ្លែ | ភាគច្រើនព្រៃរបោះ.ព្រៃសហគមន៍២៣៩(ហ.ត).ចម្ការស្វាយ.ស្វាយចន្ទី.ស្រូវចម្ការ.ស្រូវកណ្តាល |
| **ដំណាំសំខាន់ៗ** | ដំណាំស្រូវ១ដង.បន្លែ.ពោត<br>(វស្សា) | ដំណាំស្រូវ១ដង(វស្សា) | ដំណាំស្រូវ១ដង.ឈើហូបផ្លែ<br>(ស្វាយ.ស្វាយចន្ទី) |
| **ពូជស្រូវ** | រំដួល.ម្លិះថៃ.ម៉ាលិ(ធ្ងន់).ផ្កាម្លិះ.នាងគង់.ដំណើបក្រចកចាប.នាងនុ | ផ្ការំដួល.ម្លិះថៃ.ម៉ាលិ(ធ្ងន់).ផ្កាម្លិះ.នាងគង់ | ផ្ការំដួល).ផ្កាម្លិះ.ម៉ាលិ(ធ្ងន់ដាក់តាមត្រពាំង |

| | | | |
|---|---|---|---|
| **ការប្រើប្រាស់ដី** | ដីលាមកសត្វ.ដីគីមី(អ៊ុយរ៉េ.ដេ.អា.ប៉េ.១៥.១៥.១៥.២០.២០.១៥) | ដីលាមកសត្វ.ដីគីមី(អ៊ុយរ៉េ.ដេ.អា.ប៉េ.១៥.១៥.១៥.២០.២០.១៥) | ដីលាមកសត្វ.ដីគីមី(អ៊ុយរ៉េ.ដេ.អា.ប៉េ.១៥.១៥.១៥.២០.២០.១៥) |
| **ការចិញ្ចឹមសត្វ** | គោ.ក្របី.ជ្រូក.មាន់.ទា | គោ.ក្របី.ភាគច្រើនជ្រូក.មាន់.ទា | ទន្សាយ .ឈ្លូស.ជ្រូកព្រៃ.ពស់.ក្ងោក.មាន់ព្រៃ |
| **ដីរបស់រដ្ឋនិងសហគមន៍** | សាលាឃុំ.សាលារៀន.ដីចំណីស្ទឹង.មណ្ឌលសុខភាព.ផ្លូវ.វត្ត.ប្រឡាយ | សាលារៀន.វត្ត.ប្រឡាយ | ដីព្រៃសហគមន៍៣កន្លែងសរុប ២៣៩(ហ.ត) |
| **បញ្ហាផ្សេងៗ** | . ទឹកជំនន់(ភ្លៀងខ្លាំង)<br>.លិចដោយសារការបើកទ្វារទឹកអាង៣០កញ្ញាខ្វះទឹកនៅពេលបិទទ្វារទឹកអាង៣០កញ្ញា<br>.សត្វល្អិតបំផ្លាញដំណាំបន្លែនិងស្រូវ(ដង្កូវ.កណ្តូប.ខ្យងក្រហម)<br>. ផ្លូវខូចលំបាកធ្វើដំណើរ<br>.ខ្វះប្រព័ន្ធស្រោចស្រពនៅរដូវប្រាំង<br>.ខ្វះពូជស្រូវទំនើបធន់នឹងអាកាសធាតុ<br>. គ្រោះធម្មជាតិខ្យល់ព្យុះរលំផ្ទះ<br>.គោក្របីកើតជម្ងឺអុតក្តាម.សារទឹក)<br>. ខ្វះពូជសត្វល្អ. ខ្វះបង្គន់អនាម័យ<br>. ខ្វះទឹកស្អាតប្រើប្រាស់<br>. ខ្វះបច្ចេកទេសចិញ្ចឹមសត្វ<br>. ខ្វះបច្ចេកទេសដាំដុះដំណាំស្រូវ<br>. ខ្វះបច្ចេកទេសដាំដំណាំបន្លែ<br>.ខ្វះបច្ចេកទេសដាំដំណាំឈើហូបផ្លែ | . ទឹកជំនន់(ភ្លៀងខ្លាំង)<br>.លិចដោយសារការបើកទ្វារទឹក<br>. ខ្វះទឹកនៅពេលបិទទ្វារទឹក<br>.សត្វល្អិតបំផ្លាញដំណាំបន្លែនិងស្រូវ(ដង្កូវ.កណ្តូប.ខ្យងក្រហម)<br>. ផ្លូវខូចលំបាកធ្វើដំណើរ<br>.ខ្វះប្រព័ន្ធស្រោចស្រពនៅរដូវប្រាំង<br>.ខ្វះពូជស្រូវទំនើបធន់នឹងអាកាសធាតុ<br>. គ្រោះធម្មជាតិខ្យល់ព្យុះរលំផ្ទះ<br>.គោក្របីកើតជម្ងឺ(អុតក្តាម.សារទឹក)<br>.ខ្វះពូជសត្វល្អ.ខ្វះបង្គន់អនាម័យ<br>. ខ្វះទឹកស្អាតប្រើប្រាស់<br>. ខ្វះបច្ចេកទេសចិញ្ចឹមសត្វ<br>. ខ្វះបច្ចេកទេសដាំដុះដំណាំស្រូវ<br>. ខ្វះបច្ចេកទេសដាំដំណាំបន្លែ<br>.ខ្វះបច្ចេកទេសដាំដំណាំឈើហូបផ្លែ | .ការកាប់បំផ្លាញព្រៃយកឈើដុតធ្យូង<br>. ខ្វះប្រភពទឹកនៅរដូវប្រាំង<br>. មានការបំផ្លាញសត្វព្រៃ<br>.សត្វល្អិតបំផ្លាញដំណាំស្វាយចន្ទី |
| **កាលានុវត្តភាព/ឱកាស** | .បើមានប្រភពទឹកអាចធ្វើស្រែបាន២ដង<br>. អាចធ្វើស្រែបង្កើនរដូវ<br>. អាចពង្រីកការដាំដុះដំណាំបន្លែ<br>. អាចពង្រីកការចិញ្ចឹមសត្វ(គោ.ក្របីជ្រូក.មាន់.ទា..)<br>. បង្កើនការបណ្តុះបណ្តាលបច្ចេកទេស ផលិតកម្ម កសិកម្ម<br>. អាចបង្កើតស្ថានីយ៍បូមទឹក | . បើមានប្រភពទឹកអាចធ្វើស្រែបាន២ដង | . ពង្រីកការដាំដុះឈើហូបផ្លែ<br>. អាចដាំដំណាំរយៈពេលខ្លី(ឪឡឹក.ពោត សណ្តែក. ល្ង |

ប្រភពទិន្នន័យ៖ *របាយការណ៍ក្សេត្រ-បរិស្ថានឃុំទ្រា*

បើយោងទៅតាមរបាយការណ៍ក្សេត្រ-បរិស្ថាន និងក្រុមប្រឹក្សាឃុំទ្រា បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំមានប្រភពទឹកសំខាន់ៗដូចជា៖ ទឹកភ្លៀង ទឹកស្ទឹងស្មោង ទឹកប្រឡាយ ទឹកអណ្តូង ទឹកស្រះ ត្រពាំង អូរ និងមាន

ប្រឡាយសរុប ១៣ខ្សែ ប្រវែង ៣២ ១២២,៣៨ម៉ែត្រ ដែលនៅក្នុងនោះប្រឡាយមេមានចំនួន ០២ខ្សែ ប្រវែង ១៣ ៣២៩,១០ម៉ែត្រ ប្រឡាយរងមានចំនួន១ខ្សែ ប្រវែង ៦ ០២០,៤៧ម៉ែត្រ និងប្រឡាយតូចមានចំនួន១០ខ្សែ ប្រវែង ១២ ៧៧២,៨១ម៉ែត្រ ដែលធ្វើការបរិយាយលម្អិតនៅក្នុងតារាងខាងក្រោម ។

តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ

| ល.រ | ប្រព័ន្ធ ធារាសាស្ត្រ | ប្រវែង(ម) ឆ្នាំ២០១៧ | ការពិពណ៌នា |
|---|---|---|---|
| ១ | ប្រឡាយមេ | ៦ ២៦៣,៣៨ | ប្រឡាយ ៣០កញ្ញាកសាងដោយក្រុមហ៊ុនចិន |
| ២ | ប្រឡាយមេ | ៧ ០៦៥,៧២ | ពីភូមិតាទៀល ឃុំប្រឡាយ ឆ្ពោះទៅកើត ក្បែរភូមិទំពេជ ឃុំទ្រា (ប្រឡាយចាស់) |
| ៣ | ប្រឡាយរង | ៦ ០២០,៤៧ | បែកចេញពី ប្រឡាយមេ ៣០កញ្ញា ខ្សែទី១ ធ្លាក់ផ្លូវទៅភូមិបុសតាឯក ភូមិតាចរ ភូមិទ្រាជិតស្ទឹងស្ទោង |
| ៤ | ប្រឡាយតូច | ៨៨១,៧៤ | ប្រឡាយតូចនៅអមផ្លូវជាតិ វ៉ាត់ស្រុកស្ទោងឃុំទ្រា |
| ៥ | ប្រឡាយតូច | ២ ៨១៨,២២ | ទំនប់ចាស់ ឬប្រឡាយ ទប់ជារបងយុទ្ធសាស្ត្រឃុំទ្រា |
| ៦ | ប្រឡាយតូច | ១៤,០៩ | ប្រឡាយជីកតូច អមផ្លូវ ពីឃុំកំពុងចិនជើង ទៅភូមិបុសតាឯក |
| ៧ | ប្រឡាយតូច | ៩៧,៦៩ | ប្រឡាយជីកតូច អមផ្លូវ ពីឃុំកំពុងចិនជើង ទៅភូមិបុសតាឯក |
| ៨ | ប្រឡាយតូច | ១៥៥,២៥ | ប្រឡាយជីកតូច អមផ្លូវ ពីឃុំកំពុងចិនជើង ទៅភូមិបុសតាឯក |
| ៩ | ប្រឡាយតូច | ១ ៣៩២,២៨ | ប្រឡាយជីកតូច អមផ្លូវ ពីឃុំកំពុងចិនជើង ទៅភូមិបុសតាឯក |
| ១០ | ប្រឡាយតូច | ២៧,៤៨ | ប្រឡាយជីកតូច អមផ្លូវ ពីឃុំកំពុងចិនជើង ទៅភូមិបុសតាឯក |
| ១១ | ប្រឡាយតូច | ៨៧៦,០២ | ប្រឡាយជីកតូច អមផ្លូវ ពីឃុំកំពុងចិនជើង ទៅភូមិបុសតាឯក |
| ១២ | ប្រឡាយតូច | ៥៩២,០២ | ប្រឡាយជីកលើកធ្វើផ្លូវដីស ជំនួយដោយ អង្គការ World Vision |
| ១៣ | ប្រឡាយតូច | ៥ ៩១៨,០៣ | កាត់ចេញពីព្រំប្រទល់ឃុំបន្ទាយស្ទោង កើតចេញពីស្នាមប្រឡាយចាស់ មកដល់ក្រោយភូមិក្រសាំង |

ប្រភពទិន្នន័យ៖ *ក្រុមការងារបច្ចេកទេស GIS អេស ប៊ី ខេ និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

រូបភាព 3៖ ប្រឡាយទឹកនៅក្នុងឃុំទ្រា





ផែនទី 5៖ ផែនទីប្រព័ន្ធធារាសាស្ត្រនៅក្នុងឃុំទ្រា




## ១.២.២.អាកាសធាតុ (ពិពណ៌នាតាមរដូវកាល)

នៅក្នុងឃុំទ្រា ក៏ដូចជានៅទូទាំងខេត្ត គឺទទួលរបបខ្យល់មកពីតំបន់ត្រូពិច ដែលមានអាកាសធាតុក្ដៅហើយសើម ។ របបខ្យល់មូសុង គឺបានពាំនាំមកនូវចំនួនទឹកភ្លៀងយ៉ាងច្រើនមកជាមួយ ដែលអំណោយផលទៅដល់ការធ្វើកសិកម្មនានា និងដាំដំណាំផ្សេងៗទៀត ។

បើយោងទៅតាមប្រភពទិន្នន័យពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ធំ ប្រចាំស្រុកស្ទោងក្នុងឆ្នាំ ២០១៧ បានបង្ហាញឱ្យឃើញថា នៅក្នុងស្រុកស្ទោងទាំងមូលមានភ្លៀងធ្លាក់ចំនួន៨៩ដង និងមានបរិមាណទឹកភ្លៀងប្រចាំឆ្នាំចំនួន១៤២០ម.ម ។

**អំពីអាកាសធាតុ៖**

- រដូវរងារ៖ ខែ វិច្ឆិកា ដល់ ខែ មីនា (២០ ទៅ ២៨ អង្សា)
- រដូវក្តៅ៖ ខែ មីនា ដល់ ខែ ឧសភា (៣០ ទៅ ៣៥ អង្សា)
- រដូវភ្លៀង៖ ខែ ឧសភា ដល់ ខែ តុលា (២៣ ទៅ ៣០ អង្សា ជាមួយនឹងការឡើងសំណើមទៅដល់ ៩០ %)នៅរដូវនេះជារៀងរាល់ឆ្នាំ គឺមានភ្លៀងធ្លាក់ខ្លាំង នៅពេលរសៀល និងល្ងាច។

តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ

| ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បរិមាណទឹកភ្លៀង | ០ | ០ | ១៨.៧ | ១១.៦ | ២៩៥ | ១៥៣.៣ | ៩៩ | ២៣៤ | ៧៩.៥ | ២១៨. | ៩៩.៩ | ១៧ |
| ថ្ងៃភ្លៀងធ្លាក់ | ០ | ០ | ២ | ៦ | ១៣ | ៨ | ៩ | ៩ | ៣ | ៩ | ១២ | ២ |

ប្រភពទិន្នន័យ៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៨*

ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ




ប្រភពទិន្នន័យ៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៧*

## ១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍រួមមាន ផ្លូវគោក ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាស ។ បច្ចុប្បន្នឃុំទ្រាមានតែប្រព័ន្ធគមនាគមន៍ផ្លូវគោក និងផ្លូវទឹកប៉ុណ្ណោះហើយបានដើរតួយ៉ាងសំខាន់ក្នុងការសម្រួលដល់ការដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ។

នៅក្នុងឃុំទ្រា មានផ្លូវចំនួន ៦០ខ្សែ មានប្រវែងផ្លូវសរុបចំនួន ៩១ ៤១៨,៩០ម៉ែត្រ ហើយនៅក្នុងនោះ ផ្លូវក្រាលកៅស៊ូមានចំនួន៤ខ្សែ ប្រវែង១១ ៣៧៦,៤៣ម៉ែត្រ ផ្លូវក្រាលគ្រួសក្រហមមាន១៦ខ្សែ មានប្រវែង ២០ ៣៩៨,៣៧ម៉ែត្រ និងផ្លូវលំដីសមាន៤០ខ្សែ មានប្រវែង ៥៩ ៦៤៤,១០ម៉ែត្រ ដែលបានធ្វើការរៀបរាប់យ៉ាងលម្អិតនៅក្នុងតារាងខាងក្រោម ។ នៅក្នុងឃុំទ្រា មានការរីកចម្រើនផ្នែកប្រព័ន្ធដឹកជញ្ជូនគួរឱ្យកត់សម្គាល់ ប៉ុន្តែផ្លូវមួយចំនួនត្រូវបានខូចខាតទៅវិញជាបណ្តើរៗ ដោយការដឹកជញ្ជូនលើសទម្ងន់ ខូចខាតដោយគ្រោះធម្មជាតិ និងសកម្មភាពរបស់មនុស្សប្រចាំថ្ងៃ ។

តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន

| ល.រ | ប្រភេទផ្លូវជាភាសាខ្មែរ | ចំនួនខ្សែផ្លូវ | ប្រវែង (ម) |
|---|---|---|---|
| ១ | ផ្លូវចាក់កៅស៊ូ | ៤ខ្សែ | ១១ ៣៧៦,៤៣ |
| ២ | ផ្លូវគ្រួសក្រហមឬក្រាលថ្ម | ១៦ខ្សែ | ២០ ៣៩៨,៣៧ |
| ៣ | ផ្លូវដីស | ៤០ខ្សែ | ៥៩ ៦៤៤,១០ |

ប្រភពទិន្នន័យ៖ *ក្រុមការងារបច្ចេកទេស GIS និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

រូបភាព 4៖ ប្រព័ន្ធគមនាគមន៍



ផ្លូវកៅស៊ូ



ផ្លូវលំ



ផ្លូវគ្រួសក្រហម

ផែនទី ៦៖ ផែនទីហេដ្ឋារចនាសម្ព័ន្ធនៅក្នុងឃុំទ្រា



## ១.២.៤.បរិក្ខាសាធារណ:

### ក. ស្ថានភាពប្រើប្រាស់អគ្គិសនី

បេសកកម្មរបស់មន្ទីររ៉ែ និងថាមពលខេត្តកំពង់ធំ គឺដឹកនាំជំរុញការគ្រប់គ្រង និងសមាហរណកម្មលើវិស័យរ៉ែ និងថាមពលរួមទាំងប្រេងកាត ឧស្ម័ន និងអគ្គិសនី នៅក្នុងសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម នៅមូលដ្ឋាន និងក្នុងខេត្តកំពង់ធំ ក្នុងនាមជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពល ។

ដោយយោងទៅតាមទិន្នន័យមន្ទីរផែនការឆ្នាំ ២០១៧ បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំទ្រា ប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីមានចំនួន ៨៣០ខ្នងផ្ទះ ស្មើនឹង ៣៥,៨ភាគរយ ផ្ទះបំភ្លឺដោយអាគុយមានចំនួន ៥៧១ ខ្នងផ្ទះស្មើនឹង២៤,៦ភាគរយ ប្រើប្រាស់បន្ទះសូឡាចំនួន ៤៣៨ខ្នងផ្ទះ ស្មើនឹង១៨,៩ភាគរយ ហើយផ្ទះមានទូរទស្សន៍ប្រើប្រាស់មានចំនួន ១០៦៣ខ្នងផ្ទះ ស្មើនឹង៤៥,៩ភាគរយ ។ ដូច្នេះប្រជាពលរដ្ឋប្រើប្រាស់ដោយបណ្តាញអគ្គិសនីមានចំនួនច្រើនជាងគេ ហើយបន្ទះសូឡាមានចំនួនតិចជាងគេ ។

តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី

| បរិយាយ | ២០១៦(%) | ២០១៧ | |
|---|---|---|---|
| | | ភាគរយ(%) | ចំនួនផ្ទះ |
| ផ្ទះបំភ្លឺដោយបណ្តាញអគ្គិសនី | ៤៥,៣ | ៧៥ | ២ ០១០ |
| ផ្ទះបំភ្លឺដោយអាគុយ | ៣០,៦ | ២៤,៦ | ៥៧១ |
| ផ្ទះបំភ្លឺដោយបន្ទះសូឡា | ៦,១ | ១៨,៩ | ៤៣៨ |
| ផ្ទះបំភ្លឺដោយឡជីវឧស្ម័ន | ០,២ | ០,០ | ០ |
| ផ្ទះមានទូរទស្សន៍ប្រើប្រាស់ | ៦២,២ | ៤៥,៩ | ១ ០៦៣ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

### ខ. ប្រព័ន្ធទឹកស្អាត

អាជ្ញាធរខេត្តកំពង់ធំ បានអំពាវនាវឱ្យប្រជាពលរដ្ឋ ដែលធ្លាប់ប្រើប្រាស់ទឹកស្ទឹង ត្រពាំង ឬអណ្តូងដៃងាកមកបរិភោគទឹកស្អាតវិញ ដើម្បីជួយលើកកម្ពស់សុខភាព និងលើកស្ទួយអនាម័យនៅជនបទ ។ នៅក្នុងឃុំទ្រា ប្រជាពលរដ្ឋបានប្រើប្រាស់ទឹកអណ្តូងស្នប់ ឬអណ្តូងចម្រុះមានចំនួន ៩៧អណ្តូង អណ្តូងជីកមានការពារមានចំនួន ១៨២អណ្តូង ចំនួនអណ្តូងជីកគ្មានការពារមានចំនួន ៥២អណ្តូង និងចំនួនស្រះទឹកដែលប្រើប្រាស់មានចំនួន ២៤៥ស្រះ ហើយនៅក្នុងនោះ ចំនួនស្រះទឹកមានការប្រើប្រាស់ចំនួនច្រើនជាងគេ និងចំនួនអណ្តូងជីកគ្មានការពារមានចំនួនតិចជាងគេ ។

តារាង 21៖ ស្ថិតិប្រភពទឹកប្រើប្រាស់

| ល.រ | បរិយាយ | ២០១៦ | ២០១៧ |
|---|---|---|---|
| ១ | ចំនួនអណ្តូងស្នប់ឬអណ្តូងចម្រុះ | ១០១ | ៩៧ |
| ២ | ចំនួនអណ្តូងជីកមានការពារ | ១៩២ | ១៨២ |
| ៣ | ចំនួនអណ្តូងជីកគ្មានការពារ | ៥០ | ៥២ |
| ៤ | ចំនួនស្រះទឹកដែលប្រើប្រាស់ | ១៥៩ | ២៤៥ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

# ១.៣.ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

## ១.៣.១.ស្ថានភាពការកាន់កាប់ និងគ្រប់គ្រងដី

ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញនៅក្នុងឃុំទ្រា



ផែនទី ៥៖ ផែនទីប្រើប្រាស់ដីលម្អិតក្នុងនៅក្នុងឃុំទ្រា



តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្នឃុំទ្រា

| ប្រភេទប្រើប្រាស់ដី | បរិយាយ | ផ្ទៃដី (ហិកតា) | ភាគរយ(%) |
|---|---|---|---|
| **ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ** | | **២៦៤,០៨** | **២,១៤** |
| -ដីលំនៅដ្ឋានភូមិក្រៅតំបន់ការពារ | កន្លែងសង់លំនៅឋាន | ២១៨,៧៧ | ១,៧៧ |
| -ដីលំនៅឋានភូមិក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាប(សត្វខ្សឹប)ត្រួតគ្នាជាមួយគម្របព្រៃឆ្នាំឈើ២០០២ | កន្លែងសង់លំនៅឋាន | ៣៣,៩៦ | ០,២៧ |
| -ដីលំនៅឋានភូមិក្នុងគម្របព្រៃឈើឆ្នាំ២០០២ | កន្លែងសង់លំនៅឋាន | ៧,២៧ | ០,០៦ |
| -កន្លែងកប់ខ្មោច | កន្លែងបញ្ចុះសព | ៤,០៨ | ០,០៣ |
| **ខ.ដីកសិកម្ម** | | **១០ ៣០០** | **៨៣,៣៧** |
| -ដីស្រែវស្សាក្រៅតំបន់ការពារ | កន្លែងធ្វើស្រែវស្សា | ២ ៨៥០ | ២៣,០៧ |
| -ដីស្រែវស្សាក្នុងគម្របព្រៃឈើ២០០២ | កន្លែងធ្វើស្រែវស្សា | ១ ៨០០ | ១៤,៥៧ |
| -ដីស្រែវស្សាក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាប(សត្វខ្សឹប)ត្រួតគ្នាជាមួយគម្របព្រៃឈើឆ្នាំ២០០២ | កន្លែងធ្វើស្រែវស្សា | ៣៥០ | ២,៨៣ |
| -ដីចម្ការក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាបសត្វខ្សឹបត្រួតគ្នាជាមួយគម្របព្រៃឈើឆ្នាំ២០០២ | កន្លែងដាំដំណាំ | ២ ១០០ | ១៧ |
| -ដីចម្ការក្នុងគម្របព្រៃឈើ២០០២ | កន្លែងដាំដំណាំ | ៣ ២០០ | ២៥,៩ |
| **គ.ដីព្រៃ/គម្របព្រៃ** | | **១ ៦៩៤,៤៥** | **១៣,៧១** |
| -ព្រៃជាមួយចម្ការក្នុងគម្របព្រៃឆ្នាំ២០០២ | ព្រៃលាយចម្ការ | ៣៤,៣៨ | ០,២៨ |
| ព្រៃជាមួយដីស្រែក្នុងគម្របព្រៃឈើឆ្នាំ២០០២ | ព្រៃជាមួយកសិកម្ម | ៨៩០ | ៧,២ |
| -ព្រៃជាមួយដីស្រែក្នុងតំបន់ការពារ(សត្វខ្សឹប)ត្រួតគ្នាជាមួយគម្របព្រៃឈើឆ្នាំ២០០២ | ព្រៃជាមួយកសិកម្ម | ៤៩០ | ៣,៩៧ |
| -ព្រៃល្បោះ | ព្រៃល្បោះ | ២៨០ | ២,២៧ |
| -ព្រៃតាមដងស្ទឹង | ព្រៃដែលដុះអមមាត់ស្ទឹង | ០,០៧ | ០,០០ |
| **ឃ.ផ្ទៃទឹកនិងខ្សែទឹក** | | **៩៦,៩** | **០,៧៨** |
| -ស្ទឹងមានទឹកតាមរដូវ | ផ្គត់ផ្គង់ទឹកប្រើប្រាស់ | ៦៧,១៥ | ០,៥៤ |
| -ស្រះ | ផ្គត់ផ្គង់ទឹកប្រើប្រាស់ | ២៩,៧៥ | ០,២៤ |
| **ផ្ទៃដីឃុំសរុប** | | **១២ ៣៥៥,៤៣** | **១០០** |

ក. ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ

**-ដីលំដីលំនៅឋាន ភូមិ៖**

ដីលំនៅឋានភូមិ គឺជាដីត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែ ។ នៅក្នុងឃុំទ្រា ដីលំនៅឋានភូមិភាគច្រើន ស្ថិតនៅខាងកើតផ្លូវជាតិលេខ៦ចូលទៅក្នុងប្រហែល២០០ម៉ែត្រ មានផ្ទៃដីទំហំ២៦០ហិកតា ក្នុងនោះមាន៤តំបន់ ដែលតំបន់ទី១ស្ថិតនៅភាគខាងត្បូងឃុំតាមបណ្តោយផ្លូវជាតិលេខ៦ ផ្លូវវៀងស្រុកស្ទោង ជាផ្លូវកៅស៊ូដែលចេញពីផ្លូវជាតិលេខ៦ ឆ្ពោះទៅកាន់ឃុំបន្ទាយស្ទោង ព្រមទាំងផ្លូវលំគ្រួសក្រហមសំខាន់ៗមួយចំនួនទៀត ដែលមានភូមិសាមក្អោក ភូមិទទា ភូមិហប់ ភូមិកោះ ភូមិលាបទង ភូមិផ្ទះវាល ភូមិប្រាំងស ភូមិទ្រា ភូមិតាចរ និងភូមិវាល ។ តំបន់ទី២ ស្ថិតនៅតាមបណ្តោយផ្លូវគ្រួសក្រហមដែលចេញពីផ្លូវជាតិលេខ៦ កាត់ផ្លូវវៀងក្រុងស្ទោងឆ្ពោះទៅកាន់ភាគខាងកើតនៃឃុំ ។ ភូមិបុសតាឯក និង២តំបន់ទៀតស្ថិតនៅតាមបណ្តោយផ្លូវគ្រួសក្រហមដែលចេញពីផ្លូវជាតិលេខ៦ ឆ្ពោះទៅភាគខាងជើងឆៀងខាងកើតនៃឃុំ ដែលមានភូមិស្លា ភូមិក្រសាំងភូមិកុចទីទុយ ភូមិពពាយ និងភូមិទំពេជ ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំទ្រា នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋានភូមិទាំងអស់ ជាតំបន់ជម្រាលទាប និងធម្យម មានប្រភេទដីកណ្តេងលាយល្បាប់(ពណ៌លឿង) និងខ្សាច់លាយកណ្តេង ដែលដីលំនៅឋានភូមិស្ថិតក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាបនិងដីលំនៅឋានភូមិស្ថិតក្នុងគម្របព្រៃឈើឆ្នាំ២០០២ ជាដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ត្រូវបានប្រជាពលរដ្ឋកាន់កាប់ប្រើប្រាស់សាងសង់លំនៅឋាន ហើយដីលំនៅឋានភូមិទាំងអស់នេះ មិនត្រូវបានធ្វើការចុះបញ្ជីជាលក្ខណៈប្រព័ន្ធរួចរាល់នោះទេ ដែលនៅក្នុងបច្ចុប្បន្ននេះបាននឹងកំពុងប្រើប្រាស់ជាដីលំនៅឋាន ភូមិហើយស្ថិតនៅតាម ០៣ផ្សេងគ្នា គឺដីលំនៅឋានភូមិក្រៅតំបន់ការពារ ដីលំនៅឋានភូមិក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាប(សត្វខ្សឹប) ត្រួតគ្នាក្នុងគម្របព្រៃឈើឆ្នាំ២០០២ និងដីលំនៅឋានភូមិក្នុងតំបន់គម្របព្រៃឈើឆ្នាំ២០០២ ដូចមានរៀបរាប់ខាងក្រោម៖

**-ដីលំនៅឋានភូមិក្រៅតំបន់ការពារ**

ដីលំនៅឋាន ភូមិ ក្រៅតំបន់ការពារ ស្ថិតនៅខាងកើតផ្លូវជាតិលេខ៦ ប្រហែលជា២០០ម៉ែត្រ មានផ្ទៃដីទំហំ ២១៨,៧៧ហិកតា ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំទ្រា នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋាន ភូមិនេះ ជាតំបន់ជម្រាលទាប មានប្រភេទដីកណ្តេងលាយល្បាប់(ពណ៌លឿង)និងខ្សាច់លាយកណ្តេង ដែលដីលំនៅឋានភូមិនេះ ជាដីកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ ត្រូវបានកាន់កាប់ និងប្រើប្រាស់ដោយប្រជាពលរដ្ឋក្នុងឃុំ ។

**-ដីលំនៅឋានភូមិក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាប(សត្វខ្សឹប)ត្រួតគ្នាជាមួយគម្របព្រៃឈើឆ្នាំ២០០២**

ដីលំនៅឋាន ភូមិក្នុងតំបន់ការពារត្រួតគ្នានេះ ស្ថិតនៅភាគកណ្តាលឆៀងខាងកើតនៃឃុំ ដែលមានផ្ទៃដីទំហំ ៣៣,៩៦ហិកតា ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំទ្រា នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋានភូមិនេះ ជាតំបន់ជម្រាលធម្យម មានប្រភេទដីកណ្តេងលាយល្បាប់ (ពណ៌លឿង) និងខ្សាច់លាយកណ្តេង ដែលដីលំនៅឋានភូមិនេះ ជាដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋ បច្ចុប្បន្ននេះត្រូវបានប្រជាពលរដ្ឋកាន់កាប់ប្រើប្រាស់សាងសង់ជាលំនៅឋាន ។

**-ដីលំនៅឋានភូមិក្នុងតំបន់គម្របព្រៃឈើឆ្នាំ២០០២**

ដីលំនៅឋាន ភូមិក្នុងតំបន់គម្របព្រៃឈើឆ្នាំ២០០២ ស្ថិតនៅភាគខាងត្បូងនៃឃុំ ដែលមានផ្ទៃដីទំហំ ៧,២៧ ហិកតា ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំទ្រា នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ ដីលំនៅឋាន ភូមិនេះ ជាតំបន់ជម្រាលចម្យម មានប្រភេទដីកណ្តេងលាយល្បាប់(ពណ៌លឿង) និងខ្សាច់លាយកណ្តេង ដែលដីលំនៅឋានភូមិនេះ ជាដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ដែលបច្ចុប្បន្ននេះត្រូវបានប្រជាពលរដ្ឋកាន់កាប់ប្រើប្រាស់សាងសង់ជាលំនៅឋាន ។

រូបភាព 5៖ ដីលំនៅឋាន ភូមិ

|  |  |
| --- | --- |
| លំនៅឋានភូមិក្នុងតំបន់ការពារ | លំនៅឋានភូមិក្រៅតំបន់ការពារ |

**-កន្លែងកប់ខ្មោច**

ឃុំទ្រា មានកន្លែងកប់ខ្មោចចំនួនពីរកន្លែង ដែលមានផ្ទៃដីទំហំ ៤,០៨ហិកតា ដែលស្ថិត នៅក្នុងភូមិតាចរ និង១កន្លែងទៀតស្ថិតនៅក្នុងភូមិបុសតាឯក ។ ដីកប់ខ្មោចទាំងនេះ ជាដីឯកជនរបស់រដ្ឋ គ្រប់គ្រងនិងប្រើប្រាស់ដោយសហគមន៍ក្នុងឃុំទ្រា ។

រូបភាព 6៖ កន្លែងកប់ខ្មោចនៅក្នុងឃុំទ្រា




## ខ. ដីកសិកម្ម៖

### ខ.១. ដីស្រែវស្សា

នៅក្នុងឃុំទ្រា មានដីស្រែវស្សា ដែលមានផ្ទៃដីសរុបទំហំ ៥ ០០០ហិកតា ភាគច្រើនស្ថិតនៅភាគខាងត្បូងនៃឃុំ និងតិចតួចនៅភាគខាងជើងនៃឃុំ ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំទ្រា នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែវស្សាទាំងនេះ មានស្ថានភាពជាតំបន់ជម្រាលខ្ពស់ មធ្យមនិងជម្រាលទាបមានប្រភេទដីកណ្តោងលាយល្បាប់ (ពណ៌លឿង) និងខ្សាច់លាយកណ្តោង និងមានល្បាយខ្សាច់ (សលាយក្រហម) ជាដីឯកជនរបស់រដ្ឋ និងរបស់ប្រជាពលរដ្ឋ ដោយមិនទាន់ត្រូវបានធ្វើការចុះបញ្ជីកាន់កាប់រួចរាល់នោះទេ។ ដីស្រែវស្សាទាំងនេះ ពឹងផ្អែកលើប្រភពស្រោចស្រពពី ទឹកភ្លៀង ទឹកស្ទឹងស្ទោង អណ្តូងនិងស្រះ។ ដីស្រែវស្សាទាំងនេះត្រូវបានបែងចែកទៅតាមតំបន់៣ផ្សេងៗពីគ្នាដូចមានរៀបរាប់ខាងក្រោម៖

**-ដីស្រែវស្សាក្រៅតំបន់ការពារ**

ដីស្រែវស្សាក្រៅតំបន់ការពារ មានផ្ទៃដីទំហំ ២៨៥០ហិកតា មានភាគច្រើនស្ថិតនៅភាគខាងត្បូងនៃឃុំ និងមានតិចតួចនៅភាគខាងជើងនៃឃុំ ។ ដីស្រែវស្សានេះ គឺជាដីកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ ត្រូវបានកាន់កាប់ និងប្រើប្រាស់ដោយប្រជាពលរដ្ឋនៅក្នុងឃុំ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំទ្រានៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែវស្សានេះ មានស្ថានភាពជាតំបន់ជម្រាលខ្ពស់ មធ្យម និងជម្រាលទាប មានប្រភេទដីកណ្តោងលាយល្បាប់(ពណ៌លឿង) និងខ្សាច់លាយកណ្តោង និងមានល្បាយខ្សាច់(សលាយក្រហម) ដីស្រែវស្សាទាំងនេះ ពឹងផ្អែកលើប្រភពទឹកស្រោចស្រពពី ទឹកភ្លៀង ទឹកស្ទឹងស្ទោង អណ្តូង និងស្រះ ។

**-ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២**

ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ១ ៨០០ហិកតា ស្ថិតនៅភាគកណ្តាលនៃឃុំ ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំទ្រា នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែវស្សានេះ មានស្ថានភាពជាតំបន់ជម្រាលខ្ពស់ និងជម្រាលមធ្យម ដែលមានប្រភេទដីខ្សាច់លាយកណ្តោង និងមានល្បាយខ្សាច់ (សលាយក្រហម) ជាដីឯកជនរបស់រដ្ឋ ដែលបច្ចុប្បន្នេះត្រូវបានប្រជាពលរដ្ឋធ្វើស្រែ ដោយមិនទាន់ត្រូវបានធ្វើការចុះបញ្ជីកាន់កាប់រួចរាល់នោះទេ ។ ដីស្រែវស្សានេះ បើពឹងផ្អែកលើប្រភពស្រោចស្រពពីទឹកភ្លៀង ទឹកស្ទឹងស្ទោងអណ្តូងនិងស្រះ ។

**-ដីស្រែវស្សាក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាប(សត្វខ្សឹប)ត្រួតគ្នាជាមួយគម្របព្រៃឈើឆ្នាំ២០០២**

ដីស្រែវស្សាក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាប (សត្វខ្សឹប) ត្រួតគ្នាជាមួយគម្របព្រៃឈើឆ្នាំ ២០០២ មានផ្ទៃដីទំហំ ៣៥០ហិកតា ស្ថិតនៅភាគកណ្តាលឆៀងខាងកើតនៃឃុំ ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំទ្រា នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែវស្សានេះ មានស្ថានភាពជាតំបន់ជម្រាលខ្ពស់ និងជម្រាលមធ្យម មានប្រភេទដីខ្សាច់លាយកណ្តោង និងមានល្បាយខ្សាច់(សលាយក្រហម) ជាដីឯកជនរបស់រដ្ឋ ដែលបច្ចុប្បន្នេះត្រូវបានប្រជាពលរដ្ឋធ្វើស្រែ ដោយមិនទាន់ត្រូវបានធ្វើការចុះបញ្ជីកាន់កាប់រួចរាល់នោះទេ ។ ដីស្រែវស្សានេះ ពឹងផ្អែកលើប្រភពស្រោចស្រពពី ទឹកភ្លៀង ទឹកស្ទឹងស្ទោង អណ្តូង និងស្រះ ។

រូបភាព 7៖ ដីស្រែវស្សានៅក្នុងឃុំទ្រា

|  |  |  |
|---|---|---|
| ដីស្រូវវស្សាក្រៅតំបន់ការពារ | ដីស្រូវវស្សាក្នុងគម្របព្រៃឈើ | ដីស្រូវវស្សាតំបន់ការពារ( សត្វខ្សឹប ) |

## ខ.២. ដីចម្ការ

នៅក្នុងឃុំទ្រា ដីចម្ការមានផ្ទៃដីទំហំ ៥ ៣០០ហិកតា មានពីរកន្លែង ដែលមួយកន្លែងស្ថិតនៅភាគខាងកើតនៃឃុំជាប់ព្រំប្រទល់ជាមួយឃុំដូងស្រុកប្រាសាទបល្ល័ង្គ មានផ្ទៃដីទំហំ ២ ១០០ហិកតា ជាដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២ និងមួយកន្លែងទៀត ស្ថិតនៅភាគខាងជើងឆៀងខាងលិចនៃឃុំជាប់ឃុំប្រទ្បាយ និងឃុំពពក មានផ្ទៃដីទំហំ ៣ ២០០ហិកតា ជាដីចម្ការក្នុងតំបន់ការពារខាងជើងទន្លេសាប (សត្វខ្សឹប) ត្រួតគ្នាក្នុងគម្របព្រៃឈើឆ្នាំ២០០២ ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំទ្រា នៃរបាយការណ៍វិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថាន ដី ដីចម្ការទាំងនេះ មានស្ថានភាពជាតំបន់ជម្រាលខ្ពស់ និងជម្រាលមធ្យម ដែលមានប្រភេទដីកណ្តេងលាយល្បាប់ (ពណ៌លឿង) និងខ្សាច់លាយកណ្តេង និងមានល្បាយខ្សាច់(សលាយក្រហម) ជាដីឯកជនរបស់រដ្ឋ ដែលត្រូវបានប្រជាពលរដ្ឋបានធ្វើចម្ការ និងមិនទាន់ត្រូវបានធ្វើការចុះបញ្ជីកាន់កាប់រួចរាល់នោះទេ ។ ដីចម្ការទាំងនេះ ពឹងផ្អែកលើប្រភពស្រោចស្រពពី ទឹកភ្លៀង អណ្តូង និងស្រះ ។

**-ដីចម្ការក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាប ( សត្វខ្សឹប )ត្រួតគ្នាជាមួយគម្របព្រៃឈើឆ្នាំ២០០២**

ដីចម្ការក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាប( សត្វខ្សឹប )ត្រួតគ្នាគម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ២ ១០០ហិកតា ស្ថិតនៅភាគខាងកើតនៃឃុំជាប់ជាមួយឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ។ ដីចម្ការនេះ គឺជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែអាស្រ័យផលតែប៉ុណ្ណោះ ។ ដីចម្ការនេះ ពឹងផ្អែកលើប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ទឹកអណ្តូង និងស្រះ ។

**-ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២**

ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ៣ ២០០ហិកតា ស្ថិតនៅភាគខាងជើងឆៀងខាងលិចនៃឃុំជាប់ជាមួយឃុំប្រទ្បាយ និងឃុំពពក ។ ដីចម្ការនេះ គឺជាដីសធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែអាស្រ័យផលតែប៉ុណ្ណោះ។ ដីចម្ការនេះ ពឹងផ្អែកលើប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ទឹកអណ្តូង និងទឹកស្រះ ។

រូបភាព ៩៖ ដីចម្ការនៅក្នុងឃុំទ្រា



ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២



ដីចម្ការក្នុងតំបន់ការពារ(សត្វខ្សឹប)

គ. ដីព្រៃ/គម្របព្រៃ៖

**-ព្រៃជាមួយចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២**

នៅក្នុងឃុំទ្រា ព្រៃជាមួយចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ៣៤,៣៨ហិកតា ស្ថិតនៅភាគខាងលិចនៃឃុំ ដែលប្រជាពលរដ្ឋធ្វើការដាំដំណាំស្វាយចន្ទី និងដំណាំស្វាយនៅលាយឡំជាមួយតំបន់ព្រៃ ។ ផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំទ្រា នៃរបាយការណ៍វិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថាន ដីព្រៃនេះ មានស្ថានភាពជាតំបន់ជម្រាលជម្រាលមធ្យម មានប្រភេទដីកណ្តោងលាយល្បាប់ (ពណ៌លឿង) និងខ្សាច់លាយកណ្តោង និងល្បាយខ្សាច់ (សលាយក្រហម) គឺជាដីឯកជនរបស់រដ្ឋ ដែលត្រូវបានប្រជាពលរដ្ឋបានធ្វើចម្ការនៅក្នុងព្រៃនិងមិនទាន់ត្រូវបានធ្វើការចុះបញ្ជីកាន់កាប់រួចរាល់នោះទេ ។ ដីព្រៃនេះ គឺជាដីសាធារណៈរបស់រដ្ឋ ដែលត្រូវបានប្រជាពលរដ្ឋបានដាំដំណាំស្វាយចន្ទី និងស្វាយក្នុងចន្លោះព្រៃដែលមានវាល និងមានកន្លែងខ្លះត្រូវបានកាប់ស្ការដើម្បីដាំណាំនេះ ។ ដីព្រៃនេះ ពឹងផ្អែកលើប្រភពស្រោចស្រពពី ទឹកភ្លៀង ទឹកស្ទឹងស្ទោង អណ្តូង និងស្រះ ។

**-ព្រៃជាមួយដីស្រែក្នុងគម្របព្រៃឈើឆ្នាំ២០០២**

នៅក្នុងឃុំទ្រា ព្រៃជាមួយដីស្រែក្នុងគម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ៨៩០ហិកតា ដែលស្ថិតនៅភាគកណ្តាលនៃឃុំ ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំទ្រា នៃរបាយការណ៍វិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថាន ដីព្រៃនេះ មានស្ថានភាពជាតំបន់ជម្រាលជម្រាលមធ្យម មានប្រភេទដីកណ្តោងលាយល្បាប់ (ពណ៌លឿង) និងខ្សាច់លាយកណ្តោងនិងមានល្បាយខ្សាច់(សលាយក្រហម) ជាដីឯកជនរបស់រដ្ឋ ដែលត្រូវបានប្រជាពលរដ្ឋបានធ្វើស្រែនៅក្នុងព្រៃ និងមិនទាន់ត្រូវបានធ្វើការចុះបញ្ជីកាន់កាប់រួចរាល់នោះទេ ។ ដីព្រៃនេះ គឺជាដីសាធារណៈរបស់រដ្ឋ ដែលត្រូវបានប្រជាពលរដ្ឋបានធ្វើស្រែក្នុងចន្លោះព្រៃដែលមានវាល និងមានកន្លែងខ្លះត្រូវបានកាប់ស្ការដើម្បីធ្វើស្រែ ។ ដីព្រៃនេះ ពឹងផ្អែកលើប្រភពស្រោចស្រពពី ទឹកភ្លៀង ទឹកស្ទឹងស្ទោង អណ្តូង និងស្រះ ។

**-ព្រៃជាមួយដីស្រែក្នុងតំបន់ការពារ(សត្វខ្សឹប)ត្រួតគ្នាជាមួយគម្របព្រៃឈើឆ្នាំ២០០២**

នៅក្នុងឃុំទ្រា ព្រៃជាមួយដីស្រែក្នុងតំបន់ការពារ (សត្វខ្សឹប) ត្រួតគ្នាក្នុងគម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ៤៩០ហិកតា ដែលស្ថិតនៅភាគកណ្តាលឆៀងខាងកើតនៃឃុំ ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំទ្រា នៃរបាយការណ៍វិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថានដីព្រៃនេះ មានស្ថានភាពជាតំបន់ជម្រាលជម្រាលមធ្យម មានប្រភេទដីកណ្តោងលាយល្បាប់(ពណ៌លឿង) ខ្សាច់លាយកណ្តោង និងមានល្បាយខ្សាច់ (សលាយក្រហម)

ជាដីឯកជនរបស់រដ្ឋ ដែលត្រូវបានប្រជាពលរដ្ឋបានធ្វើស្រែនៅក្នុងព្រៃ និងមិនទាន់ត្រូវបានធ្វើការចុះបញ្ជីកាន់កាប់រួចរាល់នោះទេ ដីព្រៃនេះ គឺជាដីសាធារណៈរបស់រដ្ឋ ដែលត្រូវបានប្រជាពលរដ្ឋបានធ្វើស្រែក្នុងចន្លោះព្រៃ ដែលមានវាល និងមានកន្លែងខ្លះត្រូវបានកាប់ស្ការដើម្បីធ្វើស្រែ ។ ដីព្រៃនេះ ពឹងផ្អែកលើប្រភពស្រោចស្រពពីទឹកភ្លៀង ទឹកស្ទឹងស្ទោង អណ្តូង និងស្រះ ។

រូបភាព ៩៖ ព្រៃជាមួយដីចម្ការ និងស្រែ

| | | |
|---|---|---|
|  |  |  |
| ព្រៃជាមួយចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២ | ព្រៃជាមួយដីស្រែក្នុងគម្របព្រៃឈើឆ្នាំ២០០២ | ព្រៃជាមួយដីស្រែក្នុងតំបន់ការពារ( សត្វខ្សឹប ) |

**-ព្រៃល្បោះ**

នៅក្នុងឃុំទ្រា ព្រៃល្បោះ មានផ្ទៃដីទំហំ២៨០ហិកតា ស្ថិតនៅភាគខាងជើងនៃឃុំ នៅជាប់ដីស្រែវស្សា និងដីចម្ការមួយផ្នែកធំ និងនៅជាប់ព្រំប្រទល់ឃុំសាមគ្គីមួយភាគតូច ដែលមានសំបូរទៅដោយព្រៃខ្លុង ត្បែង និងមានឈើចម្រុះតូចធំជាច្រើនប្រភេទទៀត នៅលាយឡំគ្នា ។ ព្រៃទាំងនេះ បច្ចុប្បន្នគឺជាព្រៃសហគមន៍ដែលគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ និងសហគមន៍មូលដ្ឋានក្នុងឃុំទ្រា ។

រូបភាព 10៖ ព្រៃល្បោះ

| | |
|---|---|
|  |  |

**-ព្រៃតាមដងស្ទឹង**

ព្រៃតាមដងស្ទឹងនៅក្នុងឃុំទ្រា មាននៅតាមដងស្ទឹងស្ទោង ដែលមានផ្ទៃដីទំហំ០,០៧ហិកតា សម្បូរទៅដោយដើមឈើចំរុះដុះលាយឡំគ្នាដូចជា៖ ដើមភ្នំភ្លើង ត្រល់ កប្បាស់ព្រៃ ស្មាច់ និងដើមរាំងជាដើម ហើយដើមទាំងនេះមានសារៈប្រយោជន៍ក្នុងការជួយការពារការហូរច្រោះបាក់ដី និងជាជំរកត្រីមួយយ៉ាងសំខាន់នៅរដូវត្រី

ពងកូន ។ ហើយបច្ចុប្បន្ននេះព្រៃ ដែលដុះតាមមាត់ស្ទឹងនេះមានការកាប់បំផ្លាញពីប្រជាពលរដ្ឋយើងដែលកាប់ដើម្បីធ្វើជាសំរាស់ កាប់ដើម្បីធ្វើអុសដុត និងជាពិសេសដុតដើម្បីចាប់សត្វ ដូចជាអណ្តើក យ៉ុំ ជាដើម ។

រូបភាព 11៖ ព្រៃតាមដងស្ទឹងនៅក្នុងឃុំទ្រា





ឃ. ផ្ទៃទឹក និងខ្សែទឹក៖

**-ស្ទឹងមានទឹកតាមរដូវ**

នៅក្នុងឃុំទ្រា មានស្ទឹងចំនួន ១ខ្សែ មានទំហំ ៦៧,១៥ហិកតា ស្ថិតនៅភាគខាងលិចនៃឃុំជាប់ជាមួយឃុំប្រឡាយ ដែលជាប្រភពទឹកដ៏សំខាន់សម្រាប់ស្រោចស្រពដំណាំស្រូវ និងការប្រើប្រាស់ផ្សេងៗរបស់ជាពលរដ្ឋនៅក្នុងឃុំ ដែលអាចប្រើប្រាស់បានសម្រាប់តែរដូវវស្សានៅពេលមានគ្រោះរាំងស្ងួត ចំណែកនៅក្នុងរដូវប្រាំងពុំមានទឹកនោះឡើយ ។ ទន្ទឹមនេះស្ទឹងនេះក៏ជាប្រភពជលផលសម្រាប់ការនេសាទជាលក្ខណៈគ្រួសារក្នុងឃុំផងដែរ ។

រូបភាព 12៖ ស្ទឹងមានទឹកតាមរដូវនៅក្នុងឃុំទ្រា





**-ស្រះទឹក**

នៅក្នុងឃុំទ្រា មានស្រះទឹកជាច្រើន ដែលមានផ្ទៃដីទំហំសរុបចំនួន២៩,៧៥ហិកតា ដែលភាគច្រើនស្ថិតនៅក្រៅតំបន់ការពារ និងមានតិចតួចស្ថិតក្នុងតំបន់ការពារសត្វខ្សឹបនិងក្នុងគម្របព្រៃឈើឆ្នាំ២០០២ ក្នុងនោះ

ស្រះដែលស្ថិតក្រៅតំបន់ការពារ មានផ្ទៃដីទំហំ២៧ហិកតា ចំណែកស្រះទឹក ស្ថិតក្នុងគម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ១,៣៤ហិកតា និងស្រះទឹក ដែលស្ថិតក្នុងតំបន់ការពារខាងជើងទន្លេសាប (សត្វខ្សឹប) មានផ្ទៃដីទំហំ១,៤១ហិកតា ។ ស្រះទឹកដែលស្ថិតនៅក្រៅតំបន់ការពារទាំងនេះគឺជាដីឯកជន ដែលកាន់កាប់និងប្រើប្រាស់ដោយប្រជាពលរដ្ឋ ហើយក្រៅពីនេះ គឺជាដីកម្មសិទ្ធិរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមតែកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ។ នាបច្ចុប្បន្នស្រះទាំងនេះ ត្រូវបានប្រើប្រាស់សម្រាប់ជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ។

រូបភាព 13៖ ស្រះទឹក

|  |  |  |
|---|---|---|
| ស្រះទឹកក្រៅតំបន់ការពារ | ទឹកក្នុងគម្របព្រៃឈើឆ្នាំ២០០២ | ស្រះទឹកក្នុងតំបន់ការពារ(សត្វខ្សឹប) |

ពាក់ព័ន្ធបញ្ហាផ្សេងៗ ក្នុងការប្រើប្រាស់ដីនៅក្នុងឃុំទ្រា តាមរយៈការសម្ភាសន៍លោកមេឃុំបានឱ្យដឹងថា មានប្រជាពលរដ្ឋក្នុងឃុំចំនួន ២៦៨គ្រួសារ មិនមានដីសម្រាប់សាងសង់លំនៅឋាន និង ៣៣៧គ្រួសារ មិនមានដីធ្វើរបរកសិកម្មឡើយ ។ ក្នុងចំណោមប្រជាពលរដ្ឋទាំងនេះ មានមួយចំនួនរស់នៅលើដីចិញ្ចើមផ្លូវ ស្ទឹង រស់នៅលើដីកម្មសិទ្ធិរបស់គេផ្សេង ព្រមទាំងមួយចំនួនទៀត រស់នៅជាមួយឪពុកម្ដាយ ។ ចំណែកបញ្ហាទំនាស់ក្នុងការការប្រើប្រាស់ដីនៅក្នុងឃុំទ្រាវិញ ពុំមានចេញជារូបភាពធំដុំគួរឱ្យកត់សម្គាល់ឡើយ ទោះបីមិនទាន់ត្រូវបានចុះបញ្ជីកាន់កាប់ដីរួចរាល់ក៏ដោយ តែបញ្ហាដែលកើតឡើងមានទំនាស់តិចតួច ក្រុមប្រឹក្សាឃុំអាចសម្របសម្រួល និងដោះស្រាយបាន ។

### ១.៣.២.ផលិតកម្មកសិកម្ម

#### ក. ផលិតកម្មដំណាំស្បៀង

ផលិតកម្មដំណាំស្បៀងនៅក្នុងឃុំទ្រា បានផ្ដោតសំខាន់ទៅលើផលិតកម្មដំណាំស្រូវ ហើយដំណាំនេះបានដើរតួយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍន៍ឃុំដោយសារផលិតផលស្រូវ ។ ក្រៅពីទុកផ្គត់ផ្គង់សម្រាប់ការហូបចុក ហើយ ប្រជាពលរដ្ឋបានលក់ស្រូវ ដែលនៅសល់សម្រាប់បំពេញតម្រូវការចាយវាយចាំបាច់ក្នុងជីវភាពរស់នៅផងដែរ។ ដំណាំស្រូវបានធ្វើការដាំដុះនៅលើផ្ទៃដីទំហំ ៥ ០០០ហិកតា ដែលជាប្រភេទដីប្រភេទដីកណ្ដោងលាយល្បាប់(ពណ៌លឿង) និងខ្សាច់លាយកណ្ដោង និងមានល្បាយខ្សាច់(សលាយក្រហម) ដែលបច្ចុប្បន្នធ្វើស្រែបានតែស្រូវវស្សា ហើយនិយមប្រើពូជស្រូវ ស្រូវផ្ការំដួល ស្រូវផ្កាម្លិះ នាងគង់ និង ស្រូវ៤៩ ។ ដំណាំស្រូវនៅក្នុងឃុំទ្រា ត្រូវបានប្រើប្រាស់ទឹកពីប្រភពទឹកភ្លៀង ស្ទឹងស្ទោង ស្រះទឹក និងអណ្ដូង ដោយប្រើប្រាស់ប្រព័ន្ធប្រឡាយ

មួយចំនួនដើម្បីបង្ហូរទឹកចូលស្រែ ដែលបច្ចុប្បន្ននេះនៅមានការខ្វះខាតនៅឡើយ ។ ជាទូទៅនៅក្នុងឃុំទ្រា ប្រជាពលរដ្ឋទទួលបានទិន្នផលស្រូវវស្សាជាមធ្យម១,៥តោន/(ហ.ត) ហើយនៅក្នុងឆ្នាំ២០១៧នេះ ឃុំទទួលបានទិន្នផលស្រូវសរុបចំនួន ៧ ៥០០ តោន ។ ប្រជាពលរដ្ឋបានទុកស្រូវពូជចំនួន១០ភាគរយ ស្មើនឹង ៧៥០ តោន និងនៅសល់៩០ ភាគរយ ស្មើនឹង ៦ ៧៥០ តោន បានធ្វើការលក់ចេញ ក្នុងតម្លៃជាមធ្យម ១ ០២៥រៀល/គ.ក្រ ដែលទទួលបានចំណូលសរុបប្រមាណ ៦ ៩១៨ ៧៥០ រៀល ។

តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - ភាពរាំងស្ងួត<br>- សត្វល្អិតបំផ្លាញ និងជម្ងឺលើដំណាំស្រូវ<br>- ប្រើប្រាស់ពូជស្រូវតាមទម្លាប់<br>- ខ្វះបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម<br>- ខ្វះបច្ចេកទេសដាំ និងថែទាំដំណាំស្រូវ<br>- ពុំទាន់មានប្រភពទឹកសម្រាប់ផ្គត់ផ្គង់ការស្រោចស្រព<br>- ប្រព័ន្ធប្រឡាយមានស្រាប់រងការខូចខាត (រាក់)<br>- ខ្វះកម្លាំងពលកម្ម(ចំណាកស្រុកច្រើន)។ | - មានដីស្រែធំទូលាយ<br>- ស្ថានភាពដីស្រែជាវាលទំនាប អាចមានលទ្ធភាព នាំទឹកពីប្រភពទឹកទន្លេ បឹង មកផ្គត់ផ្គង់ការស្រោចស្រព ដើម្បីធ្វើស្រែបង្កើនរដូវ២-៣ដងក្នុងមួយឆ្នាំបាន<br>- មានប្រព័ន្ធប្រឡាយស្រាប់<br>- មានកម្លាំងពលកម្មច្រើន<br>- មានគោលការណ៍ជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុង ការពង្រឹងតួនាទីលើវិស័យកសិកម្ម<br>- មានគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ របស់រាជរដ្ឋាភិបាល។ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំទ្រា ខែមិថុនា ឆ្នាំ២០១៨*

### ខ. ផលិតកម្មដំណាំរួមផ្សំ

ផលិតកម្មដំណាំរួមផ្សំនៅក្នុងឃុំទ្រា បច្ចុប្បន្នប្រជាពលរដ្ឋធ្វើការដាំដុះលក្ខណៈគ្រួសារនៅជុំវិញដីលំនៅឋាន ជុំវិញត្រពាំងបឹងបួរ និងកន្លែងដែលមានប្រភពទឹក ជាប្រភេទដីកណ្តោងលាយល្បាប់(ពណ៌លឿង) តែមិនមានទិន្នន័យពីទំហំផ្ទៃដីនោះទេ ហើយដំណាំទាំងនេះមានដូចជា៖ បន្លែ ពោត ស្ពៃ ត្រកួន ត្រសក់ សណ្តែកននោង ល្ពៅ ដែលភាគច្រើន ដែលទទួលបានការស្រោចស្រពពីស្ទឹងស្ទោង,ប្រឡាយ,អណ្តូង,ភ្លៀង,ស្រះ ហើយពួកគាត់ធ្វើការដាំដុះដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ និងលក់ដូរបន្តិចបន្តួច ដើម្បីបានកម្រៃខ្លះក្នុងការជួយបំពេញញការខ្វះខាតនៅក្នុងជីវភាពគ្រួសារតែប៉ុណ្ណោះ ។

តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - មានដីតិចតួចនៅជុំវិញលំនៅឋាន<br>- ដីខ្វះជីជាតិ<br>- ខ្វះទឹកស្រោចស្រពនៅរដូវប្រាំង<br>- ការយល់ដឹងពីបច្ចេកទេសដាំដំណាំ របស់ប្រជាពលរដ្ឋនៅមានកម្រិត។ | - មានដីនៅជុំវិញលំនៅឋាន<br>- មានប្រភពទឹកភ្លៀង ទឹកស្រះ និងទឹកក្រោមដី សម្រាប់ការស្រោចស្រព<br>- ប្រជាពលរដ្ឋមានការយល់ដឹងពីសារៈប្រយោជន៍នៃដំណាំរួមផ្សំដែលអាចជួយផ្គត់ផ្គង់ដល់ការហូបចុក ដោះស្រាយដល់ជីវភាពរស់នៅប្រចាំថ្ងៃ កាត់បន្ថយបានលើការចំណាយ។ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ទ្រា ខែមិថុនា ឆ្នាំ២០១៨*

### គ. ផលិតកម្មឧស្សាហកម្ម

ផលិតកម្មដំណាំឧស្សាហកម្មបច្ចុប្បន្នក្នុងឃុំទ្រា ក៏បានដើរតួយ៉ាងសំខាន់ដែរក្នុងការអភិវឌ្ឍន៍ឃុំបន្ទាប់ពីដំណាំស្រូវ ហើយត្រូវបានផលិតនៅលើផ្ទៃដី ៥ ៣០០ ហិកតា ដែលជាប្រភេទដីល្បាយខ្សាច់ មាននៅលើទីតាំងដីចំនួនពីរកន្លែងផ្សេងគ្នា ក្នុងនោះទីតាំងទី១ នៅភាកខាងជើងឆៀងខាងលិចនៃឃុំជាប់ជាមួយឃុំប្រឡាយនិងឃុំ ពពក និងទីតាំងទី២ នៅភាគខាងជើងឆៀងខាងកើតនៃឃុំជាប់ព្រំប្រទល់ជាមួយឃុំដូង ។ ដំណាំឧស្សាហកម្មទាំងនេះ ភាគច្រើនជាដំណាំស្វាយចន្ទី និងស្វាយកែវល្មៀតមានតិចតួច ដែលមិនមានទទូលបានការស្រោចស្រពបន្ថែមក្រៅពីទឹកភ្លៀង អណ្តូង និងទឹកស្រះនោះទេហើយទទួលបានទិន្នផល ជាមធ្យម១,៥តោន/ហិកតា សម្រាប់ស្វាយចន្ទី និងស្វាយកែវល្មៀតទទួលបានផលជាមធ្យម ០១តោន/ហិកតា ដែលទិន្នផលទាំងនេះ មិនមានរបាយការណ៍បញ្ជាក់ទូទាំងឃុំទេ ពីឃុំសម្រាប់ផលិតផលកសិកម្មទាំងនេះ ។

តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| -ខ្វះទឹកស្រោចស្រព<br>-បញ្ហាជួបគ្រោះរាំងស្ងួត<br>-បញ្ហាជួបទឹកជំនន់(ទឹកភ្លៀង)<br>-បញ្ហាសត្វល្អិតបំផ្លាញ<br>-បញ្ហាតម្លៃនៅទីផ្សារមាន ការប្រែប្រួល<br>-បញ្ហាជំងឺលើដំណាំ<br>-បញ្ហាដីខ្វះជីវជាតិ<br>-បញ្ហាខ្វះបច្ចេកទេសកសិកម្ម | -ពង្រីកប្រព័ន្ធស្រោចស្រព<br>-ពង្រីកផ្ទៃដីដាំដុះលើដំណាំ ស្វាយ ចន្ទីរ ដំណាំដំឡូងមី<br>-បើវគ្គបណ្តុះបណ្តាលលើដំណាំ ឈើហូបផ្លែ<br>-បើវគ្គបណ្តុះបណ្តាលលើដំណាំ បន្លែ<br>-បើកវគ្គបណ្តុះបណ្តាលលើដំណាំ<br>-បោកវគ្គបណ្តុះបណ្តាលការ ប្រើប្រាស់ថ្នាំកសិកម្មសមស្រប |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំទ្រា ខែមិថុនា ឆ្នាំ២០១៨*

## ១.៣.៣.ធនធានធម្មជាតិ

### ក. ធនធានព្រៃឈើ

បច្ចុប្បន្ននៅក្នុងឃុំទ្រា មានព្រៃល្បោះដែលតំបន់ព្រៃឈើសហគមន៍ចំនួន៣កន្លែងផ្សេងគ្នា មានផ្ទៃដីទំហំ ២៨០ហិកតា ដែលស្ថិតនៅក្នុងភូមិទំពេជ ហើយត្រូវបានគ្រប់គ្រង និងថែទាំដោយសហគមន៍មូលដ្ឋាន និងអាជ្ញាធរដែនដីភូមិឃុំ(ជាដីកម្មសិទ្ធិរបស់រដ្ឋ) និងព្រៃជាមួយដីស្រែ និងព្រៃជាមួយចម្ការ មានទំហំ ១៤១៤,៤៥ហិកតា ដែលមានមុខងារការពារឱ្យមានស្ថេរភាពទៅលើបរិស្ថានធម្មជាតិដូចជាចរន្តទឹកភ្លៀង ខ្យល់អាកាស សីតុណ្ហភាព ជាដើម ។ល។ ព្រមទាំងបង្កើតនូវលក្ខខណ្ឌជីវៈចម្រុះប្រកបដោយនិរន្តរភាព និងផលិតកម្មកសិកម្ម ដែលសម្បូរទៅដោយប្រភេទឈើផ្សេងៗ ដូចជា ៖ ខ្លងត្បែង ធ្នឹក សុក្រំ ធ្នង ឈើទៀល តាអុង ស្មាច់ ព្រីង កកោះ ផ្ចឹក ត្រសេក ធ្លក ដង្កៀបក្តាម និងមានប្រភេទសត្វព្រៃមួយចំនួនដូចជា៖ ទន្សាយ ជ្រូកព្រៃ ពស់ អណ្តើក ប្រវឹក កណ្តុរ ជាដើម។ល។ ប្រភេទអនុផលព្រៃឈើមានដូចជា៖ ឃ្មុំ ផ្សិត អង្ក្រង ស្លឹកលៀង ល្ពាក់ ផ្តៅ គមផ្តៅ ផ្លែឈើព្រៃ ឧស ធ្យូង ស្បូវ និងជាជម្រកសត្វស្លាបផងដែរ (សត្វខ្សឹប) ។

តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
| --- | --- |
| - មានការកាប់ឈើសម្រាប់ធ្វើជាឱសដុត និងប្រើប្រាស់ផ្សេងៗ<br>- ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីផលប្រយោជន៍ នៃដើមឈើនៅមានកម្រិត<br>- ការអនុវត្តច្បាប់ព្រៃឈើនូវទាន់បានពេញលេញ<br>- ការផ្សព្វផ្សាយច្បាប់ពុំទាន់បានទូលំទូលាយនៅឡើយ | - មានច្បាប់ស្តីពីព្រៃឈើដែលបានកំណត់ករណីយកិច្ចរបស់ប្រជាពលរដ្ឋក្នុងការចូលរួមដាំដើមឈើ<br>- មានការលើកទឹកចិត្តពីរាជរដ្ឋាភិបាលដល់ការចូលរួមដាំដើមឈើរបស់ប្រជាពលរដ្ឋ<br>- មានការផ្តល់នូវជំនួយបច្ចេកទេសដាំដើមឈើពី រដ្ឋបាលព្រៃឈើ។<br>- មានដីតាមដងផ្លូវសាធារណៈប្រព័ន្ធប្រឡាយ សាលារៀន មណ្ឌលសុខភាព វត្តអារាម តាមភូមិ ដែលអាចដាំដើមឈើបាន ។ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំទ្រា ខែមិថុនា ឆ្នាំ២០១៨*

### ខ. ធនធានជលផល

បច្ចុប្បន្ននៅក្នុងឃុំទ្រា មានស្ទឹងស្ទោង ដែលមានផ្ទៃដីទំហំ ៦៧,១៥ហិកតា និងស្រះទឹក មានផ្ទៃដីទំហំ ២៩,៧៥ហិកតា ដែលស្ថិតនៅរាយប៉ាយក្នុងឃុំ។ ស្ទឹង និងស្រះទឹកទាំងអស់នេះ មានធនធានជលផលជាច្រើនប្រភេទដូចជា៖ ក្តាម ខ្យង ត្រីរ៉ស់ ត្រីឆ្តោរ ត្រីទក់ ត្រីក្រាញ់ ត្រីអណ្តែង ត្រីឆ្លូញ ត្រីចង្វា។ល។ ហើយការនេសាទរបស់ប្រជាពលរដ្ឋនៅក្នុងឃុំនេះ ទទួលបានផលច្រើនគួរសម ដែលពួកគាត់អាចយកទៅលក់ដូរខ្លះ និងទុកហូបចុកខ្លួនឯងខ្លះ ដោយប្រើប្រាស់ឧបករណ៍ដូចជា សំណាញ់ មង ទ្រូ អួន និងសន្ទូចជាលក្ខណៈប្រពៃណីក្នុងនោះក៏មាន ប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ខ្លះដែរ ។

តារាង 27៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
| --- | --- |
| - មានការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតមិនសមស្រប នាំឱ្យមានការថយចុះបរិមាណត្រីស្រែ<br>- ការនេសាទខុសច្បាប់។ | - មានដីស្រែធំទូលាយអំណោយផលដល់ធនធានជលផល<br>- មានប្រព័ន្ធប្រឡាយអំណោយផលដល់ធនធានជលផល<br>- មានការគាំទ្រ និងផ្សព្វផ្សាយអំពីវារីវប្បកម្មពីក្រសួងកសិកម្មជូនដល់កសិករ។ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំទ្រា ខែមិថុនា ឆ្នាំ២០១៨*

រូបភាព 14៖ ផលនេសាទនៅក្នុងឃុំទ្រា



### ១.៣.៤.ធនធានរ៉ែ

ធនធានខ្សាច់នៅក្នុងឃុំទ្រា គឺស្ថិតនៅតាមមាត់ស្ទឹងស្ទោង។ ទីតាំងទាំងនេះមានការចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មដោយពីមន្ទីរ ឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបានដឹកចេញ និងយកទៅធ្វើអាជីវកម្ម និង សំណង់ផ្សេងៗ ។ ឃុំ និងប្រជាពលរដ្ឋពុំបានទទួលផលប្រយោជន៍អ្វីពីធនធានរ៉ែនេះទេ ។ ការធ្វើអាជីវកម្មខ្សាច់នេះមានផលប៉ះពាល់ដូចជា៖ បាក់ច្រាំងស្ទឹង ដីហុយនៅពេលដឹកជញ្ជូន ធ្វើឱ្យខូចផ្លូវជាដើម ។ ក្រៅពីរ៉ែខ្សាច់ ឃុំទ្រា មិនមានធនធានរ៉ែផ្សេងៗទៀតឡើយ ។

## ១.៤. ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១.ទីផ្សារ និងតម្លៃកសិផល ផល-អនុផលព្រៃឈើ និងផលនេសាទ

បច្ចុប្បន្ននៅក្នុងឃុំទ្រា មានតែផលិតផលស្រូវ និង ស្វាយចន្ទី ដែលអាចនាំចេញទៅរកទីផ្សារ ហើយ ផលិតផលស្រូវ ដែលនៅសល់ពីការហូបចុក អាចនាំទៅរកទីផ្សារមានប្រភេទ សែនក្រអូប ស្រូវ៤៩ ស្រូវរាំងជ័យ និងស្រូវផ្ការំដួល ដោយឡែកផលិតផលដំណាំស្វាយចន្ទី គឺត្រូវបាននាំទៅរកទីផ្សារទាំងអស់ ។ បើយោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំទ្រា ឆ្នាំ២០១៧ បានឱ្យដឹងថាប្រភេទស្រូវស្រូវផ្ការំដួល ដោយចាប់ផ្តើមពីការត្រៀមពូជស្រូវ ដែលភាគច្រើនបានរក្សាទុកដោយខ្លួនឯង ៥0ភាគរយ និងមានការទិញចូល ៥0ភាគរយ ហើយមានការរៀបចំដីរួមទាំងការថែទាំ មានការដាក់ជី និងបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតដល់ ច្រូតកាត់ ដោយប្រើប្រាស់គ្រឿងយន្តរហូតទៅដល់៩៥ភាគរយ និងច្រូតកាត់ដោយដៃតែ៥%ប៉ុណ្ណោះ ។ ទិន្នផលស្រូវដែលទទួលបាន ត្រូវហាលសម្ងួតទុកពូជ ១0ភាគរយ និងទុកផ្គត់ផ្គង់ការហូបចុកប្រមាណ 00ភាគរយ ចំណែកផលស្រូវនៅសើម ដែលសល់ប្រមាណ៩0ភាគរយបានយកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំបានតម្លៃ១000-១0៥0រៀលក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តលក់ឱ្យរោងម៉ាស៊ីនកិនស្រូវយកទៅកិនកែច្នៃជាអង្ករនាំទៅទីផ្សារក្នុងប្រទេស និងទីផ្សារក្រៅប្រទេស ។ ចំណែកផលិតផលស្វាយចន្ទី តាមការសាកសួរក្រុមប្រឹក្សាឃុំបានឱ្យដឹងថាមានឈ្មួញមកទិញដល់ឃុំ និងបន្តដឹកទៅលក់នៅប្រទេសវៀតណាម មានតម្លៃចាប់ពី ៣ ៥00រៀលទៅ៦ ៥00រៀលនៅក្នុងមួយគីឡូក្រាម ។

តារាង 28៖ ស្ថិតិផលិតផលស្រូវ និងតម្លៃ

| ល.រ | ប្រភេទផលិតផលស្រូវ | ឯកតា | តម្លៃជារៀល | តម្លៃជារៀលទីផ្សារ | |
|---|---|---|---|---|---|
| | | | | ក្នុងស្រុក | ក្រៅប្រទេស |
| ១ | សែនក្រអូប | ១គីឡូ | ៩០០-១ ០០០ | | វៀតណាម |
| ២ | ស្រូវ៤៩ | ១គីឡូ | ៨០០-៩០០ | | វៀតណាម |
| ៣ | ស្រូវរាំងជ័យ | ១គីឡូ | ៨៥០-១ ០០០ | | វៀតណាម |
| ៤ | ផ្ការំដួល ម្លិះ | ១គីឡូ | ១ ០០០-១ ២០០ | | វៀតណាម |

ប្រភពទិន្នន័យ៖ *ក្រុមប្រឹក្សាឃុំទ្រា ខែមិថុនា ឆ្នាំ២០១៨*

### ១.៤.២.ខ្សែសង្វាក់ និងចរាចរផលិតផល

តាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកសិត្រ-បរិស្ថានឃុំទ្រា ឆ្នាំ ២០១៧ បានឱ្យដឹងថា បច្ចុប្បន្ននៅក្នុងឃុំទ្រា ការផលិតដំណាំស្រូវរហូតដល់បានផលលក់ចេញ គឺត្រូវដំណើរការតាមខ្សែសង្វាក់ជាបន្តបន្ទាប់ ដូចជាការផលិតដំណាំស្រូវផ្ការំដួល ដោយចាប់ផ្តើមពីការត្រៀមពូជស្រូវ ដែលភាគច្រើនបានរក្សាទុកដោយខ្លួនឯង ៥០ភាគរយ និងមានការទិញចូល ៥០ភាគរយ ហើយមានការរៀបចំដីរួមទាំងការថែទាំ មានការដាក់ជី និងបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតដល់ច្រូតកាត់ ដោយប្រើប្រាស់គ្រឿងយន្តរហូតទៅដល់៩៥ភាគរយ និងច្រូតកាត់ដោយដៃតែ៥%ប៉ុណ្ណោះ ។ ទិន្នផលស្រូវដែលទទួលបាន ត្រូវហាលសម្ងួតទុកពូជ ១០ភាគរយ និងទុកផ្គត់ផ្គង់ការហូបចុកប្រមាណ ០០ភាគរយ ចំណែកផលស្រូវនៅសើម ដែលសល់ប្រមាណ៩០ភាគរយ បានយកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំបានតម្លៃ១ ០០០-១ ០៥០ រៀលក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តលក់ឱ្យរោងម៉ាស៊ីនកិនស្រូវយកទៅកិនកែច្នៃជាអង្ករនាំទៅទីផ្សារក្នុងប្រទេស និងទីផ្សារក្រៅប្រទេស ។

ក្រៅពីផលិតផលស្រូវ ក្នុងឃុំទ្រា នៅមានផលិតផលស្វាយចន្ទីថែមទៀត ដែលបច្ចុប្បន្នដំណាំនេះមានដើមលូតលាស់ធំៗ និងកំពុងផ្តល់ផលជាបណ្តើរៗហើយ បើតាមការសាកសួរប្រជាពលរដ្ឋនៅក្នុងឃុំ បានឱ្យដឹងថាពួកគាត់កំពុងថែទាំ ដោយការដាក់ជីបាញ់ថ្នាំសម្លាប់សត្វល្អិតបំផ្លាញដំណាំធ្វើដី និងបេះផ្លែជាដើម ។ ការប្រមូលផល ស្វាយចន្ទីក្នុងមួយឆ្នាំបាន ២ដង គឺនៅដើមរដូវ និងចុងរដូវ ហើយផលិតផលត្រូវបានលក់ឱ្យឈ្មួញកណ្តាលដែលមកទិញដល់ដល់ចម្ការ និងខ្លះទិញតាមផ្ទះ ក្នុងតម្លៃចាប់ពី ៣ ៥០០រៀលដល់ ៦ ៥០០រៀលក្នុង១គីឡូក្រាម ហើយឈ្មួញបន្តលក់ទៅទីផ្សារទីរួមខេត្តកំពង់ធំ ព្រមទាំងលក់បន្តទៅ ប្រទេសវៀតណាម ។

រូបភាព 15៖ ផលិតផលកសិកម្ម



ផលិតផលស្រូវ



ផលិតផលស្វាយចន្ទី

### ដ្យាក្រាម 4៖ គំនូសតាងនៃការលំហូផលិតផលកសិកម្ម នៅក្នុងភូមិ និងការប្រើប្រាស់



## ១.៤.៣.ឧបសគ្គ និងឱកាស

តារាង 29៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - ឈ្មួញជាអ្នកកំណត់តម្លៃស្រូវ<br>- ឈ្មួញកណ្តាលយកជី ថ្នាំ និងប្រេងមកបណ្តាក់ដោយគិតការប្រាក់ខ្ពស់រហូតដល់២%ក្នុងមួយខែ ហើយទូទាត់នៅពេលប្រមូលផល<br>- កសិករប្រើពូជទុកខ្លួនឯងច្រើនជំនាន់<br>- ធាតុចូលកសិកម្មថ្លៃខ្ពស់<br>- តម្លៃស្រូវមិនទៀងទាត់(អាស្រ័យលើឈ្មួញ)<br>- ប្រើប្រាស់ពូជស្រូវវៀតណាម | - មានឈ្មួញមកទិញដល់កន្លែង<br>- មានសេវាកម្មជួលគ្រឿងយន្តកសិកម្ម(ភ្ជួររាស់ ច្រូតកាត់)<br>- មានភាពងាយស្រួលក្នុងការដឹកជញ្ជូនផលិតផលស្រូវ<br>- អាចប្រកួតប្រជែងតម្លៃជាមួយប្រទេសជិតខាង<br>- គុណភាពស្រូវស្របតាមស្តង់ដាសម្រាប់ការនាំចេញ<br>- តម្លៃអង្ករកើនឡើង និងទៀងទាត់<br>- ពូជស្រូវមានទិន្នផលខ្ពស់ និងតម្លៃខ្ពស់<br>- កែច្នៃចេញជាផលិតផលសម្រេច |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំទ្រា ខែមិថុនា ឆ្នាំ២០១៧*

# ជំពូក ២៖ ការវិភាគ តម្រូវការ សក្ដានុពល និងឧបសគ្គសម្រាប់អនាគត

## ២.១. តម្រូវការសម្រាប់អនាគត

### ២.១.១.ផែនការអភិវឌ្ឍន៍ឃុំ

ក. ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ (២០១៧-២០២២)

ផែនការអភិវឌ្ឍន៍ឃុំ ០៥ឆ្នាំ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា តម្រូវការជាអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងឃុំយ៉ាងមានប្រសិទ្ធិភាពតាមរយៈការរៀបចំឱ្យមានតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំមួយ មានរយៈពេលប្រាំឆ្នាំសម្រាប់អណត្តិក្រុមប្រឹក្សាឃុំ ។ តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំនេះ បានរំលេចនូវចក្ខុវិស័យអភិវឌ្ឍន៍ដែលជាទស្សនៈរបស់ក្រុមប្រឹក្សាចង់បាន ការប្រែប្រួលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្លួនឱ្យបាន ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ហើយដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ក៏បានរំលេចឱ្យឃើញពីគោលបំណងអភិវឌ្ឍន៍ ដែលជាលទ្ធផលរួមរបស់ក្រុមប្រឹក្សាចង់បាន ព្រមទាំងគោលដៅអភិវឌ្ឍន៍ដែលជាលទ្ធផលនានារបស់ក្រុមប្រឹក្សាចង់បានតាមវិស័យនីមួយៗ ទន្ទឹមនេះក៏បានរំលេចឱ្យឃើញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលជាការកំណត់នូវវិធីសាស្ត្រ ឬសកម្មភាពត្រូវអនុវត្តដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍នីមួយៗខាងលើ ។

ចំណែកឃុំទ្រា ក្រុមប្រឹក្សាឃុំក្នុងអណត្តិ ២០១៨-២០២២ ក៏បានរៀបចំឱ្យមានផែនការអភិវឌ្ឍន៍ឃុំរយៈពេលប្រាំឆ្នាំរបស់ខ្លួន ដែលក្នុងនោះបានលើកឡើងពីគម្រោងវិនិយោគរយៈពេលប្រាំឆ្នាំទៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍឃុំដូចមានខ្លឹមសារដែលក្រុមការងារបានដកស្រង់ក្នុងតារាងខាងក្រោម៖

តារាង 30៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងជម្រើសនៃការប្រើប្រាស់ដីធ្លីអនាគត

| កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និង យុទ្ធសាស្ត្រ | | | | | |
|---|---|---|---|---|---|
| តម្រូវការនៃការអភិវឌ្ឍន៍ន៍ | ប្រភពឯកសារ | គោលដៅនៃ ការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ | សកម្មភាពជា អាទិភាព | លេខរៀងនៅលើផែនទី |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១.ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូនល្អប្រសើរ | -សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៨-២០២២ | -ប្រជាពលរដ្ឋក្នុងឃុំមានផ្លូវធ្វើដំណើរស្រួល ចាប់ពីឆ្នាំ ២០១៨ | -កែលម្អជួសជុលផ្លូវ និងដាក់លូបង្ហូរទឹក<br>-សាងសង់ផ្លូវថ្មីបន្ថែម | -កសាងផ្លូវកៅស៊ូ<br>-កសាងផ្លូវបេតុង<br>-កសាងផ្លូវគ្រួសក្រហម<br>-ជួសជុលផ្លូវក្រាលគ្រួសក្រហម<br>-ជួសជុលផ្លូវលំដីស<br>-ដាក់លូអមផ្លូវ<br>-ពង្រឹងការគ្រប់គ្រងថែទាំជាប្រចាំ<br>-គ្រប់គ្រងចំណីផ្លូវ<br>-ដាក់បង្គោលនិងផ្លាកសញ្ញាចរាចរណ៍ | |
| ២.មានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ | -សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៨-២០២២ | -ប្រជាពលរដ្ឋមានប្រព័ន្ធស្រោចស្រពគ្រាប់គ្រាន់ | -ស្តារនិងជួសជុលប្រព័ន្ធធារាសាស្ត្រចាស់ៗឡើងវិញ<br>-សាងសង់ប្រព័ន្ធធារាសាស្ត្រថ្មីបន្ថែមទៀត | -ជីកប្រឡាយស្រោចស្រព<br>-សាងសង់ទ្វារទឹក<br>-សាងសង់ទំនប់បង្ងៀរទឹក<br>-ជួសជុលទំនប់ទឹក<br>-ជួសជុលទ្វារទឹក | |

| | | | | | |
|---|---|---|---|---|---|
| | | | | -ស្តារប្រឡាយស្រោចស្រព<br>-សាងសង់ស្ថានីយ៍បូមទឹក<br>-បង្កើតសហគមន៍កសិករប្រើប្រាស់ទឹក<br>-ផ្តល់ម៉ាស៊ីនបូមទឹក<br>-បង្កើតគណៈកម្មការគ្រប់គ្រងធារាសាស្ត្រ | |
| ៣.កម្រិតអប់រំមានគ្រប់កម្រិត និងសិស្សបានចូលរៀនគ្រប់គ្នានៅក្នុងឃុំ | -សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៨-២០២២ | -បង្កើនការចូលរៀនកុមារអាយុ ៣-៤ ឆ្នាំឱ្យបាន ៩០% នៅឆ្នាំ ២០១៨<br>-កុមារអាយុ ៦-១៤ឆ្នាំបានរៀនបញ្ចប់នូវកម្រិតមូលដ្ឋានថ្នាក់ទី ០៩<br>-ចំនួនអនក្ខរជននឹងថយចុះ | -ពង្រឹងនិងពង្រីកផ្នែកមត្តេយ្យសាលាឱ្យបានគ្រប់មូលដ្ឋានភូមិ<br>-ជម្រុញការយល់ដឹងដល់ឳពុកម្តាយកុមារពីតម្លៃសិក្សា<br>-ពង្រឹងកិច្ចសហការជាមួយមន្ទីរជំនាញ និងអង្គការនានាដើម្បីកាត់បន្ថយអនក្ខរកម្មរបស់ប្រជាពលរដ្ឋ | -បង្កើតសាលារៀនឱ្យគ្រប់កម្រិតសិក្សាស្របតាមភូមិសាស្ត្រជាក់ស្តែង<br>-កែលម្អគុណភាពនៃការបង្រៀននិងរៀនគ្រប់កម្រិតសិក្សា<br>-ផ្សព្វផ្សាយឱ្យឳពុកម្តាយនាំកូនចូលរៀន<br>-ផ្តល់សម្ភារសិក្សាដល់សិស្សក្រីក្រ<br>-ផ្តល់អាហាររូបករណ៍ដល់សិស្សក្រីក្រ<br>-អប់រំកុមារឱ្យយល់ដឹងពីតម្លៃនៃការសិក្សា<br>-បើកថ្នាក់អក្ខរកម្មឱ្យបានគ្រប់ភូមិ | |
| ៤.សុខភាពរបស់ប្រជាជនល្អប្រសើរ | -សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៨-២០២២ | -ធ្វើឱ្យប្រសើរឡើងសុខភាព និងអនាម័យរបស់ប្រជាជនបានល្អ | -បង្កើននិងកែលម្អសេវាសុខភាព និងចំណេះដឹងដល់ភ្នាក់ងារសុខភាពភូមិ | -អប់រំឱ្យមានការធ្វើអនាម័យជាប្រចាំ<br>-ចាក់វ៉ាក់សាំងការពារជម្ងឺ៧មុខ<br>-ផ្តល់ថ្នាំជាតិដែក<br>-សំណើរសុំគ្រូពេទ្យ សម្ភារនិងថ្នាំ<br>-ជួសជុលជីកអណ្តូងទឹកស្អាត<br>-ធ្វើទស្សនៈកិច្ចសិក្សាយកបទពិសោធន៍ពីកន្លែងផ្សេងៗ<br>-បណ្តុះបណ្តាលស្ត្រីមេម៉ាយក្រីក្របង្កើតជាសមាគមន៍ក្រុមចេះជួយខ្លួនឯង<br>-សាងសង់បង្គន់អនាម័យ<br>-អប់រំ និងផ្សព្វផ្សាយអំពីជម្ងឺឆ្លងដូចជា៖ របេង ថ្លើម គ្រុនចាញ់ និងគ្រុណឈាមជាដើម<br>-កម្មវិធីពន្យាកំណើត | |
| ៥.កាត់បន្ថយមរណៈមាតា និងទារកក្រោយពេលសម្រាល | -សាលាឃុំ | -បង្កើនការលុបបំបាត់អត្រាស្លាប់មាតា និងទារកក្រោយសម្រាល | -ពង្រឹង និងពង្រីកការផ្តល់សេវាគាំពារសុខភាពមាតា និងទារក | -ពង្រឹងនិងពង្រីកសេវាសុខភាពសាធារណៈ<br>-អប់រំអំពីសុខភាពបន្តពូជ<br>-ផ្សព្វផ្សាយដល់ស្ត្រីមានផ្ទៃពោះឱ្យទៅសម្រាលកូនដោយពេទ្យឆ្មប<br>-អប់រំការយល់ដឹងពីអាហារូបត្ថម្ភ<br>-អប់រំឱ្យស្ត្រីចេះរបៀបការពារជម្ងឺឆ្លងកាមរោគ និងជម្ងឺអេដស៍<br>-មិនរើសអើង និងគាំទ្រដល់អ្នកកើតមេរោគអេដស៍<br>-ជម្រុញឱ្យស្ត្រីមានផ្ទៃពោះទៅពិនិត្យពោះនៅមណ្ឌលសុខភាព<br>-ជម្រុញឳពុកម្តាយយកកុមារទៅចាក់ថ្នាំការពារជម្ងឺ០៧មុខ | |
| ៦.ឃុំមានបរិស្ថាន និងធនធាន | -សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៨- | -ធ្វើឱ្យប្រសើរឡើងនូវធនធានធម្មជាតិ | -បង្កើនសេវាលើការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | -បង្កើនការដាំដើមឈើឡើងវិញ<br>- ពង្រឹងការអនុវត្តច្បាប់ការគ្រប់គ្រងធនធានជលផល | |

| | | | | | |
|---|---|---|---|---|---|
| ធម្មជាតិស្រស់បំព្រង | ២០២២ | | | -ពង្រឹងការគ្រប់គ្រងឧបករណ៍ខុសច្បាប់<br>-អភិរក្សស្រះជម្រកត្រី<br>-បណ្តុះបណ្តាលច្បាប់ការពារព្រៃសហគមន៍<br>-បណ្តុះបណ្តាលច្បាប់ព្រៃឈើ ជលផល និងបរិស្ថាន<br>-ពង្រឹងការគ្រប់គ្រងកាកសំណល់រឹងរាវ<br>-ចិញ្ចឹមត្រីតាមគ្រួសារតាមគោលការណ៍ធម្មជាតិផ្តល់សម្ភារនិងថវិកាដល់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ | |
| ៧.ធ្វើឱ្យប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខសាន្តនិងសុវត្ថិភាព | -សាលាឃុំ | -ភូមិឃុំមានសន្តិសុខ និងសណ្តាប់ធ្នាប់ និងមានសុវត្ថិភាពល្អ | -ជម្រុញពង្រីកការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព<br>-ប្រជាពលរដ្ឋចូលរួមនិងបង្កើតក្រុមការពារភូមិ ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់ក្នុងភូមិឃុំ | -បង្កើតប៉ុស្តិ៍ស្ម័យការពារតាមភូមិ<br>-បង្កើតក្រុមប្រជាជនការពារតាមភូមិឃុំ<br>-ផ្សព្វផ្សាយច្បាប់ភូមិបាលនិងច្បាប់ផ្សេងៗទៀត<br>-ចុះបញ្ជី អត្រានុកូលដ្ឋានបានគ្រប់ៗគ្នា<br>-ផ្សព្វផ្សាយអប់រំក្រុមក្រុមក្មេងទំនើង<br>-អប់រំអំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន<br>-កាត់បន្ថយល្បែងស៊ីសងគ្រប់ប្រភេទ<br>-បំផុសឱ្យចូលរួមសហការណ៍ជាមួយសមត្ថកិច្ច | |
| ៨.លុបបំបាត់កាត់បន្ថយទំនាស់ដីធ្លី | -សាលាឃុំ | -មានប័ណ្ណកម្មសិទ្ធិគ្រប់គ្រងដីធ្លី និងយល់ច្បាស់ពីសិទ្ធិក្នុងការគ្រប់គ្រង | -ជម្រុញឱ្យប្រជាពរដ្ឋបានយល់ដឹងពីច្បាប់ និងមានកម្មសិទ្ធិដីធ្លីដោយស្របច្បាប់<br>-បង្កើនការគ្រប់គ្រងដីធ្លីឱ្យស្របតាមគោលនយោបាយរបស់រដ្ឋ | -ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋ<br>-ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់ផ្សេងៗ<br>-ជម្រុញឱ្យប្រជាពលរដ្ឋធ្វើរបង និងព្រំដីឱ្យបានច្បាស់លាស់ | |
| ៩ សមភាពនិងសមធម៌ក្នុងការរស់នៅ | -សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៨-២០២២ | -ធ្វើឱ្យប្រសើរឡើងដល់ប្រជាជនគ្រប់រូបរស់នៅប្រកបដោយសមភាព សមធម៌ គោរពគ្នាទៅវិញទៅមក | -បង្កើនការផ្សព្វផ្សាយច្បាប់ និងលើកកម្ពស់មុខរបរ | -ផ្សព្វផ្សាយច្បាប់សិទ្ធិមនុស្ស<br>-ផ្សព្វផ្សាយច្បាប់អំពើហិង្សាក្នុងគ្រួសារ<br>-ផ្សព្វផ្សាយច្បាប់ជួញដូរស្ត្រី និងកុមារ<br>-ពង្រឹងជនបង្គោលជាស្ត្រីតាមភូមិ<br>-ផ្សព្វផ្សាយច្បាប់កេងប្រវ័ញ្ចដល់កម្លាំងពលកម្មស្ត្រី និងកុមារ<br>-បណ្តុះបណ្តាលពីតួនាទីយេនឌ័រ | |
| ១០.ទិន្នផលកសិកម្មកើនឡើង | -សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៨-២០២២ | -ធានាស្បៀងហូបគ្រប់គ្រាន់ | -បង្កើនផលិតកសិកម្ម | -លើកទំនប់<br>-ជីកប្រឡាយ<br>-លូស្ពាក់ទឹក ទ្វារទឹក<br>-ផ្តល់ពូជស្រូវល្អ<br>-ផ្តល់ពូជសត្វ<br>-ធ្វើជីកំប៉ុស<br>-បច្ចេកទេសប្រើប្រាស់ជី<br>-បណ្តុះបណ្តាលចិញ្ចឹមសត្វ<br>-បណ្តុះបណ្តាលឈើហូបផ្លែ<br>-បណ្តុះបណ្តាលការដាំដំណាំ | |
| ១១.មានទឹកស្អាតសម្រាប់គ្រួសារប្រើ | -សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៨- | -ការរស់នៅមានអនាម័យតាមរយៈមានទឹក | -ពង្រីក និងកែលម្អប្រភពផ្គត់ផ្គង់ទឹក | -ជីកអណ្តូងលូ ស្នប់ ស្រះសហគមន៍<br>-ជួសជុលអណ្តូង<br>-បច្ចេកទេសចម្រោះទឹកជម្រុញការគប | |

| | | | | | |
|---|---|---|---|---|---|
| ប្រាស់ | ២០២២ | ស្អាតប្រើប្រាស់ | | ណ្ដាញទឹកស្អាតទូទាំងឃុំ | |
| ១២.ទិន្នផលត្រីកើនឡើង | -សាលាឃុំ | -បង្កើនធនធានជលផល | -ជម្រុញការបង្កើតវារីវប្បកម្ម | -បណ្ដោះបណ្ដាលបច្ចេកទេសចិញ្ចឹមត្រី<br>-ជ្រើសរើសទីតាំង<br>-ផ្ដល់ឥណទាន<br>-ផ្ដល់ពូជត្រី<br>-ផ្សព្វផ្សាយច្បាប់ជលផល<br>-បង្កើនការចិញ្ចឹមត្រីតាមគ្រួសារ<br>-អប់រំ និងផ្សព្វផ្សាយបំរាមនេសាទនៅរដូវត្រីពង | |
| ១៣.គ្រួសារចិញ្ចឹមសត្វកើនឡើង | -សាលាឃុំ | -បង្កើនការចិញ្ចឹមសត្វបន្ថែមទៀត | -ជម្រុញការផ្ដល់បច្ចេកទេសជំនាញកសិកម្ម<br>-ជម្រុញការផ្ដល់បច្ចេកទេសចិញ្ចឹមថែទាំសុខភាពសត្វ និងជ្រើសរើសពូជ | -ចាក់វ៉ាក់សាំងការពារជម្ងឺសត្វឱ្យបានទៀងទាត់<br>-ផ្ដល់ឥណទានសត្វ<br>-ផ្ដល់ឥណទានមានការប្រាក់ទាប | |
| ១៤.ឱ្យមានថាមពលអគ្គិសនីប្រើប្រាស់គ្រប់ផ្ទះ | -សាលាឃុំ | -ទូទាំងឃុំមានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ | -ពង្រឹងកិច្ចសហការជាមួយអង្គភាពជំនាញដើម្បីជម្រុញការផ្គត់ផ្គង់ថាមពលអគ្គិសនី | -រៀបចំបណ្ដាញអគ្គិសនីតាមភូមិ | |

ប្រភពទិន្នន័យ៖ *របាយការណ៍ក្សេត្រ-បរិស្ថាន និងក្រុមប្រឹក្សាឃុំទ្រា ខែសីហា ឆ្នាំ២០១៨*

## ខ. គម្រោងអភិវឌ្ឍន៍ផ្សេងៗទៀតដែលបានអនុម័តរួច

នៅក្នុងឃុំទ្រា បច្ចុប្បន្នមិនមានគម្រោងណាមួយ ដែលត្រូវបានអនុម័តរួច ដើម្បីដំណើរការជួយជំរុញក្នុងការអភិវឌ្ឍន៍ឃុំឡើយ ។

ផែនទី ៦៖ គម្រោងវិនិយោគជាអាទិភាព ឃុំទ្រា



### ២.១.២.ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២

ការព្យាករណ៍ពីកំណើនប្រជាជន ជាចំណុចសំខាន់ណាស់សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំទ្រា ដែលអាចឱ្យយើងដឹងមុននូវចំនួនប្រជាជនក្នុងឃុំក្នុងរយៈពេល១៥ឆ្នាំខាងមុខដ៏វែង អត្រាកំណើនជាមធ្យមរបស់ប្រជាពលរដ្ឋនៅក្នុងឃុំដែលបានបង្ហាញក្នុងជំពូកទី១ បានឱ្យដឹង គឺ៣,៥៣% ដូច្នេះប្រជាពលរដ្ឋក្នុងឃុំនឹងមានការកើនឡើងរហូតដល់ឆ្នាំ ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០១៧ គឺ ១៤ ៨០៦នាក់

-អត្រាកំណើនមធ្យមប្រចាំឆ្នាំៈ ៣,៥៣%

-ចំនួនប្រជាជនកើនឡើងក្នុងរយៈពេល១ឆ្នាំៈ ១៤ ៨០៦នាក់ x ៣,៥៣% = ៥២៣នាក់/ឆ្នាំ

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងបានៈ ៥២៣នាក់/ឆ្នាំ x ១៥ ឆ្នាំ = ៧ ៨៤៥នាក់**

**-ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ខាងមុខមានៈ ១៤ ៨០៦នាក់ + ៧៨៤៥នាក់ = ២២៦៥១នាក់**

ចំណែកចំនួនគ្រួសារក្នុងឃុំ នឹងមានការកើនឡើងនៅក្នុងឆ្នាំ ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០១៧ គឺ ១៤ ៨០៦នាក់

-ចំនួនគ្រួសារសរុបក្នុងឆ្នាំ ២០១៧ គឺ ២ ៨៧៤គ្រួសារ

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារក្នុងឆ្នាំ ២០១៧ គឺៈ

**១៤ ៨០៦នាក់ /២ ៨៧៤គ្រួសារ = ៥នាក់/គ្រួសារ**

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបានៈ

**៧ ៨៤៥នាក់/ ៥នាក់/គ្រួសារ = ១ ៥៦៩គ្រួសារ**

-ដូច្នេះចំនួនគ្រួសារសរុបក្នុងរយៈពេល១៥ឆ្នាំខាងមុខទៀតមានៈ

**២ ៨៧៤គ្រួសារ + ១ ៥៦៩គ្រួសារ = ៤ ៤៤៣គ្រួសារ**

តារាង 31៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ)

| ឆ្នាំ | ចំនួនគ្រួសារ | ចំនួនប្រជាជន(នាក់) | |
|---|---|---|---|
| | | សរុប | ស្រី |
| ២០១៧ | ២ ៨៧៤ | ១៤ ៨០៦ | ៧ ១៧២ |
| ២០២២ | ៣ ៤២៤ | ១៧ ៤១៩ | ៧ ៩៥៩ |
| ២០២៧ | ៣ ៩៧៤ | ២០ ០៣២ | ៨ ៧៤៧ |
| ២០៣២ | ៤ ៤៤៣ | ២២ ៦៥១ | ៩ ៥៣៤ |

**☞ចំណាំ៖**

- ចំណោលប្រជាសាស្ត្រសម្រាប់១៥ឆ្នាំខាងមុខ៖ អត្រាកំណើនមធ្យមប្រចាំឆ្នាំ x ចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន/១០០
- ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើន៖ អត្រាកំណើនប្រជាជនប្រចាំឆ្នាំ x ១៥
- ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ទៀតមាន៖ ចំនួនអត្រាកំណើនប្រជាជន១៥ខាងមុខ+ចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន

តារាង 32៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ)

| ស្ថិតិតាមក្រុមអាយុ | ២០១៧ | | ២០២២ | | ២០២៧ | | ២០៣២ | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អាយុពី០ឆ្នាំ២- | ៨៧៤ | ៤៩០ | ៩៨៥ | ៥៥២ | ១០៩៥ | ៦១៤ | ១២០៦ | ៦៧៦ |
| អាយុពី៣ឆ្នាំ៤- | ៧៣១ | ៣៣២ | ៨៤២ | ៣៩៤ | ៨៤២ | ៤៥៦ | ៨៤២ | ៥១៨ |
| អាយុ៥ឆ្នាំ | ៥០៧ | ១៩៦ | ៥៩៦ | ២៣១ | ៦៨៦ | ២៦៥ | ៧៧៥ | ៣០០ |
| អាយុ៦-១១ឆ្នាំ | ១៧៩០ | ៧៨៥ | ២១០៦ | ៩២៤ | ២៤២២ | ១០៦២ | ២៧៣៨ | ១២០១ |
| អាយុ១២-១៤ឆ្នាំ | ៨៧៧ | ៣៩៥ | ១០៣២ | ៤៦៥ | ១១៨៧ | ៥៣៤ | ១៣៤១ | ៦០៤ |
| អាយុ១៥-១៧ឆ្នាំ | ៩១២ | ៤១៦ | ១០៧៣ | ៤៨៩ | ១២៣៤ | ៥៦៣ | ១៣៩៥ | ៦៣៦ |
| អាយុ១៨-២៤ឆ្នាំ | ១៧៦៧ | ៨៦៥ | ២០៧៩ | ១០១៨ | ២៣៩១ | ១១៧០ | ២៧០២ | ១៣២៣ |
| អាយុ២៥-៦០ឆ្នាំ | ៦២៤៨ | ៣១០៤ | ៧៣៥១ | ៣៦៥២ | ៨៤៥៣ | ៤២០០ | ៩៥៥៦ | ៤៧៤៧ |
| អាយុ៦១ឆ្នាំ | ១១០០ | ៥៨៩ | ១២៩៤ | ៦៩៣ | ១៤៨៨ | ៧៩៧ | ១៦៨២ | ៩០១ |
| ចំនួនប្រជាជនសរុប | ១៤ ៨០៦ | ៧ ១៧២ | ១៧ ៤១៩ | ៨៤៣៨ | ២០០៣២ | ៩ ៧០៣ | ២២ ៦៥១ | ១០ ៩៦៩ |
| ចំនួនគ្រួសារ | ២ ៨៧៤ | | ៣ ៤២៥ | | ៣ ៩៧៧ | | ៤ ៤៤៣ | |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំទ្រា ខែសីហា ឆ្នាំ២០១៨*

## ២.១.៣.តម្រូវការដីធ្លីជាមូលដ្ឋាន

### ក. ដីលំនៅឋាន

ចំពោះដីភូមិសំដៅទៅលើដីសម្រាប់សង់ផ្ទះ និងសម្រាប់សួនដំណាំជុំវិញផ្ទះតាមគ្រួសារ ។ នៅក្នុងឆ្នាំ ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីលំនៅឋានមានទំហំ ២៦០ហិកតា និងមានគ្រួសារសរុបចំនួន ២ ៨៧៤គ្រួសារ ជាស្ថានភាពរស់នៅរបស់ប្រជាជនមានភាពសមស្របមិនមានបញ្ហាពីការខ្វះដីសម្រាប់លំនៅឋានឡើយ លើកលែងតែគ្រួសារមួយចំនួនតូចគឺស្មើចំនួន ២៦៨គ្រួសារប៉ុណ្ណោះ ដែលមិនមានដីសម្រាប់សាងសង់លំនៅឋាន ហើយបច្ចុប្បន្នគ្រួសារទាំងនោះកំពុងរស់នៅលើដីចំណីប្រឡាយជាដីសាធារណៈ និង គ្រួសារមួយចំនួនទៀតកំពុងរស់នៅលើដីកម្មសិទ្ធិរបស់អ្នកដ៏ទៃ (យោងតាមទិន្នន័យក្នុងជំពូកទី១ ត្រង់ចំណុច ១.៣.១ អំពីការកាន់កាប់ និងគ្រប់គ្រងការប្រើប្រាស់ដី) ដែលត្រូវយកចិត្តទុកដាក់ដោះស្រាយជូនតាមរយៈដីសម្បទានដីសង្គមកិច្ចមាននៅទីតាំងក្រៅឃុំតាមការសម្រេចចរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ច

ក្នុងឆ្នាំ២០១៧ ផ្ទៃដីលំនៅឋានជាមធ្យមសម្រាប់មួយគ្រួសារមានចំនួន៖

**២៦០ហិកតា/ ២ ៨៧៤គ្រួសារ = 0,0៩ហិកតា/ គ្រួសារ**

តែបើយោងតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ចចែងតម្រូវឱ្យមានដីលំនៅឋានយ៉ាងច្រើន 0,២៥ហិកតា ក្នុងមួយគ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូន ២៦៨គ្រួសារ ដែលគ្មានដីពិតប្រាកដសម្រាប់លំនៅឋានដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋដែលមាននៅទីតាំងផ្សេងពីឃុំទ្រានេះ។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្មចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងចំនួនៈ៧ ៨៤៥នាក់

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារមានៈ ៥នាក់/គ្រួសារ

-តម្រូវការដីលំនៅឋានក្នុង១គ្រួសារមានចំនួន 0,0៩ហិកតា/ គ្រួសារ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបានៈ

**៧ ៨៤៥នាក់/ ៥នាក់/គ្រួសារ = ១ ៥៦៩គ្រួសារ**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ (២០១៧-២០៣២) ដីលំនៅឋានត្រូវកើនឡើង:**

**១ ៥៦៩គ្រួសារ x 0,0៩ហិកតា/គ្រួសារ = ១៤១,២១ហិកតា**

**-ដូច្នេះរហូតដល់ឆ្នាំ ២០៣២ ដីលំនៅឋាននៅក្នុងឃុំទ្រាត្រូវកើនឡើងដល់:**

**២៦០ហិកតា + ១៤១,២១ហិកតា = ៤០១,២១ហិកតា**

-ចំណែកការដោះស្រាយដីលំនៅឋានជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន២៦៨គ្រួសារតាមរយៈ សម្បទានសង្គមកិច្ចមានចំនួនៈ **២៦៨គ្រួសារ x 0,២៥ ហិកតា/គ្រួសារ = ៦៧ហិកតា**

តារាង 33៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២

| បរិយាយ | ២០១៧ បច្ចុប្បន្ន | អនាគត ២០៣២ | បម្រែបម្រួលតម្រូវការដី |
|---|---|---|---|
| គ្រួសារ | ២ ៨៧៤គ្រួសារ | ៤ ៤៤៣គ្រួសារ | ១ ៥៦៩គ្រួសារ |
| តម្រូវការដីលំនៅឋាន | ២៦០ហិកតា | ៤០១,២១ហិកតា | ១៤១,២១ហិកតា |

ប្រភពទិន្នន័យ៖ *ក្រុមការងារបច្ចេកទេស អេស ប៊ី ខេ*

## ខ. ដីកសិកម្ម

ចំពោះដីកសិកម្មសំដៅទៅលើដីសម្រាប់ធ្វើស្រែ និងដីចំការដំណាំ ។ នៅក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីកសិកម្មមានទំហំ ១០ ៣០០ហិកតា និងមានគ្រួសារសរុបចំនួន ២ ៨៧៤គ្រួសារ អាចធ្វើស្រែផលិតស្រូវបានសល់ពីការហូបចុកខ្លះសម្រាប់ការនាំចេញទៅទីផ្សារដោះស្រាយជីវភាព គឺជាស្ថានភាពដែលប្រជាពលរដ្ឋអាចរស់នៅក្នុងជីវភាពសមរម្យបាន លើកលែងតែគ្រួសារចំនួន ៣៣៧គ្រួសារប៉ុណ្ណោះ ដែលមិនមានដីសម្រាប់ធ្វើកសិកម្មផ្ទាល់ខ្លួន និងមួយចំនួនស៊ីឈ្នួលគេ ។

ដូច្នេះបច្ចុប្បន្នទំហំដីកសិកម្មសម្រាប់មួយគ្រួសារមានចំនួន៖

**១០ ៣០០ហិកតា / ២ ៨៧៤គ្រួសារ = ៣,៥៨ហិកតា/ គ្រួសារ**

បើតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ចចែងតម្រូវឱ្យមានដីកសិកម្មយ៉ាងច្រើន ២ហិកតាក្នុង១គ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូន៣៣៧គ្រួសារ ដែលគ្មានដីពិតប្រាកដសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋដែលមាននៅទីតាំងផ្សេងពីឃុំទ្រា។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្មចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ គ្រួសារកើនឡើងចំនួនៈ ១៥៦៩គ្រួសារ

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ (២០១៧-២០៣២) ដីកសិកម្មត្រូវកើនឡើង:**

**១៥៦៩គ្រួសារ x ៣,៩២ហិកតា/គ្រួសារ = ៦ ១៥០,៤៨ហិកតា**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ (២០១៧-២០៣២) ដីកសិកម្មសរុបមានចំនួនៈ**

**១០ ៣០០ហិកតា + ៦ ១៥០,៤៨ហិកតា = ១៦ ៤៥០,៤៨ហិកតា**

-ចំណែកការដោះស្រាយដីកសិកម្មជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន ៣៣៧ គ្រួសារតាមរយៈ សម្បទានសង្គមកិច្ចមានចំនួនៈ **៣៣៧គ្រួសារ x ២ ហិកតា/គ្រួសារ = ៦៧៤ហិកតា**

តារាង 34៖ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២

| បរិយាយ | ២០១៧ បច្ចុប្បន្ន | អនាគត ២០៣២ | បម្រែបម្រួលតម្រូវការដី |
|---|---|---|---|
| គ្រួសារ | ២ ៨៧៤គ្រួសារ | ៤ ៤៤៣គ្រួសារ | ១ ៥៦៩គ្រួសារ |
| តម្រូវការដីកសិកម្ម | ១០ ៣០០ហិកតា | ១ ៦៤៥០,៤៨ហិកតា | ៦ ១៥០,៤៨ហិកតា |

ប្រភពទិន្នន័យ៖ *ក្រុមការងារបច្ចេកទេស អេស ប៊ី ខេ*

### គ. ដីព្រៃឈើ

ព្រៃឈើផ្តល់នូវផលិតផលនានា ដូចជា ឈើហ៊ុប ឈើគ្រឿងសង្ហារឹម ឈើបង្គោល អុស និងអនុផលនានា មានជ័រ វល្លិ ឱសថ ដែលគាំទ្រដល់ការចិញ្ចឹមជីវិតរបស់ប្រជាជននៅជនបទ តាមរយៈការប្រើប្រាស់ដោយផ្ទាល់ ឬតាមរយៈការលក់ដូរ។ ទន្ទឹមនេះ ព្រៃឈើក៏បានដើរតួយ៉ាងសំខាន់ក្នុងចំណោមតួនាទីដទៃទៀត ដូចជាទាក់ទាញទឹកភ្លៀង បញ្ចុះសីតុណ្ហភាព មានអាកាសធាតុបរិសុទ្ធ (ផ្តល់ខ្យល់អាកាសបរិសុទ្ធ) បញ្ចេញឧស្ម័នអុកស៊ីសែន (ជួយស្រូបយកឧស្ម័នកាបូននិច និងបញ្ចេញឧស្ម័នអុកស៊ីសែនដល់មនុស្ស) ការពារគ្រោះធម្មជាតិ (ជួយទប់ទល់ខ្យល់ព្យុះទឹកជំនន់ជួយការពារការហូរច្រោះដី និងបាក់ដី)ធ្វើឱ្យដីមានជីជាតិ ជាតំបន់ទេសចរធម្មជាតិ។ ចំណែកព្រៃលិចទឹកសាបជា ជម្រកត្រីពង ផ្តល់ជីជាតិដី សម្រាប់ធ្វើកសិកម្ម រក្សាជីវសាស្ត្រចម្រុះ... ។

បច្ចុប្បន្នក្នុងឃុំទ្រាទាំងមូល មានសហគមន៍ព្រៃឈើចំនួន ០៣កន្លែង មានផ្ទៃដីសរុបចំនួន ២៣៩ហិកតា ដែលស្ថិតនៅក្នុភូមិទំពេជ មានផ្ទៃដីចំនួន ២៣៩ហិកតា ក្នុងនោះសហគមន៍ព្រៃឈើ (ព្រៃអណ្តូង)មានចំនួន ២១៩,៦៣ហិកតា សហគមន៍ព្រៃឈើ (ត្រពាំងក្រណាម)មានចំនួន ១៣,៦៦ហិកតា សហគមន៍ព្រៃឈើ (ព្រៃអ្នកតាជ័យ)មានចំនួន ៤៥,០៤ហិកតា ដែលនៅពេលអនាគតឃុំ មិនអាចមានលទ្ធភាពពង្រីកដីបន្ថែម សម្រាប់ព្រៃឈើនោះទេ តែនៅក្នុងឃុំមានលទ្ធភាពក្នុងការដាំដើមឈើបន្ថែមលើដីសាធារណៈផ្សេងៗ ដូចជាតាមដងផ្លូវ ស្ទឹង ប្រឡាយ អាងស្តុកទឹក សាលាឃុំ សាលារៀន មណ្ឌលសុខភាព និងនៅតាមវត្តអារាមជាដើម សម្រាប់ជាម្លប់ ពណ៌បៃតង ធ្វើឱ្យដីមានជីជាតិ ផ្តល់អុកស៊ីសែន ស្រូបឧស្ម័នកាបូនិកជួយដល់សុខភាពប្រជាពលរដ្ឋ ។ល។

### ឃ. ធនធានទឹក

ឃុំទ្រា ជាឃុំមានសក្តានុពលទៅលើផ្នែកកសិកម្ម ដំណាំស្រូវ និងចម្ការដំណាំឧស្សាហកម្ម ដែលនាំឱ្យឃុំទ្រាមានគោលដៅអភិវឌ្ឍន៍រយៈពេលវែងរបស់ខ្លួន ផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវនេះ និងចម្ការដំណាំឧស្សាហកម្មនេះមិនអាចគេចចេញបានឡើយ ។ ដូច្នេះដើម្បីជំរុញវិស័យកសិកម្មដំណាំស្រូវ និងចម្ការ ជាកត្តាចាំបាច់មួយក្នុងចំណោមកត្តាជាច្រើនគឺមានកត្តាទឹកជាកត្តាសំខាន់ ដែលត្រូវយកចិត្តទុកដាក់ដោយ ត្រូវធ្វើយ៉ាងណាឱ្យមានទឹកគ្រប់គ្រាន់សម្រាប់ការស្រោចស្រពបានគ្រប់រដូវកាលទៅលើដីស្រែ និងចម្ការទាំងអស់ ដែលឃុំមានដើម្បីដោះស្រាយទឹកពេលមានគ្រោះរាំងស្ងួត និងធ្វើស្រែបង្កើនរដូវឱ្យទទួលបានផលិតភាពខ្ពស់ជួយផ្គត់ផ្គង់ដល់ការហូបចុក និងជំរុញការនាំចេញ សម្រាប់បង្កើនសេដ្ឋកិច្ចគ្រួសារក៏ដូចសេដ្ឋកិច្ចជាតិ ដើម្បីឆ្លើយតបបានទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ។

ដោយឡែកនៅក្នុងឃុំទ្រា មានស្ទឹង និងស្រះ ដែលមានផ្ទៃដីទំហំ ៩៦,៩ហិកតា ស្មើនឹង ០,៧៨% នៃផ្ទៃដីសរុបឃុំ ។ នៅពេលអនាគតឃុំទ្រា ត្រូវធ្វើការស្តារ និងកែលម្អទៅលើប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ឱ្យបានប្រសើរឡើងវិញដើម្បីមានលទ្ធភាពប្រើប្រាស់ក្នុងការបង្ហូរនាំទឹកស្រោចស្រពទៅលើផ្ទៃដីស្រែនៅរដូវប្រាំងក្នុងឃុំទាំងមូលបានតាមតម្រូវការ និងនៅពេលមានគ្រោះរាំងស្ងួតដែលចេញពីប្រភពទឹកខាងលើនេះ ហើយក៏

អាចជាជម្រកត្រីនាំឱ្យកើនឡើងបរិមាណត្រី បូកផ្សំជាមួយការយកចិត្តទុកដាក់ក្នុងការចិញ្ចឹមត្រីតាមបែបចិញ្ចឹមនៅក្នុងស្រះខ្នាតតូច ស្រះចិញ្ចឹមត្រីតាមគ្រួសារ លាយឡំជាមួយបន្លែចម្រុះ និងកសិដ្ឋានចិញ្ចឹមត្រីនៅក្នុងស្រែ ដែលជាទម្រង់មួយនៃវារីវប្បកម្ម ដែលជាបច្ចេកទេសមួយជួយដើម្បីបង្កើនបរិមាណត្រី ដោយអាចបង្កើនផលិតភាពជលផលនៅតាមវាលស្រែ ហើយមានប្រយោជន៍ក្នុងការប្រើត្រីសម្រាប់ទប់ទល់សត្វល្អិត និងដង្កូវហ្វូងក្នុងស្រែដែលបំផ្លាញផលស្រូវផង ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់បំផុតសម្រាប់ទ្រទ្រង់សុខភាព និងជីវិតរស់នៅអោយមានភាពល្អប្រសើរ ។

## ង. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត

### ង.១. វិស័យអប់រំ

កុមារគ្រប់រូបមានសិទ្ធិរៀនសូត្រ មិនថាពួកគេស្ថិតនៅក្នុងកាលៈទេសៈបែបណានោះឡើយ ។ ការផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ការរៀនសូត្ររបស់កុមារ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឱ្យពួកគេអាចអភិវឌ្ឍន៍ខ្លួនឈានទៅសម្រេចបានសក្តានុពលរបស់ពួកគេ ។ យ៉ាងណាមិញនៅក្នុងឃុំទ្រាទៅអនាគត់ក្នុងរយៈពេល ១៥ឆ្នាំខាងមុខនឹងមានការកើនឡើងនូវចំនួនកុមារ និងមនុស្សវ័យជំទង់ក្នុងវ័យសិក្សា ដូចមានការគណនាក្នុងចណុច ២.១.២ស្តីពីចំណោលប្រជាសាស្ត្រខាងលើ ដែលចាំបាច់ត្រូវគិតគូរដោះស្រាយបន្ទប់រៀនបន្ថែម គ្រប់កម្រិតនៅតាមទីតាំងសាលារៀនដែលមានស្រាប់ក្នុងបច្ចុប្បន្ន ។

❖ **មត្តេយ្យសិក្សា:**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ កុមារមានអាយុពី៣-៥ឆ្នាំ នឹងកើនឡើងចំនួនៈ ១ ៦១៧នាក់

-តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ បានឱ្យដឹងពីការកំណត់សម្រាប់មត្តេយ្យសាលាក្នុងមួយថ្នាក់មានចំណុះកុមារសិក្សារៀនសូត្រ **៥0នាក់**

**-ដូច្នេះក្នុងរយៈពេល ១៥ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់មត្តេយ្យត្រូវការបន្ថែមចំនួនៈ**

**១ ៦១៧នាក់ /៥0 នាក់/បន្ទប់= ៣២បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ**

**៣២បន្ទប់ /៥ បន្ទប់/អគារ= ៦ អគារ**

❖ **បឋមសិក្សា**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ៦-១១ ឆ្នាំនឹងកើនឡើងចំនួនៈ ២ ៧៣៨នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់បឋមសិក្សាត្រូវការបន្ថែមចំនួនៈ**

**២ ៧៣៨នាក់ ៖ ៤៥នាក់/បន្ទប់ = ៦១បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៦ បន្ទប់បន្ថែមចំនួនៈ**

**៦១បន្ទប់ ៖ ៦ បន្ទប់/អគារ = ១០ អគារ**

-តែក្នុងករណីត្រូវរៀន**២វេន**ក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

**១0អគារ/វេន ៖ ២ វេន = ៥អគារ**

❖ **អនុវិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១២-១៤ ឆ្នាំនឹងកើនឡើងចំនួនៈ ១ ៣៤១នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ**

**១ ៣៤១នាក់ ៖ ៤៥នាក់/បន្ទប់ =៣០បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ១២ បន្ទប់បន្ថែមចំនួនៈ**

**៣០បន្ទប់ ៖ ១២បន្ទប់/អគារ =៣អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សារតែចំនួនៈ

**៣ អគារ / វេន ៖ ២ វេន = ២អគារ**

❖ **វិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១៥-១៧ឆ្នាំនឹងកើនឡើងចំនួនៈ ១ ៣៩៥នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ**

**១ ៣៩៥នាក់ ៖ ៤៥នាក់/បន្ទប់ = ៣១បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ១២ បន្ទប់បន្ថែមចំនួនៈ**

**៣១ បន្ទប់ ៖ ១២បន្ទប់/អគារ = ៣អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សារតែចំនួនៈ

**៣អគារ / វេន ៖ ២ វេន = ២អគារ**

តារាង 35៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១៨ ដល់ ឆ្នាំ ២០៣២

| បរិយាយ | បច្ចុប្បន្ន២០១៧ | អនាគត ២០៣២ | បម្រែបម្រួល |
|---|---|---|---|
| **សាលាមត្តេយ្យ** | | | |
| សិស្ស | ០០ នាក់ | ១ ៦១៧នាក់ | ១ ៦១៧នាក់ |
| បន្ទប់ | ៣ បន្ទប់ | ៣២បន្ទប់ | ២៩ បន្ទប់ |
| អគារ | ៣ អគារ | ៦អគារ | ៣ អគារ |
| **សាលាបឋមសិក្សា** | | | |
| សិស្ស | ១ ៨១៥នាក់ | ២ ៧៨៣នាក់ | ៩៦៨នាក់ |
| បន្ទប់ | ៤២បន្ទប់ | ៦១បន្ទប់ | ២១ បន្ទប់ |
| អគារ | ៦ អគារ | ១០ អគារ | ៤ អគារ |
| **អនុវិទ្យាល័យ** | | | |
| សិស្ស | ៦១០នាក់ | ១ ៣៤១នាក់ | ៧៣១នាក់ |
| បន្ទប់ | ១១បន្ទប់ | ៣០បន្ទប់ | ១៩ បន្ទប់ |
| អគារ | ១ អគារ | ៣ អគារ | ២ អគារ |
| **វិទ្យាល័យ** | | | |
| សិស្ស | ៧៥៨នាក់ | ១ ៣៩៥ នាក់ | ៦៣៧នាក់ |
| បន្ទប់ | ១៦ បន្ទប់ | ៣១ បន្ទប់ | ១៥ បន្ទប់ |
| អគារ | ១ អគារ | ៣ អគារ | ២ អគារ |

### ង.២. វិស័យសុខាភិបាល

នៅក្នុងឃុំទ្រា មានមណ្ឌលសុខភាពមួយកន្លែងដែលស្ថិតនៅក្នុងភូមិកោះ ហើយបើផ្អែកទៅតាមកំណើនប្រជាជន ដែលមានការកើនឡើង និងស្ថានភាពភូមិសាស្ត្ររបស់ឃុំទាំងមូល យើងឃើញថាភូមិ ដែលនៅឆ្ងាយពីមណ្ឌលសុខភាពមានចំនួន៥ ភូមិ គឺភូមិទំពេជ ភូមិពពាយ ភូមិកុចទីទុយ ភូមិស្លា និងភូមិក្រសាំង។ ជាយុទ្ធសាស្ត្រក្រុមប្រឹក្សាឃុំអាណត្តិទី៤ ក៏ដូចជាមេភូមិ បានរៀបចំផែនការបង្កើតឱ្យមានប៉ុស្តិ៍សុខភាព១កន្លែង នៅក្នុងភូមិពពាយ សម្រាប់បម្រើឱ្យប្រជាជនរស់នៅក្នុងភូមិពពាយ ភូមិទំពេជ ភូមិកុចទីទុយ ភូមិស្លា និងភូមិក្រាសាំងបន្ថែមទៀតរយៈពេល ១៥ឆ្នាំខាងមុខ ដើម្បីងាយស្រួលផ្តល់ការគាំទ្រសេវាថែទាំ និងព្យាបាលសុខភាពផ្សេងៗរបស់ប្រជាពលរដ្ឋ បានរហ័សទាន់ចិត្ត និងកាត់បន្ថយការចំណាយរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានមកមណ្ឌលសុខភាព ឬពេទ្យបង្អែកស្រុក ។

### ង.៣. អគ្គិសនី

អគ្គិសនី គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ជីវិតរស់នៅរបស់មនុស្សយើង។ អគ្គិសនីផ្តល់ឱ្យយើងនូវសន្តិសុខ សុវត្ថិភាព សុខភាព និងភាពសំបូររុងរឿង ដូចជាជួយដោះស្រាយបញ្ហា និងធ្វើឱ្យកាន់តែប្រសើរឡើងនូវសន្តិសុខ សុវត្ថិភាព ការប្រែប្រួលអាកាសធាតុ ផលិតកម្មស្បៀងអាហារ និងការពង្រឹងសេដ្ឋកិច្ចដោយរួមទាំងការអប់រំ និងកំសាន្តផងដែរ ។

បើយោងទៅតាមទិន្នន័យពីមន្ទីរផែនការឆ្នាំ២០១៧ បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំទ្រាប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីមានចំនួន៣៥,៨%បានតភ្ជាប់បណ្តាញអគ្គិសនីរដ្ឋប្រើប្រាស់ ហើយនៅសល់គ្រួសារប្រមាណ ៧៤% ដែលមិនទាន់បានទទួលសេវាកម្មនេះនៅឡើយ ។ ដូច្នេះនៅពេលអនាគត១៥ឆ្នាំទៅមុខនឹងមានការកើនឡើងចំនួនគ្រួសារថែមទៀត អាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ជាពិសេសក្រុមប្រឹក្សាឃុំកំពង់ស្វាយត្រូវខិតខំយកចិត្តទុកដាក់ក្នុងការដោះស្រាយពង្រីកបណ្តាញអគ្គិសនីតភ្ជាប់ផ្គត់ផ្គង់ឱ្យដល់គ្រប់គ្រួសារបានប្រើប្រាស់ ។

### ង.៤. ទីលានចាក់សំរាម

សំរាម គឺជាកាកសំណល់ដែលគេបានបោះបង់ចោល ហើយវាមានពីរបែប គឺកាកសំណល់រឹងនិងរាវ។ ដូច្នេះសំរាមគឺជាអ្វីដែលបំបែកចេញពីបរិស្ថានយើង និងជាការបង្កើតកន្លែងគរមួយផ្សេងទៀតប្រសិនបើយើងមិនប្រុងប្រយ័ត្ន។ មានគំនរសំរាម នៅពេលមានភ្លៀងធ្លាក់ចុះមក គឺដូចជាការចម្រោះជាតិពុលគ្រប់បែបយ៉ាងឱ្យហូរជ្រាបទៅបំពុលដី បំពុលទឹក និងបំពុលដល់ប្រភពទឹកនៅក្នុងស្រទាប់ដីខាងក្រោម ជាហេតុធ្វើឱ្យទឹកស្អាតក្លាយជាទឹកមិនស្អាត មានលោហៈធ្ងន់ និងជួនកាលមានបាក់តេរីកាចៗ ដែលនៅពេលនោះ មានលេចឡើងនូវជម្ងឺរាតត្បាតផ្សេងៗដោយសារតែការទទួលទានទឹកមិនស្អាត ។

ចំពោះសំរាមនៅក្នុងឃុំទ្រា បច្ចុប្បន្នប្រជាពលរដ្ឋភាគច្រើនបោះចោលសំរាមនៅក្បែរផ្ទះ ខ្លះចោលរាយប៉ាយនៅតាមផ្លូវ ខ្លះដុតចោល ដែលធ្វើឱ្យរងការបំពុលពីផ្សែងដុត និងបាត់បង់សោភ័ណភាពក្នុងភូមិ ឃុំ ។ ដើម្បីអាចគ្រប់គ្រងសំរាមបានឃុំត្រូវរកទីតាំងនៅក្នុងឃុំដែលនៅដាច់ដោយឡែកឆ្ងាយពីភូមិធ្វើទីលានចាក់សំរាមមួយកន្លែង តែក្នុងករណីនៅក្នុងឃុំមិនមានដីសម្រាប់ទីលានចាក់សំរាម ក៏គួរបង្កើតឱ្យមានឡដុតសំរាមនៅក្នុងឃុំនេះផងដែរ ដើម្បីប្រមូលសំរាមដែលមាននៅក្នុងឃុំទៅរក្សាទុកឱ្យបានគត់មត់ ឬត្រូវប្រមូលសំរាមប្លាស្ទីកយកទៅកែច្នៃផលិតឡើងវិញ ចំណែកសំរាមពីផ្ទះបាយ និងស្លឹកឈើផ្សេងពីប្លាស្ទីកអាចកែច្នៃធ្វើជីដូចជាជីកំប៉ុស្តជាដើម ដើម្បីប្រើប្រាស់ក្នុងការបង្កើនគុណភាពដីដាំដុះ។ ជារួមសំខាន់បំផុត ត្រូវលុបបំបាត់សំរាមប្លាស្ទិកឱ្យ

អស់ពីភូមិ ឃុំ ។ នៅក្នុងឃុំទ្រា បានគិតគូរពីទំលានចាក់សំរាមមួយកន្លែងសម្រាប់អនាគត ដែលស្ថិតនៅក្នុងភូមិបុសតាឯក មានផ្ទៃដីទំហំ ៣,១៣ហិកតា សម្រាប់ធ្វើការចាក់សំរាមទាំងអស់ដែលមាននៅក្នុងឃុំចោលទីនោះ ។

ង.៥. ដីកប់ខ្មោច

ជាទូទៅពិធីបូជាសព មានពីរបែបគឺពិធីដុតសព និងកប់សពរក្សាក្នុងដី ដែលពិធីទាំងពីរនេះពីធីកប់សពត្រូវការប្រើប្រាស់ដី ដែលធ្វើឱ្យមានការបាត់បង់ដី សម្រាប់ប្រើប្រាស់បម្រើឱ្យការអភិវឌ្ឍន៍ក្នុងសហគមន៍ដែលមនុស្សរស់នៅ ។ នៅក្នុងឃុំទ្រាបច្ចុប្បន្នក៏មានប្រើពិធីទាំងពីរនេះដែរ ហើយការប្រើប្រាស់ដីនៅក្នុងឃុំទ្រាក៏មានតម្រូវការកាន់តែច្រើនឡើង ដើម្បីបំពេញតម្រូវការស្របនឹងអត្រាមរណៈទៅអនាគត ដែលចាំបាច់អាជ្ញាធរដែនដីពាក់ព័ន្ធជាពិសេសក្រុមប្រឹក្សាឃុំទ្រា ត្រូវខិតខំយកចិត្តទុកដាក់គិតគូរអំពីពិធីបូជាសពនេះ ដែលនឹងកើតឡើងជាបន្តបន្ទាប់ដោយគួរខិតខំលប់បំបាត់ការបញ្ចុះសពដោយកប់ក្នុងដី ហើយជំនួសមកវិញ ដោយការរៀបចំឱ្យមានកន្លែងបូជាសពនៅតាមវត្តអារាម ឬកន្លែងណាផ្សេងដាច់ឆ្ងាយពីភូមិដែលជាជម្រើសល្អបំផុត ។

ង.៦. ស្រះ និងអណ្តូងទឹក

ទឹក ជាផ្នែកមួយនៃធាតុដ៏សំខាន់បំផុតសម្រាប់រាងកាយមនុស្ស ជាពិសេសសម្រាប់សុខភាពដើម្បីធានាបាននូវការរស់រានមានជីវិតរបស់មនុស្ស ។ ទឹកអាចនឹងមាននៅគ្រប់ទីកន្លែង ប៉ុន្តែមិនត្រូវបានយកមកសម្រាប់ការទទួលទានបានទាំងអស់នោះទេគឺត្រូវការទឹកដែលស្អាត។ នៅក្នុងឃុំទ្រាបច្ចុប្បន្នមានការប្រើប្រាស់ទឹកស្អាតសម្រាប់ទទួលទានតាមរយៈការប្រើទឹកស្រះ និងអណ្តូងដូចបានរៀបរាប់ក្នុងជំពូក១នៃរបាយការណ៍នេះ ប៉ុន្តែបានរកឃើញថា ចំនួនស្រះទឹក និងអណ្តូងទាំងអស់នេះ មិនមានបរិមាណគ្រប់គ្រាន់សម្រាប់បំពេញតម្រូវរបស់មនុស្ស និងសត្វចិញ្ចឹមគ្រប់គ្រាន់នារដូវប្រាំងបានឡើយ ។

ដូច្នេះ ដើម្បីឆ្លើយតបទៅនឹងការខ្វះខាតនាពេលបច្ចុប្បន្ន ក៏ដូចជា ឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋក្នុងរយៈពេល១៥ឆ្នាំខាងមុខបាន អាជ្ញាធរដែនដីពាក់ព័ន្ធជាពិសេសក្រុមប្រឹក្សាឃុំទ្រា ត្រូវយកចិត្តទុកដាក់លើកទឹកចិត្តឱ្យប្រជាពលរដ្ឋក្នុងឃុំត្រង់ទឹកភ្លៀងនៅរដូវវស្សា រក្សាទុកក្នុងអាងស្តុកតាមផ្ទះរៀងៗខ្លួនសម្រាប់ទុកដោះស្រាយការប្រើប្រាស់នៅរដូវប្រាំង ដែលបានខ្សត់ទឹកហើយថែមពីលើនេះទៀត ក៏ត្រូវបំផុសឱ្យមានការរៀបចំជីកស្រះទឹកសហគមន៍ផងដែរ ព្រមទាំងជំរុញលើកទឹកចិត្តដល់វិស័យឯកជនឱ្យផលិតទឹកស្អាតតបណ្តាញឱ្យដល់គ្រប់ខ្នងផ្ទះប្រជាពលរដ្ឋបានប្រើប្រាស់គ្រប់ក្រុមគ្រួសារដែលជាជម្រើសដ៏ល្អបំផុត ។

## ២.២.តំបន់រសើប

តំបន់រសើប ជាតំបន់ដែលទាមទារនូវការការពារបន្ថែម និងជាពិសេសដោយផ្អែកលើសារៈសំខាន់ ឬជីវចំរុះនៃបរិស្ថាន បេតិកភ័ណ្ឌវប្បធ៌ម តំលៃខាងផ្លូវចិត្តដែលមានលក្ខណៈដូចជា៖ តំបន់ប្រពៃណីសម្រាប់ជនជាតិដើមភាគតិច ឬក៏មូលហេតុសំខាន់ៗផ្សេងទៀត។ តំបន់បង្ហាញបញ្ហាចោទ ចាំបាច់ត្រូវតែកំណត់ និងធ្វើផែនទីដើម្បីធានាថាឃុំសង្កាត់ត្រូវការដឹងលឺនូវតម្រូវការ និងប្រធានបទពិសេសទាំងនេះ ។

នៅក្នុងឃុំទ្រា តំបន់រសើបមាននៅតំបន់លំនៅឋានប្រជាពលរដ្ឋនៅក្នុងភូមិទំពេជស្ថិតនៅក្នុងតំបន់ការពារសត្វខ្សឹប ដីស្រែរបស់ប្រជាពលរដ្ឋស្ថិតនៅក្នុងតំបន់របៀងអភិរក្សជីវចម្រុះ និងដីស្រែចម្ការរបស់ប្រជាពលរដ្ឋសង្ស័យថាមានមីនមិនទាន់ផ្ទុះ និងតំបន់សហគមន៍ព្រៃឈើ ដែលត្រូវទាមទារនូវកិច្ចការពារ គ្រប់គ្រង និងដោះស្រាយ ជាពិសេស សម្រាប់បំពេញតម្រូវការប្រើប្រាស់អភិវឌ្ឍន៍តាមការចាំបាច់របស់ឃុំ រួមទាំងតំបន់ទួលបុរាណឬស្ថានីយ៍

បុរាណ តំបន់របៀងជីវចម្រុះ តំបន់សហគមន៍ព្រៃឈើ តំបន់ការពារសត្វខ្សឹប ដែលត្រូវទាមទារឱ្យមានការការពារ និងថែរក្សាសម្រាប់ជាប្រយោជន៍រួម និងគោរពទៅតាមច្បាប់ដែលបានកំណត់ ។

ផែនទី 10៖ ផែនទីតំបន់រសើប ឃុំទ្រា



## ២.៣. ការប្រឈម

### ២.៣.១.ការប្រឈមដោយធម្មជាតិ

#### ក. កំណើនប្រជាជន

បច្ចុប្បន្ននៅក្នុងឃុំទ្រា បានរកឃើញថា ប្រជាពលរដ្ឋបានកើនឡើងតាមធម្មជាតិជារៀងរាល់ឆ្នាំ គិតជាមធ្យមប្រចាំឆ្នាំ ៣,៥៣% ហើយទៅថ្ងៃអនាគតត្រឹមឆ្នាំ២០៣២ បញ្ហាកំណើនប្រជាជន ត្រូវបានធ្វើការគិតគូរដោះស្រាយដោយពុំមានបញ្ហាប្រឈមធ្ងន់ធ្ងរឡើយ តែបន្តពីនេះទៅមុខវែងឆ្ងាយនឹងអាចកើតមានបញ្ហាប្រឈមដែលត្រូវបន្តដោះស្រាយមួយចំនួនដូចខាងក្រោមៈ

-មានការខ្វះខាតដីលំនៅឋាន ដែលនាំឱ្យមានការដោះស្រាយផលប៉ះពាល់ទៅដល់ដីស្រែ

-មានការខ្វះខាតដីស្រែ ដែលនាំឱ្យពិបាកដោះស្រាយ ដោយនៅក្នុងឃុំពុំមានដីសល់ទំនេរសម្រាប់បំពេញការខ្វះខាតនេះ

-មានការខ្វះខាតដល់ការផ្តល់សេវាអប់រំ ដែលត្រូវដោះស្រាយការសាងសង់សាលារៀន គ្រូបង្រៀន និងសម្ភារៈសិក្សាបន្ថែម

-មានការខ្វះខាតសេវាសុខាភិបាល ដែលត្រូវដោះស្រាយគ្រូពេទ្យ ឧបករណ៍និងសម្ភារៈពេទ្យ និងថ្នាំពេទ្យបន្ថែម

-មានការខ្វះខាតទឹកស្អាត អគ្គិសនី ដែលត្រូវដោះស្រាយផ្គត់ផ្គង់បន្ថែម

#### ខ. គ្រោះធម្មជាតិ ការរេចរិលនៃធម្មជាតិ

បច្ចុប្បន្ននៅក្នុងឃុំទ្រា គេបានកត់សំគាល់ឃើញថា មានជួបប្រទះនូវគ្រោះធម្មជាតិ កើតឡើងស្ទើរតែរៀងរាល់ឆ្នាំ ដូចជាគ្រោះរាំងស្ងួត ទឹកជំនន់ ជាដើម ។ ទន្ទឹមនេះ ដីធ្លីដែលជាធនធានធម្មជាតិកម្រនៅក្នុងឃុំកំពុងស្វាយ ក៏មានភាពរិចរិលទៅៗផងដែរ ដូចជាធ្វើឱ្យដីស្រែរឹង និងខ្សោះជីជាតិ ដោយសារតែការប្រើប្រាស់ជីគីមី និងថ្នាំគីមីសម្លាប់សត្វល្អិតនៅលើដំណាំស្រូវ និងដំណាំដទៃទៀត មិនស្របតាមបទដ្ឋានបច្ចេកទេស ព្រមទាំងមានការថយចុះ និងបាត់បង់ធនធានជលផល ជាពិសេសនោះមច្ឆាជាតិ ដោយការនេសាទខុសច្បាប់ មានដូចជាការប្រើប្រាស់ឧបករណ៍ឆក់ នេសាទនៅរដូវបិទនេសាទជាដើម ។ ទៅថ្ងៃអនាគត ប្រជាពលរដ្ឋនៅក្នុងឃុំនៅតែបន្តជួបប្រទះនូវបញ្ហាប្រឈមទាំងអស់នេះជាដដែល បើសិនជាមិនមានយន្តការ ឬដំណោះស្រាយដើម្បីទប់ទល់ទៅនឹងគ្រោះរាំងស្ងួត ព្រមទាំងមិនមានការកែប្រែឥរិយាបថ នៅក្នុងការប្រើប្រាស់ដីធ្លីសម្រាប់កសិកម្មឱ្យបានសមស្របទេនោះ ។

### ២.៣.២.ការប្រឈមដោយ ការអភិវឌ្ឍន៍ដែលពុំមាននិរន្តរភាព

ជាការពិតណាស់រាល់គម្រោងអភិវឌ្ឍន៍នានា ពាក់ព័ន្ធការប្រើប្រាស់ធនធានធម្មជាតិ ជាពិសេសការប្រើប្រាស់ដីក្នុងទីតាំងភូមិសាស្ត្រណាមួយ តែងនាំមកការរីកចម្រើនជានិច្ច តែផ្ទុយទៅវិញបើគម្រោងអភិវឌ្ឍន៍ទាំងនោះពុំទាន់បានគិតគូរគ្រប់ជ្រុងជ្រោយទៅដល់ទីតាំងភូមិសាស្ត្រនីមួយៗ និងសក្តានុពលនៃធនធានដែលមាន វានឹងនាំមកនូវផលប៉ះពាល់ដល់សេដ្ឋកិច្ច សង្គម និងបរិស្ថាននូវពេលអនាគត ដោយមិនអាចធានាចិរភាពនៃគម្រោងទាំងនោះដល់កូនចៅជំនាន់ក្រោយក្នុងតំបន់នោះបានឡើយដូចជាស្ថានភាពនៅក្នុងឃុំទ្រា ដែលជាឃុំគោលដៅសិក្សារៀបចំផែនការប្រើប្រាស់ដីដូចបានរៀបរាប់ក្នុងជំពូកទី ១នៃរបាយការណ៍នេះបានឱ្យដឹងថា ឃុំទ្រា មាន

ស្ថានភាពភូមិសាស្ត្រជាវាលទំនាបមានធនធានដីអំណោយផលដល់ដំណាំស្រូវ ដែលជាសក្តានុពល ដល់ការអភិវឌ្ឍន៍ដល់ឃុំនេះ ដោយមិនមានការអះអាងណាផ្សេងក្រៅពីនេះនៅឡើយ ។ ដូចនេះឃុំទ្រា គួរជៀសវាងដាច់ខាតនៅគម្រោងអភិវឌ្ឍន៍ទាំងឡាយណា ដែលនាំឱ្យមានផលប៉ះពាល់ដល់ការបាត់បង់ដីស្រែដែលខ្លួនមាន ធ្វើឱ្យឃុំទ្រាមានការថយចុះឱកាសអភិវឌ្ឍន៍ ដូចជា គម្រោងចាក់លុបដីស្រែបង្កកទុកលក់ ឬពុះដីឡូត៍លក់ ដើម្បីកេងផលចំណេញពីឈ្មួញ គម្រោងជីកយកអាចម៍ដីយកលក់ជាដើម លើកលែងតែគម្រោងណាដែលពាក់ព័ន្ធដែលធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធកសិកម្ម ដូចជា កសិដ្ឋានផលិតពូជស្រូវស្រែគម្រូផលិតជី ទុកដាក់គ្រឿងយន្តកសិកម្ម ទន្ទឹមនិងនេះក៏នៅមានគម្រោងអភិវឌ្ឍន៍ដល់ការរស់នៅនិងបរិស្ថាន ដែលគួរជៀសវាងផងដែរ ដូចជា គម្រោងបង្កើតសិប្បកម្ម ឧស្សាហកម្ម ដែលធ្វើឱ្យមានការបង្ហូរទឹកស្អុយ កខ្វក់ជាដើម។ល។ ទន្ទឹមនឹងការប្រឈមដោយការអភិវឌ្ឍន៍នខាងលើដែលត្រូវជៀសវាងក៏នៅមានការប្រឈមទៅនិងអំពើអនាធិបតេយ្យដែលកើតឡើងពីការដោះស្រាយការខ្វះខាតរបស់ប្រជាពលរដ្ឋក្នុងឃុំផងដែរ ដូចជា ការស្នាក់លើដីនៅតាមមាត់ប្រឡាយតាមចិញ្ចើមផ្លូវសាធារណៈ ការទន្ទ្រានដីទួលសាធារណៈ ការទន្ទ្រានដីព្រៃ ធ្វើស្រែបំពានលើប្រឡាយ ការនេសាទខុសច្បាប់ជាដើម ។

## ២.៤. ឱកាស

### ២.៤.១.ដោយអំណោយផលពីធម្មជាតិ

នៅលើលោកយើងនេះ ធម្មជាតិ គឺពិតជាបានផ្តល់នូវធនធានដ៏មានសារសំខាន់សម្រាប់ធ្វើអ្វីៗ គ្រប់យ៉ាងដែល មនុស្សចង់ធ្វើ ដូចជា មនុស្សប្រើប្រាស់ដីនឹងទឹកសម្រាប់ការដាំដំណាំ ឈើធ្វើអុសដុតសម្រាប់ផ្តល់កំដៅ ឬសាងសង់ទីជម្រក ខ្យល់អាកាស ត្បូងថ្ម ប្រេង ឧស្ម័នធម្មជាតិ និងរ៉ែជាវត្ថុធាតុដើមជាច្រើនទៀត ដូចជាដែកទង់ដែង។ល។ សម្រាប់ធ្វើឧបករណ៍ប្រើប្រាស់ផ្សេងៗ ។ ចំណែកនៅក្នុងឃុំទ្រា យើងផ្តោតសំខាន់ទៅធនធានដីដែលមានសក្តានុពលលើសលប់ទៅលើការអភិវឌ្ឍន៍ឃុំ ដូចបានរកឃើញ និងរៀបរាប់នៅក្នុងជំពូកទី១នៃរបាយការណ៍នេះដូចខាងក្រោម៖

- ស្ថានភាពដីជាវាលទំនាប អំណោយផលដល់ការដាំដុះដំណាំស្រូវ
- នៅជិតប្រភពស្ទឹង អូរ អាចមានលទ្ធភាពនាំទឹកមកស្រោចស្រពដំណាំស្រូវនៅពេលជួបប្រទះគ្រោះរាំងស្ងួត និងមានលទ្ធភាពនាំទឹកមកស្រោចស្រពបង្កើនរដូវធ្វើស្រែបានច្រើនដង
- នៅរដូវវស្សាមានភ្លៀងធ្លាក់ច្រើនអាចស្រោចស្រពដំណាំស្រូវបាន
- អាកាសធាតុ ក្តៅ ហើយសើម អំណោយផលដល់ការលូតលាស់របស់រុក្ខជាតិ

### ២.៤.២.ដោយបច្ចេកវិទ្យាថ្មីៗ

ជីវិតរស់នៅ ដែលយើងកំពុងតែទទួលបានប្រសើរឡើងនាពេលបច្ចុប្បន្ននេះ គឺដោយសារតែមានការអភិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យា។បច្ចេកវិទ្យាថ្មីធ្វើឱ្យមានការផ្លាស់ប្តូរបានប្រសើរឡើងនៃជីវិតរស់នៅរបស់យើង ដែលអ្វីៗបច្ចុប្បន្នកាន់តែប្រសើរឡើង និងងាយស្រួលជាងមុន ។ បច្ចេកវិទ្យាថ្មីអាចកាត់បន្ថយបាននូវពេលវេលា និងការចំណាយទៅលើកម្លាំងពលកម្មក្នុងផលិតកម្មនានា ។

បច្ចុប្បន្ន ឃុំទ្រា ដែលមានសក្តានុពលខ្លាំងពឹងផ្អែកទៅលើផលិតកម្មដំណាំស្រូវ ហើយនាពេលអនាគតក៏នៅតែពឹងផ្អែកលើផលិតកម្មដំណាំស្រូវដដែលនោះ នឹងចាំបាច់ត្រូវការបច្ចេកវិទ្យាទំនើបទាន់សម័យសម្រាប់

វិស័យកសិកម្មដំណាំស្រូវ ដើម្បីជួយជំរុញឱ្យមានការកើនឡើងផលិតផលស្រូវ ដោះស្រាយនូវសន្តិសុខស្បៀង និងប្រាក់ចំណូលកាន់តែខ្ពស់ នាំឱ្យជីវភាពរស់របស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើងក្នុងពេលដែលមានកំណើនប្រជាពលរដ្ឋកាន់តែខ្ពស់ ។ តាមរយៈបច្ចេកវិទ្យាថ្មី នឹងនាំឱ្យប្រជាពលរដ្ឋមានឱកាសអាចប្រើប្រាស់គ្រឿងយន្តកសិកម្មទំនើបទាន់សម័យសម្រាប់ការផលិតដំណាំស្រូវដែលរួមមាន ដូចជា៖ ម៉ាស៊ីនភ្ជួររាស់ដី ម៉ាស៊ីនពង្រាបដីស្រែដោយប្រើប្រព័ន្ធឡាស៊ែរ ម៉ាស៊ីនដកស្ទូង ដ្រូនបាញ់ថ្នាំសម្លាប់សត្វល្អិតនិងដាក់ជី ម៉ាស៊ីនច្រូតកាត់និងបោកបែន ព្រមទាំងដឹកជញ្ជូនជាដើម។ល។

២.៤.៣.ដោយគម្រោងវិនិយោគ

សម្រាប់នាពេលអនាគត ឃុំទ្រា ដែលមានសក្តានុពលទៅលើដំណាំស្រូវ នឹងនាំឱ្យមានគម្រោងវិនិយោគដែលភាគច្រើនផ្តោតទៅលើដំណាំស្រូវ ដូចជា គម្រោងបង្កើតកសិដ្ឋានកសិកម្មដើម្បីជំរុញផលិតកម្មដំណាំស្រូវគម្រោងវិនិយោគទៅលើការកែច្នៃផលិតផលស្រូវដើម្បីនាំចេញ ដែលនឹងផ្តល់ការងារបន្ថែមដល់ប្រជាពលរដ្ឋបង្កើនប្រាក់ចំណូលបានកាន់តែខ្ពស់ នាំឱ្យជីវភាពរស់នៅកាន់តែប្រសើរឡើង កាត់បន្ថយបាននូវភាពក្រីក្រស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។

## ២.៥. បញ្ហា មូលហេតុ និងដំណោះស្រាយ

ផ្អែកតាមការរកឃើញនៅក្នុងជំពូកទី១នៃរបាយការណ៍នេះ អាចឱ្យយើងធ្វើការវិភាគ និងចងក្រងបាននូវបញ្ហាដែលកើតមាននៅក្នុងឃុំទ្រា មូលហេតុដែលនាំឱ្យកើតមានបញ្ហា និងដំណោះស្រាយបញ្ហាទាំងអស់នេះ ដោយមានបង្ហាញអំពីទីតាំងដែលកើតមានបញ្ហានៅក្នុងតារាង ព្រមទាំងកំណត់បាននូវទីតាំងបញ្ហានៅក្នុងផែនទីទៀតផងដែរ ដូចមាននៅខាងក្រោមនេះ៖

តារាង 36៖ បញ្ហាប្រឈម និងសក្តានុពល(ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ)

| បញ្ហាប្រឈម | ទីតាំងនៃបញ្ហា | មូលហេតុនៃបញ្ហា | ដំណោះស្រាយ |
|---|---|---|---|
| ១ | ២ | ៣ | ៥ |
| ១.ខ្វះដីលំនៅឋានក្នុងភូមិ(ចំនួន២៦៨គ្រួសារ) | គ្រប់ភូមិ | ក-ចំណូលស្រុក<br>ខ-កំណើនប្រជាជនក្នុងស្រុក(អាពាហ៍ពិពាហ៍)<br>គ-ភាពក្រីក្រ (លក់ដីភូមិដោះបំណុល) | ក.ខ.គ.១-ស្នើសុំដីសម្បទានសង្គមកិច្ច។ |
| ២.កង្វះខាតទីលានទុកដាក់សម្រាមក្នុងឃុំ | របស់ឃុំរួម(គ្រប់ភូមិតែលើកលែងភូមិបុសតាឯក) | ក-គ្មានសណ្តាប់ធ្នាប់ មិនមានទីតាំង សមរម្យ | ក.១-យល់ដឹងពីការបែងចែកសម្រាម (ប្រភេទសម្រាមនីមួយ) |
| | | ខ-កង្វះខាតទីលានចាក់សម្រាម | ខ.១-ជម្រុញឱ្យក្រុមហ៊ុនវិនិយោគ ក្នុងការប្រមូលសម្រាមកែច្នៃ<br>ខ.២-មន្ទីរ ឬក្រសួង ពាក់ព័ន្ធ ដោះស្រាយដីសម្បទានសង្គមកិច្ច។ |

| បញ្ហាប្រឈម | ទីតាំងនៃបញ្ហា | មូលហេតុនៃបញ្ហា | ដំណោះស្រាយ |
|---|---|---|---|
| ៣.គ្រាប់មីន នៅសេសសល់  | ១.ភូមិទំពេជ | ក-ជាកន្លែងសមរភូមិប្រយុទ្ធ | ក.១-ដាក់សញ្ញាសម្គាល់ដីដែលមានមីន និងគ្រាប់មិនទាន់ផ្ទុះ<br>ក.២-ដាក់សំណើរទៅអង្គភាពកំចាត់ មីន ឬអង្គការដើម្បី ជួយអន្តរាគមន៍ |
| ៤.ផ្លូវពិបាកធ្វើដំណើរ ចំពោះ ផ្លូវគ្រួសក្រហម  | ១.ភូមិលាភទង<br>២.ភូមិសោមក្មោក<br>៣.ភូមិវាល<br>៤.ភូមិប្រាំងស<br>៥.ភូមិតាចរ<br>៦.ភូមិបុសតាឯក<br>៧.ភូមិទំពេជ | ក.ផ្លូវខូច | ក.១-ជួសជុលផ្លូវលំក្រាលគ្រួសក្រហម |
| | | ខ.ផ្លូវត្រូវទឹកហូរដាច់ (ទឹកភ្លៀង) | ខ.១-ដាក់លូអមផ្លូវ |
| | | គ.ផ្លូវចាស់ទ្រុឌទ្រោម | គ.១-ក្រាលបេតុង ឬ កៅស៊ូ |
| | | ឃ.គ្មានស្ពានឆ្លង | ឃ.១-ធ្វើស្ពានឆ្លង |
| ៥.ខ្វះដីកសិកម្ម (ដីស្រែវស្សា. ដីស្រែប្រាំង. អាងស្រែប្រាំង. ដីចម្ការ. ដីចំម្ការកៅស៊ូ. ព្រៃជាមួយកសិកម្ម)(ចំនួន ៣៣៧គ្រួសារ) | គ្រប់ភូមិ | ក-លក់សងបំណុល<br>ខ-កំណើនគ្រួសារក្នុងភូមិ<br>គ-គ្មានដីកសិកម្ម | ក.ខ.គ.១-ស្នើសុំដីសម្បទានសង្គមកិច្ច |
| ៦.ខ្វះប្រព័ន្ធស្រោចស្រព | គ្រប់ភូមិ | ក-ខ្វះទឹកនៅរដូវប្រាំង<br>ខ-ខ្វះអាងស្តុកទឹកនៅរដូវប្រាំង<br>គ-ខ្វះប្រព័ន្ធប្រឡាយ | ក.ខ.គ.១- សាងសង់និងជួសជុលប្រព័ន្ធធារាសាស្ត្របន្ថែម |
| ៧.ទិន្នផលស្រូវទាប | គ្រប់ភូមិ | ក-ដីអត់រៀបស្មើ | ក.១-កៀរដីឱ្យស្មើ |
| | | ខ-ដីខ្សោះជីជាតិ<br>គ-កណ្តូល ខ្យងក្រហម សត្វបំផ្លាញ<br>ង-ខ្វះជី | ខ.គ.ង.១-បណ្តុះបណ្តាលការប្រើប្រាស់ជីធម្មជាតិនិងថ្នាំសម្លាប់សត្វល្អិត |
| | | ឃ-មិនសូវថែទាំ<br>ច-ធ្វើស្រែតាមទម្លាប់ចាស់ | ឃ.ច.១-បណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ |
| | | ឆ-ខ្វះពូជស្រូវល្អ | ឆ.១-ផ្តល់ពូជស្រូវដែលមានទិន្នផលខ្ពស់ |
| | | ជ-ខ្វះប្រឡាយបញ្ចេញបញ្ចូលទឹក | ជ.១-ស្តារប្រឡាយនិងធ្វើទ្វារទឹក<br>ជ.២-ធ្វើទ្វារទឹក និងប្រឡាយថ្មី |
| ៨. បាត់បង់ព្រៃឈើ | គ្រប់ភូមិ | ក-កាប់រានធ្វើស្រែ<br>ខ-កាប់រានធ្វើចម្ការ | ក.ខ.១-ផ្សព្វផ្សាយច្បាប់ព្រៃឈើ |

| បញ្ហាប្រឈម | ទីតាំងនៃបញ្ហា | មូលហេតុនៃបញ្ហា | ដំណោះស្រាយ |
|---|---|---|---|
| ៩. បាត់បង់ធនធានជលផល | គ្រប់ភូមិ | ក-ប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ | ក.១-ផ្សព្វផ្សាយច្បាប់ជលផល |
| | | ខ-ខ្វះជម្រកត្រីពង<br>ឃ-នេសាទនៅរដូវត្រីពង | ខ.ឃ.១-អប់រំ និងផ្សព្វផ្សាយបំរាមនេសាទនៅរដូវត្រីពង |
| | | គ-កំណើនអ្នកនេសាទច្រើន | គ.១-បង្កើនការចិញ្ចឹមត្រីតាមគ្រួសារ |

ប្រភពទិន្នន័យៈ *សៀវភៅផែនការអភិវឌ្ឍន៍០៥ឆ្នាំ របាយការណ៍ក្សេត្រ-បរិស្ថា និងក្រុមប្រឹក្សាឃុំទ្រា ខែសីហា ឆ្នាំ២១០៨*


ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ ឃុំទ្រា
ឃុំពពក
ឃុំប្រឡាយ
ឃុំសាមគ្គី
ឃុំដូង
ឃុំកំពង់ចិនជើង
ឃុំកំពង់ចិនត្បូង
ឃុំបន្ទាយស្ទោង
ឃុំសំព្រោជ
ទៅខេត្តសៀមរាប
ផ្លូវជាតិលេខ ៦
ទំពេជ
ពពាយ
កុចនីទួយ
ក្រសាំង
បុសតាឯក
សាមគ្គី
ទ្រា
ព្រាំងស
ផ្ទះរលំ
កោះ
សាលាទេង
សញ្ញាសម្គាល់
ព្រំប្រទល់ និងទីតាំងរដ្ឋបាល
សាលាឃុំ
ភូមិ
ព្រំប្រទល់រដ្ឋបាលឃុំ
ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន
មន្ទីរពេទ្យ មណ្ឌលសុខភាព
វត្ត
សាលារៀន
ស្ពាន
ទ្វារទឹក
ផ្លូវជាតិលេខ ៦
ផ្លូវចាក់កៅស៊ូ
ផ្លូវចាក់បេតុង
ផ្លូវគ្រួសក្រហម ឬក្រាលថ្ម
ផ្លូវដីស ឬផ្លូវរទេះ
ប្រឡាយមេ
ប្រឡាយរង
ប្រឡាយតូច
ប្រភេទប្រើប្រាស់ដីបច្ចុប្បន្ន
ដីលំនៅឋានភូមិ
កន្លែងកប់ខ្មោច
ដីស្រែវស្សា
ដីចម្ការ
ព្រៃជាមួយចម្ការ
ព្រៃជាមួយដីស្រែ
ព្រៃល្បោះ
ព្រៃតាមដងស្ទឹង
ស្ទឹងមានទឹកតាមរដូវ
ស្រះ
តំបន់ និងទីតាំងបញ្ហា
ដីសង្ស័យថាមានមីន
ផ្លូវពិបាកធ្វើដំណើរ
ប្រព័ន្ធកូអរដោនេ
ចំណោលផែនទី : UTM
តំបន់ទី : 48N
ទិន្នន័យយោង : WGS 1984
អេលីបសូអីត : WGS 1984
ប្រភពទិន្នន័យ
-ទីតាំងវិនិយោគ ប្រភពពីផែនការអភិវឌ្ឍឃុំរយៈពេល៥ឆ្នាំនិងអាជ្ញាធរមូលដ្ឋាន
-ទិន្នន័យទីតាំង និងព្រំប្រទល់រដ្ឋបាលប្រភពពីនាយកដ្ឋានភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២០១៥)
-ទិន្នន័យសំខាន់ៗផ្សេងទៀត ប្រភពពីមន្ទីរ/ស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត
បញ្ជាក់
-ព័ត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើងដោយថ្នាក់ជាតិនិងត្រូវបានកែសម្រួលដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន
-ព្រំប្រទល់រដ្ឋបាលទាំងនោះ មិនអាចចាត់ទុកជាផ្លូវការ និងខ្សែបន្ទាត់ព្រំដែននៃផែនទីនេះ ពុំមានតម្លៃជាផ្លូវការអន្តរជាតិឡើយ
-ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ.................................. ឆ្នាំ២០.......
មាត្រដ្ឋាន ១: ៨៥ ០០០
០ ២ ៤
គីឡូម៉ែត្រ
គាំទ្រដោយ
អនុវត្តដោយ
ADB
GAFSP

# ជំពូក ៣៖  ផែនការប្រើប្រាស់ដីអនាគតឆ្នាំ២០១៧-២០៣២

## ៣.១. តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង

### ៣.១.១.តម្រូវការដីទៅតាមប្រភេទ

នៅពេលអនាគតរហូតដល់ឆ្នាំ២០៣២ នៅក្នុងឃុំទ្រានឹងមានការកើនឡើងចំនួនប្រជាជន ៧ ៨៤៥នាក់ ដែលត្រូវនឹងចំនួន ១ ៥៦៩គ្រួសារ និងបច្ចុប្បន្នមានអ្នកគ្មានដីលំនៅឋានពិតប្រាកដចំនួន ២៦៨គ្រួសារ និងអ្នកគ្មានដីកសិកម្មពិតប្រាកដត្រូវដោះស្រាយទៅអនាគតចំនួន ៣៣៧គ្រួសារ ។ ដោយសារកំណើនប្រជាពលរដ្ឋនេះហើយ ដែលតម្រូវឱ្យមានការគិតគូរយកចិត្តទុកដាក់ដល់ការរកដីបន្ថែម សម្រាប់លំនៅឋាន និងដីស្រែជូនដល់ប្រជាពលរដ្ឋដែលមានចំនួនកើនឡើង ដើម្បីធានាឱ្យមាននិរន្តរភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំទ្រា ទៅថ្ងៃអនាគតបន្តពីពេលបច្ចុប្បន្ន ដូចបានរកឃើញនៅក្នុងជំពូក២ខាងលើនៃរបាយការណ៍នេះ ។ តែដោយសារទំហំផ្ទៃដីដែលត្រូវបានប្រើប្រាស់បច្ចុប្បន្ននៅក្នុងឃុំ ពុំមានប្រែប្រួលកើនឡើងស្របគ្នាទៅនឹងកំណើនប្រជាពលរដ្ឋនាពេលអនាគត ដើម្បីដោះស្រាយបានតាមតម្រូវការដីសម្រាប់លំនៅឋាន និងដីស្រែបន្ថែមនោះគឺជាដំណោះស្រាយសមស្របដីសម្រាប់លំនៅឋានត្រូវប្រើប្រាស់ដីភូមិលំនៅឋានដែលមានស្រាប់ ពីព្រោះស្ថានភាពការតាំងលំនៅឋានបច្ចុប្បន្ននេះមិនទាន់មានភាពចង្អៀត ដែលអាចមានលទ្ធភាពទ្រទ្រង់ដល់ការសាងសង់លំនៅឋានបន្ថែមទៀតបានសម្រាប់រយៈពេល១៥ឆ្នាំទៅមុខ ហើយម្យ៉ាងទៀតការតាំងលំនៅឋានមានលក្ខណៈប្រមូលផ្តុំវានឹងផ្តល់ភាពងាយស្រួលដល់ការផ្គត់ផ្គង់ទឹកស្អាត ភ្លើង និងសេវាសង្គមផ្សេងៗទៀតដូចជាសេវាអប់រំ សេវាសុខភាពជាដើម។ល។

ចំពោះដីស្រែមិនត្រឹមតែមិនបានពង្រីកបន្ថែមតាមការគិតគូរខាងលើនោះទេ តែត្រូវទទួលរងការបាត់បង់ខ្លះថែមទៀតសម្រាប់ផ្គត់ផ្គង់ដល់ទីលានចាក់សំរាមរួមក្នុងឃុំជាដំណោះស្រាយគឺ ត្រូវតែគិតគូរពិចារណាដោយយកចិត្តទុកដាក់ តាមរយៈការបង្កើនផលិតភាព គុណភាព និង ពិពិធកម្មកសិកម្មដំណាំស្រូវ ដោយត្រូវធ្វើស្រែបង្កើនរដូវឱ្យបានពី២ទៅ៣ដងក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ស្របទៅតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា ។

### ៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល

នៅពេលអនាគត ធនធានដីនៅក្នុងឃុំទ្រានៅតែរក្សាទំហំក្រឡាផ្ទៃសរុបទំហំ ១២ ៣៥៥,៤៣ហិកតា ហើយមានការប្រើប្រាស់សម្រាប់ លំនៅឋាន(រួមទាំងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន) ដីស្រែ(រួមទាំងប្រព័ន្ធធារាសាស្ត្រនឹងហេដ្ឋារចនាសម្ព័ន្ធ) ដីចម្ការ ដីព្រៃលាយដីស្រែនិងដីព្រៃល្បោះ ដូចកាប្រើប្រាស់ដីបច្ចុប្បន្នដដែលដោយគ្រាន់តែមានការប្រែប្រួលតិចតួចពីដីកសិកម្មទៅជាទីលានចាក់សំរាមរួមក្នុងឃុំ ដើម្បីសម្រួលដល់សោភ័ណ្ឌភាពនិងអនាម័យក្នុងឃុំឱ្យមានរបៀបរាបរយល្អ ចំណែកទំហំផ្ទៃដីតំបន់ប្រើប្រាស់នីមួយៗ ដូចមានរៀបរាប់ក្នុងសេចក្តីអត្ថាធិប្បាយអំពីការបែងចែកដីតាមតម្រូវការប្រើប្រាស់ខាងក្រោមនេះ ។ ជាទូទៅធនធានដីនៅក្នុងឃុំទ្រាមាន សក្តានុពលខ្ពស់សមស្របទៅលើកសិកម្មដំណាំស្រូវ ដោយសារដីនៅក្នុងឃុំមានទីតាំងភូមិសាស្ត្រ អំណោយផលពីធម្មជាតិដូចបានរៀបរាប់នៅក្នុងជំពូកទី២ខាងលើ ។ ដូច្នេះការប្រើប្រាស់ដីនាពេលបច្ចុប្បន្ន និងការសម្រេចចិត្តប្រើប្រាស់ដីទៅថ្ងៃអនាគតនៅក្នុងឃុំ ដែលបានផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវជាចម្បង គឺជាការប្រើប្រាស់បានត្រឹមត្រូវចំសក្តានុពលនៃដី ហើយក៏ជាការគាប់ជួនដែលភាពអំណោយផលពីធនធានដី នៅក្នុងឃុំសមស្របទៅលើវិស័យកសិកម្មដំណាំស្រូវនេះ ក៏ស្របទៅនឹងគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងតួនាទីវិស័យ

កសិកម្ម ក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ជនបទដែលមានចែងក្នុងមុំទី១ ចតុកោណទី៤ នៃយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ដែលជាការផ្តល់ឱកាសដ៏ល្អដល់អាចអភិវឌ្ឍន៍ក្នុងមូលដ្ឋានរបស់ខ្លួន ឱ្យឃុំមានការរីកចម្រើនបានតាមរយៈការជំរុញធ្វើពិពិធកម្មកសិកម្ម ដំណាំស្រូវនៅលើ ផ្ទៃដីកសិកម្មដ៏ធំល្វឹងល្វើយស្ទើរតែពេញដែនដីឃុំទាំងមូល ដើម្បីបង្កើនទិន្នផលស្រូវ ដែលជាដំណាំដ៏មានសារៈសំខាន់ សម្រាប់ជាស្បៀងផ្គត់ផ្គង់ការហូបចុកមិនអាចខ្វះបាន និងការនាំចេញទៅលក់នៅទីផ្សារ ដើម្បីបានចំណូលផ្គត់ផ្គង់តម្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង រួមទាំងចូលរួមក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិតាមរយៈសកម្មភាពធ្វើពាណិជ្ជកម្មនាំអង្ករចេញ របស់រាជរដ្ឋាភិបាល ។

## ៣.២. ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់

### ៣.២.១.ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ

ជាទូទៅការកំណត់តំបន់ប្រើប្រាស់ដីបានផ្តោតសំខាន់លើមុខងារប្រើប្រាស់សម្រាប់ប្រព័ន្ធផ្លូវ កសិកម្ម លំនៅឋាន ពាណិជ្ជកម្ម កំសាន្ត ព្រៃឈើ ។ល។ ទន្ទឹមនឹងនោះ ការប្រើប្រាស់ដីតែងតែមានការផ្លាស់ប្តូរមុខងាររបស់វា តែការផ្លាស់ប្តូរមុខងារប្រើប្រាស់ដីនេះត្រូវតែគិតគូរពិចារណាឱ្យបានហ្មត់ចត់ ដើម្បីធ្វើការសម្រេចចិត្តបានត្រឹមត្រូវ ដោយត្រូវតែប្រាកដថា ដីដែលក្រោយពីបានប្តូរមុខងារប្រើប្រាស់ហើយនោះត្រូវតែមានតម្លៃសេដ្ឋកិច្ច ឬ ផលប្រយោជន៍ខ្ពស់ជាងមុខងារប្រើប្រាស់មុន តាមរយៈការរក្សាជំហរច្បាស់លាស់ក្នុងការបង្កើនធនធានប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព ជាមួយនឹងផលប៉ះពាល់ដ៏តិចតួចបំផុត ចំពោះមនុស្សជំនាន់ក្រោយ ឧទាហរណ៍ ដូចជា ការផ្លាស់ប្តូរពីដីព្រៃឈើរេចរិលទៅជាដីសម្រាប់ធ្វើកសិកម្ម វានឹងនាំឱ្យមានការបាត់បង់បរិមាណដីព្រៃឈើដែលផ្តល់ប្រយោជន៍ច្រើនយ៉ាងដល់សហគមន៍ តែត្រូវបានកើតឡើងជំនួសដោយវាលស្រែសម្រាប់ផលិតកម្មស្រូវដែលជាចំណីអាហារមិនអាចខ្វះបាន ដែលទាំងនេះជាការបង្ហាញឱ្យឃើញអំពីអន្តរអំពើរវាងមុខងារប្រើប្រាស់ដីមួយ ជាមួយមុខងារប្រើប្រាស់ដីមួយផ្សេងទៀតនៅលើទីតាំងដីដដែល ។

យ៉ាងណាមិញក្នុងរយៈពេល ១៥ឆ្នាំ ទៅមុខរហូតដល់ឆ្នាំ២០៣២ ការប្រើប្រាស់ដីនៅក្នុងឃុំទ្រាត្រូវបានធ្វើការគិតគូរយ៉ាងយកចិត្តទុកដាក់ ដើម្បីដោះស្រាយឆ្លើយតបទៅនឹងកំណើនប្រជាជនដូចបានរៀបរាប់ខាងលើ ជាពិសេស គឺការដោះស្រាយក្នុងការបែងចែកការប្រើប្រាស់ដីធ្លី ដើម្បី បំពេញសេចក្តីត្រូវការរបស់ប្រជាជនដោយឈរលើស្មារតីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រើប្រាស់ដីធ្លីនៅក្នុងឃុំ ។ បញ្ហាដែលត្រូវដោះស្រាយខាងលើនេះ យើងសង្កេតឃើញថានៅក្នុងឃុំមានការប្រែប្រួលការប្រើប្រាស់ដីមួយចំនួនដូចខាងក្រោម៖

-**ដីទីលានចាក់សំរាម** ៖ ការរៀបចំដីទីលានចាក់សំរាមសម្រាប់ប្រើប្រាស់បំពេញសេចក្តីត្រូវការចាំបាច់នាពេលអនាគត ត្រូវបានកំណត់យកដីស្រែវស្សា ទំហំ ៣,១៣ហិកតា ដែលនឹងត្រូវប្រែប្រួលថយចុះផ្ទៃដីស្រែវស្សាតិចតួចប៉ុណ្ណោះ នឹងមិននាំឱ្យរងផលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណាំស្រូវឡើយ តែផ្ទុយទៅវិញវាបានផ្តល់នូវទីលានចាក់សំរាមមួយ ដែលផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនលើសលប់ ដែលជាតម្រូវការចាំបាច់មិនអាចខ្វះបានសម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំទ្រា ដើម្បីទទួលបាននូវបរិស្ថានល្អ សោភ័ណភាព និងសុខាមាលភាពក្នុងភូមិ ឃុំ ។

តារាង 37៖ តារាងប្រើប្រាស់ដីនាពេលអនាគតឃុំទ្រា

| ប្រភេទការប្រើប្រាស់ដី | ផ្ទៃដីបច្ចុប្បន្ន (ហិកតា) | ផ្ទៃដី១៥ក្រោយ (ហិកតា) | បម្រែបម្រួល (ហិកតា) |
|---|---|---|---|
| **ក.ដីលំនៅឋាន ភូមិ** | **២៦០** | **២៦០** | **0** |
| -ដីលំនៅដ្ឋាន ភូមិ ក្រៅតំបន់ការពារ | ២១៨,៧៧ | ២១៨,៧៧ | 0 |
| -ដីលំនៅឋានភូមិក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាប(សត្វខ្សឹប)ត្រួតគ្នាគម្របព្រៃឈើឆ្នាំ២០០២ | ៣៣,៩៦ | ៣៣,៩៦ | 0 |
| -ដីលំនៅឋាន ភូមិក្នុងគម្របព្រៃឈើ២០០២ | ៧,២៧ | ៧,២៧ | 0 |
| **ខ.ទីលានចាក់សំរាម** | **0** | **៣,១៣** | **៣,១៣** |
| **គ.កន្លែងកប់ខ្មោច** | **៤,០៨** | **៤,០៨** | **0** |
| **ឃ.ដីស្រែវស្សា** | **៥ ០០០** | **២ ៨៤៦,៨៧** | **-៣,១៣** |
| -ដីស្រែវស្សាក្រៅតំបន់ការពារ | ២ ៨៥០ | ២ ៨៤៦,៨៧ | -៣,១៣ |
| -ដីស្រែវស្សាក្នុងគម្របព្រៃឈើ២០០២ | ១ ៨០០ | ១ ៨០០ | 0 |
| -ដីស្រែវស្សាក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាប(សត្វខ្សឹប)ត្រួតគ្នាគម្របព្រៃឈើឆ្នាំ២០០២ | ៣៥០ | ៣៥០ | 0 |
| **ង.ដីចម្ការ** | **៥ ៣០០** | **៥ ៣០០** | **0** |
| -ដីចម្ការក្នុងតំបន់ការពារសត្វខ្សឹបត្រួតគ្នាគម្របព្រៃឈើឆ្នាំ២០០២ | ២ ១០០ | ២ ១០០ | 0 |
| -ដីចម្ការក្នុងគម្របព្រៃ២០០២ | ៣ ២០០ | ៣ ២០០ | 0 |
| **ច.ព្រៃជាមួយចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២** | **៣៤,៣៨** | **៣៤,៣៨** | **0** |
| **ឆ.ព្រៃជាមួយដីស្រែក្នុងគម្របព្រៃឈើឆ្នាំ២០០២** | **៨៩០** | **៨៩០** | **0** |
| **ជ.ព្រៃជាមួយដីស្រែក្នុងតំបន់ការពារសត្វខ្សឹបត្រួតគ្នាគម្របព្រៃឈើឆ្នាំ២០០២** | **៤៩០** | **៤៩០** | **0** |
| **ឈ.ព្រៃល្បោះ** | **២៨០** | **២៨០** | **0** |
| **ញ.ព្រៃតាមដងស្ទឹង** | **0,០៧** | **0,០៧** | **0** |
| **ដ.ស្ទឹងមានទឹកតាមរដូវ** | **៦៧,១៥** | **៦៧,១៥** | **0** |
| **ឋ.ស្រះ** | **២៩,៧៥** | **២៩,៧៥** | **0** |
| **ផ្ទៃដីឃុំសរុប** | **១២ ៣៥៥,៤៣** | **១២ ៣៥៥,៤៣** | **0** |

តារាង 38៖ តារាងផែនការផ្នែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែងផ្លូវឆ្នាំនេះ(ម) | ប្រវែងផ្លូវ១៥ឆ្នាំក្រោយ(ម) | បម្រែបម្រួល(ម) |
|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ | ១២, ៧២២ | ៣០, ៣៩៩ | ១៧, ៦៧៦ |
| ផ្លូវក្រាលគ្រួសក្រហម | ៤៦, ៧៥២ | ១១១, ៨០៣ | ៦៥, ០៥០ |
| ផ្លូវលំដីស/ផ្លូវរទេះ | ២២៥, ២០១ | ១៤២, ៤៧៤ | ៨២, ៧២៧ |
| ប្រឡាយមេ | ១៥ ៥២១,០២ | ១៥ ៥២១,០២ | 0 |
| ប្រឡាយរង | ២៣ ២៦៧,១៦ | ២៣ ២៦៧,១៦ | 0 |
| ប្រឡាយតូច | ៥៧ ៨០៦,២៣ | ៦៣ ៥៧១,៣៦ | ៥ ៧៦៥,១៣ |

តារាង ៣៩៖ តារាងផែនការផ្អែកសេវាកម្មនាពេលអនាគត

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំ២០១៧ | ចំនួនសម្រាប់១៥ឆ្នាំក្រោយ | បម្រែបម្រួល |
|---|---|---|---|
| សាលាមតេយ្យ | ៣អគារ/៣បន្ទប់ | ៦អគារ/៣២បន្ទប់ | ៣អគារ/២៩បន្ទប់ |
| សាលាបឋមសិក្សា | ៦អគារ/៤២បន្ទប់ | ១០អគារ/៦១បន្ទប់ | ៤អគារ/២១បន្ទប់ |
| សាលាអនុវិទ្យាល័យ | ១អគារ/១១បន្ទប់ | ៣អគារ/៣០បន្ទប់ | ២អគារ/១៩បន្ទប់ |
| សាលាវិទ្យាល័យ | ១អាគារ/១៦បន្ទប់ | ៣អគារ/៣១បន្ទប់ | ២អគារ/១៥បន្ទប់ |
| មណ្ឌលសុខភាព | ០១កន្លែង | ០១កន្លែង | 0កន្លែង |
| ទីលានចាក់សំរាម | 0 | ១កន្លែង | ១កន្លែង |
| ទីតាំងផ្សារ | ១កន្លែង | ១កន្លែង | 0កន្លែង |

### ៣.២.២.ផែនទីប្រើប្រាស់ដីអនាគត

ការកំណត់ការប្រើប្រាស់ដី នាពេលអនាគតនៅក្នុងឃុំ គឺជាការសម្រេចចិត្តមួយដ៏ត្រឹមត្រូវបំផុត ដោយពឹងផ្អែកទាំងស្រុងទៅលើការវិភាគដីសមស្របមួយ តាមរយៈការវាយតម្លៃបែបសាមញ្ញទៅលើធនធានដី រយៈកម្ពស់ ទីជម្រាលធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនេះនាពេលបច្ចុប្បន្ន ដោយយកផែនទីប្រើប្រាស់ដីធ្លីបច្ចុប្បន្នមកធ្វើជាមូលដ្ឋានក្នុងការគិតពិចារណា ដូចមានរំលេចឱ្យឃើញនៅក្នុងតារាងទី៣៧ខាងលើនេះ ដោយមានភ្ជាប់នូវផែនទីប្រើប្រាស់ដីនាពេលអនាគតមួយដូចខាងក្រោម ដែលសមស្របអាចទទួលយកបាន និងអាចប្រើប្រាស់មានប្រសិទ្ធិភាព តាមរយៈការបង្ហាញយ៉ាងពិស្តារពីជម្រើសដ៏ល្អសម្រាប់ការប្រើប្រាស់ដីនាពេលអនាគតរបស់ឃុំនេះ ។ ចំណែកផែនទីប្រើប្រាស់ដីនាពេលអនាគតខាងក្រោម ក៏មានការអត្ថាធិប្បាយលម្អិតទៅលើតំបន់ប្រើប្រាស់ដីនីមួយៗដែលបានកំណត់នៅលើផែនទីនេះផងដែរ ។

ផែនទី 12៖ ផែនទីប្រើប្រាស់ដីអនាគតឃុំទ្រា



### ៣.២.៣.សេចក្តីអត្ថាធិប្បាយ

ផ្អែកតាមផែនទីប្រើប្រាស់ដីអនាគតខាងលើ បានបង្ហាញឱ្យឃើញពីប្រភេទនៃការប្រើប្រាស់ដីនៅក្នុងឃុំទ្រា ដូចខាងក្រោម៖

### ក. ដីលំដីលំនៅឋាន ភូមិ

ដីលំនៅឋាន ភូមិ គឺជាដីត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែ ។ នៅក្នុងឃុំទ្រា ដីលំនៅឋាន ភូមិ មានផ្ទៃដីសរុបចំនួន២៦០ហិកតា ដែលភាគច្រើនស្ថិតនៅខាងកើតផ្លូវជាតិលេខ៦ ក្នុងនោះមានមួយផ្នែកស្ថិតនៅភាគខាងត្បូងនៃឃុំតាមបណ្តោយផ្លូវវៀងស្រុកស្ទោង គឺផ្លូវកៅស៊ូដែលចេញពីផ្លូវជាតិលេខ៦ឆ្ពោះទៅកាន់ឃុំបន្ទាយស្ទោងជាដីលំនៅឋានភូមិ ជាដីលំនៅឋាន ភូមិក្រៅតំបន់ការពារ មានផ្ទៃដីទំហំ ២១៨,៧៧ហិកតា ដែលមានភូមិសាមក្តោក ភូមិទទា ភូមិហប់ ភូមិកោះ ភូមិលាបទង ភូមិផ្ទះវាល ភូមិច្រាំងស ភូមិទ្រា ភូមិតាចរនិងភូមិផ្ទះវាល និងដីលំនៅឋាន ភូមិ ស្ថិតក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាប( សត្វខ្សឹប ) ត្រួតគ្នាក្នុងគម្របព្រៃឆ្នាំ២០០២ មានផ្ទៃដីទំហំ៣៣,៩៦ហិកតា មានភូមិបុសតាឯក និងភូមិពពាយ និងតំបន់មួយទៀតគឺជាដីលំនៅឋានភូមិស្ថិតក្នុងគម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ៧,២៧ហិកតា ស្ថិតនៅតាមបណ្តោយផ្លូវគ្រួសក្រហមដែលចេញពីផ្លូវជាតិលេខ៦ឆ្ពោះទៅភាគខាងជើងឆៀងខាងកើត ដែលដដាច់ពីគេគឺមានភូមិទំពេជ ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំទ្រា នៃរបាយការណ៍វិភាគប្រព័ន្ធគ្សេត្រ-បរិស្ថាន ដីលំនៅឋានភូមិទាំងអស់ ជាតំបន់ជម្រាលទាប និងធម្យម មានប្រភេទដីកណ្តេងលាយល្បាប់( ពណ៌លឿង )និងខ្សាច់លាយកណ្តែង ដែលដីលំនៅឋានភូមិស្ថិតក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាបនិងដីលំនៅឋានភូមិស្ថិតក្នុងគម្របព្រៃឈើឆ្នាំ២០០២ គឺជាដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ត្រូវបានប្រជាពលរដ្ឋកាន់កាប់ប្រើប្រាស់សាងសង់លំនៅឋាន ហើយដីលំនៅឋានភូមិទាំងអស់នេះ មិនត្រូវបានធ្វើការចុះបញ្ជី ជាលក្ខណៈប្រព័ន្ធរួចរាល់នោះទេ ដែលនៅក្នុងបច្ចុប្បន្ននេះបាននឹងកំពុងប្រើប្រាស់ជាដីលំនៅឋាន ភូមិដែរ ដោយពុំមានការពង្រីកបន្ថែមសម្រាប់ ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២នោះឡើយ ដោយសារបច្ចុប្បន្ននេះដីលំនៅឋានភូមិនៅមានភាពទូលាយ ដែលអាចធ្វើការដោះស្រាយសម្រាប់ការសាងសង់លំនៅឋានរហូតដល់ឆ្នាំ២០៣២បាន ។ ដីដែលបានកំណត់ជាដីភូមិនេះ ពឹងផ្អែកលើប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងស្រោចស្រពដំណាំរួមផ្សំជុំវិញលំនៅឋានបានមកពីទឹកភ្លៀង ស្ទឹងស្ទោង អណ្តូងស្នប់និងស្រះ ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ាស៊ីនបូម ម៉ូទ័របូម និងស្នប់សប់ដៃ។ នាពេលអនាគតទីតាំងដីលំនៅឋានភូមិ ដែលមានស្រាប់នាពេលបច្ចុប្បន្ននេះនឹងត្រូវរក្សាទុកជាដីសម្រាប់សាងសង់លំនៅឋានដដែល ដោយសារតែទីតាំងដីនេះមានស្ថានភាពជាដីខ្ពស់មិនលិចទឹកនៅរដូវវស្សា និងនៅជាប់ផ្លូវសំខាន់ៗ ក្នុងឃុំងាយស្រួលក្នុងការចេញចូលប្រកបរបររកស៊ីរបស់ប្រជាពលរដ្ឋ ដែលសមស្របសម្រាប់ការតាំងលំនៅឋាន ជាជម្រកដ៏កក់ក្តៅសម្រាប់ជិវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។ បើផ្អែកទៅតាមកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២ ដែលនឹងមានប្រជាជនកើនឡើងរហូតដល់ចំនួន ៤ ៤៤៣ គ្រួសារ និងដីលំនៅឋានមិនមានការប្រែប្រួលកើនឡើងដូចរៀបរាបខាងលើ គឺនៅរក្សាទំហំ ២៦០ហិកតា ដូច្នេះទៅថ្ងៃអនាគត ១៥ឆ្នាំខាងមុខការប្រើប្រាស់ដីលំនៅឋាននឹងមានទំហំ ០,០៦ហិកតាក្នុងមួយគ្រួសារ ដែលប្រហាក់ប្រហែលនិងដីប្រើប្រាស់ដីលំនៅឋាននាពេលបច្ចុប្បន្នដែរ គឺចំនួន ០,០៩ ហិកតា ក្នុងមួយគ្រួសារ ។

-ទំហំដីលំនៅឋានជាមធ្យមសម្រាប់មួយគ្រួសារ១៥ឆ្នាំខាងមុខ =

**២៦០ហិកតា/៤ ៤៤៣គ្រួសារ=០,០៦ហិកតា**

ខ. កន្លែងកប់ខ្មោច

នៅពេលអនាគត ក្នុងឃុំទ្រា ដីកប់ខ្មោចមាន២កនកន្លែង ដែលស្ថិតនៅក្បែរផ្លូវវាងស្រុកស្ទោង នៅក្នុងភូមិតាចរ និង១កន្លែងទៀតស្ថិតនៅក្បែរផ្លូវលំគ្រួសក្រហមចេញពីផ្លូវជាតិលេខ៦ កាត់ផ្លូវវាងស្រុកស្ទោង ក្នុងភូមិបុសតាឯក ដែលមានផ្ទៃដីទំហំ៤,០៨ហិកតា ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីកប់ខ្មោចដោយពុំមានការពង្រីកបន្ថែមសម្រាប់ការដោះស្រាយរហូតដល់ឆ្នាំ២០៣២នោះឡើយ ។ នាពេលអនាគត ទីតាំងដីកប់ខ្មោច ដែលមានស្រាប់នាពេលបច្ចុប្បន្ននេះ នឹងត្រូវរក្សាទុកជាដីសម្រាប់កប់ខ្មោចដដែល ដោយសារតែទីតាំងដីនេះ ជាដីសហគមន៍ដែលគ្រប់គ្រងដោយរដ្ឋបាលឃុំទ្រា ហើយត្រូវបានប្រជាពលរដ្ឋក្នុងទ្រា ប្រើប្រាស់ទុកជាកន្លែងបញ្ចុះសពតាំងពីយូរយារណាស់មកហើយ ។

គ. ទីលានចាក់សំរាម

នៅក្នុងឃុំទ្រា ដីទីលានចាក់សំរាមនៅពេលអនាគត ត្រូវបានកំណត់ទីតាំងនៅភាគខាងជើងឆៀងខាងកើតនៃឃុំ ស្ថិតក្នុងភូមិទំពេជ មានផ្ទៃដីទំហំ ៣,១៣ហិកតា ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាក់ស្តែងជាស្រែវស្សាក្រៅតំបន់ការពារ មានស្ថានភាពដីជាតំបន់ជម្រាលមធ្យម និងជាដីកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ ។ នាពេលអនាគតទីតាំងដីត្រូវបានកំណត់ជាទីលានចាក់សំរាមនេះ ដោយសារដីនេះមានស្ថានភាពជាដីខ្ពស់មិនលិចទឹកខ្លាំងនៅរដូវវស្សា ហើយនៅឃ្លាតឆ្ងាយពីភូមិ ដែលសមស្របបំផុតសម្រាប់ការប្រើប្រាស់ជាទីលានចាក់សំរាមក្នុងឃុំ ។

ឃ. ដីស្រែវស្សា

នៅក្នុងឃុំទ្រា ដីដែលបានកំណត់ការប្រើប្រាស់សម្រាប់ស្រែវស្សានាពេលអនាគតមានផ្ទៃដីសរុបទំហំ ៥ ០០០ហិកតា ដែលបច្ចុប្បន្ននេះ ត្រូវបានប្រើប្រាស់ជាក់ស្តែងសម្រាប់ស្រែវស្សាដដែល ដោយពុំមានពង្រីកបន្ថែមសម្រាប់ដំណោះស្រាយទៅនឹងកំណើនប្រជាជនរហូតឆ្នាំ២០៣២នោះឡើយ តែត្រូវបានកាត់ចេញទៅជាដីទីលានចាក់សំរាមអស់ ៣,១៣ហិកតាទៀតផង។ ដីស្រែវស្សាស្ថិតនៅលាតសន្ធឹងខាងកើតផ្លូវជាតិលេខ៦ ហើយមានស្ថានភាពជាដីជម្រាលមធ្យមពីជើងទៅត្បូងឃុំ និងមានប្រភេទដីកណ្តេងលាយល្បាប់(ពណ៌លឿង) និងខ្សាច់លាយកណ្តេង និងមានល្បាយខ្សាច់ (សលាយក្រហម) ។ ដីស្រែវស្សានេះត្រូវពឹងផ្អែកលើប្រភពទឹកសម្រាប់ស្រោចស្រពពីទឹកភ្លៀង ស្ទឹង ស្រះទឹក និងប្រឡាយ ៣០កញ្ញា ដែលមានប្រភពពីទំនប់ស្នាក់ទឹកស្ទឹងស្ទោងស្ថិតក្នុងស្រុកស្ទោង នៅខាងកើតនៃឃុំនាំទឹកមកស្រោចស្រពតាម រយៈប្រឡាយមេ គឺប្រឡាយ៣០កញ្ញា ដោយប្រើប្រាស់មធ្យោបាយម៉ាស៊ីនបូមទឹក ។ នាពេលអនាគត ទីតាំងដីស្រែវស្សា ដែលមានស្រាប់នាពេលបច្ចុប្បន្ន នឹងត្រូវរក្សាទុកជាដីសម្រាប់ប្រើប្រាស់ជាដីស្រែវស្សាដដែល ដោយសារដីនេះមានស្ថានភាពជាដីទំនាបលិចទឹកនៅរដូវវស្សាសមស្រប សម្រាប់ដំណាំស្រូវទទួលបានផលិតផល ផ្គត់ផ្គង់ដល់ការហូបចុកសម្រាប់ជីវិតរស់របស់ប្រជាពលរដ្ឋក្នុងឃុំ និងនៅសល់លក់ទៅទីផ្សារ ក្នុងនិងក្រៅ ដើម្បីបង្កើនបាននូវប្រាក់ចំណូលក្នុងគ្រួសារ និងចំណូលថវិកាជាតិ ។ ដីស្រែវស្សានាពេលអនាគតមានស្ថានភាពនៃការកាន់កាប់ទៅតាមតំបន់ផ្សេងគ្នាដូចខាងក្រោម៖

-**ដីស្រែវស្សាក្រៅតំបន់ការពារ៖** ដីស្រែវស្សាក្រៅតំបន់ការពារស្ថិតនៅខាងកើតផ្លូវជាតិលេខ៦ នៅភាគខាងត្បូងនៃឃុំ មានទំហំផ្ទៃដី ២៨៤៦,៨៧ហិកតា គឺជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់ប្រើប្រាស់ដោយប្រជាពលរដ្ឋ ។

**-ដីស្រែវស្សាក្នុងគម្របព្រៃឆ្នាំឈើ ២០០២ ៖** ដីស្រែវស្សាក្នុងគម្របព្រៃឆ្នាំ២០០២ ស្ថិតនៅភាគខាងកើតនៃឃុំនៅបន្តចាប់ពីដីស្រែវស្សាក្រៅតំបន់ការពារ ហើយមានផ្ទៃដីទំហំផ្ទៃដី ១ ៨០០ ហិកតា ជាដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ត្រូវបានប្រជាពលរដ្ឋកាន់កាប់ប្រើប្រាស់ធ្វើស្រែវស្សា ដែលទៅថ្ងៃអនាគតអាជ្ញាធរដែនដីពាក់ព័ន្ធត្រូវស្នើសុំការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាល ដើម្បីជូនប្រជាពលរដ្ឋធានាសុវត្ថិភាពកាន់កាប់ជាកម្មសិទ្ធិផ្ទាល់ខ្លួនបាន បើពុំមានការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាលទេនោះ ដីនេះនឹងត្រូវប្រើប្រាស់ជាដីព្រៃឈើ ហាមប្រើប្រាស់មុខងារក្រៅពីរក្សាទុកជាដីគម្របព្រៃឈើឡើងវិញ ។

**-ដីស្រែវស្សាក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាប (សត្វខ្សឹប) ត្រួតគ្នាជាមួយគម្របព្រៃឈើឆ្នាំ ២០០២ ៖** ទីតាំងដីនេះស្ថិតនៅភាគកណ្តាលនៃឃុំ មានទំហំផ្ទៃដី ៣៥០ ហិកតា គឺជាដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ត្រូវបានប្រជាពលរដ្ឋកាន់កាប់ប្រើប្រាស់ធ្វើស្រែវស្សា ដែលទៅថ្ងៃអនាគត អាជ្ញាធរ ដែនដីពាក់ព័ន្ធត្រូវស្នើសុំការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាល ដើម្បីជូនប្រជាពលរដ្ឋធានាសុវត្ថិភាពកាន់កាប់ជាកម្មសិទ្ធិផ្ទាល់ខ្លួនបាន បើពុំមានការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាលទេនោះ ដីនេះនឹងត្រូវប្រើប្រាស់ជាដីការពារដោយហាមប្រើប្រាស់មុខងារក្រៅពីគោលបំណងការពារនេះ ។

### ង. ដីចម្ការ

នៅក្នុងឃុំទ្រា ដីដែលបានកំណត់ការប្រើប្រាស់ សម្រាប់ដំណាំចម្ការ ដែលផ្តោតសំខាន់ទៅលើដំណាំឧស្សាហកម្មនាពេលអនាគតមានផ្ទៃដីសរុបទំហំ ៥ ៣០០ហិកតា ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាក់ស្តែងជាដីចម្ការដំណាំស្វាយចន្ទីនិងដំឡូងមីភាគច្រើន ។ ដីចម្ការទាំងនេះ ស្ថិតនៅភាគខាងកើតនិងខាងលិចនៃឃុំ ហើយមានស្ថានភាពជាដីទម្រាលមធ្យម និងខ្ពស់ ព្រមទាំងមានប្រភេទដីកណ្តេងលាយល្បាប់(ពណ៌លឿង) និងខ្សាច់លាយកណ្តេង និងមានល្បាយខ្សាច់(សលាយក្រហម)។ដីចម្ការនេះត្រូវពឹងផ្អែកទៅលើប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ស្ទឹង និងស្រះទឹក ។ នាពេលអនាគតទីតាំងដីដែលត្រូវបានកំណត់ការប្រើប្រាស់ជាដីចម្ការ ដោយសារដីនេះមានស្ថានភាពជាដីជម្រាលខ្ពស់ និងមធ្យម ដែលសមស្រប សម្រាប់ដំណាំចម្ការឧស្សាហកម្ម ទទួលបានផលិតផលផ្គត់ផ្គង់សម្រាប់ការនាំចេញទៅរកទីផ្សារ ដែលជាការប្រសើរជាងនេះទៀតនោះផលិតផលទាំងនេះត្រូវធ្វើការកែច្នៃមុននឹងនាំចេញទៅរកទីផ្សារ ដែលនាំឱ្យឃុំទ្រា មានមូលដ្ឋានគ្រឹះកាន់តែរឹងមាំក្នុងការអភិវឌ្ឍន៍ក្នុង ឃុំខ្លួនឯងថែមទៀត ជាពិសេសនឹងនាំឱ្យកើនឡើងប្រាក់ចំណូលក្នុងគ្រួសារ ក៏ដូចជា បានចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។ ដីចម្ការនាពេលអនាគតមានស្ថានភាពនៃការកាន់កាប់ទៅតាម២តំបន់ផ្សេងគ្នាដូចខាងក្រោម៖

**-ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២៖** ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២ ស្ថិតនៅភាគខាងលិចនៃឃុំនៅតាមបណ្តោយព្រំប្រទល់ជាប់ជាមួយឃុំប្រឡាយ និងឃុំពពក មានទំហំផ្ទៃដី ៣ ២០០ ហិកតា ជាដីសាធារណៈរបស់រដ្ឋ ត្រូវបានប្រជាពលរដ្ឋកាន់កាប់ប្រើប្រាស់ធ្វើចម្ការស្វាយចន្ទី និងដំឡូងមី ដែលទៅថ្ងៃអនាគត អាជ្ញាធរដែនពាក់ព័ន្ធ ត្រូវស្នើសុំការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាល ដើម្បីជូនប្រជាពលរដ្ឋធានាសុវត្ថិភាពកាន់កាប់ជាកម្មសិទ្ធិផ្ទាល់ខ្លួនបាន បើពុំមានការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាលទេនោះ ដីនេះនឹងត្រូវប្រើប្រាស់ជាដីព្រៃឈើ ដែលហាមប្រើប្រាស់មុខងារក្រៅពីរក្សាទុកជាដីគម្របព្រៃឈើឡើងវិញ ។

**-ដីចម្ការក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាប(សត្វខ្សឹប)ត្រួតគ្នាជាមួយគម្របព្រៃឈើឆ្នាំ២០០២៖** ដីចម្ការក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាប(សត្វខ្សឹប)ត្រួតគ្នាជាមួយគម្របព្រៃឈើឆ្នាំ ២០០២ ស្ថិតនៅភាគខាងកើតនៃឃុំជាប់ជាមួយឃុំដូងមានផ្ទៃដី ២ ១០០ ហិកតា ជាដីសាធារណៈរបស់រដ្ឋ ត្រូវបានប្រជាពលរដ្ឋកាន់កាប់ប្រើប្រាស់ធ្វើចម្ការស្វាយចន្ទី និងដំឡូងមី ដែលទៅថ្ងៃអនាគត អាជ្ញាធរដែលពាក់ព័ន្ធត្រូវធ្វើការស្នើសុំ

ការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាលដើម្បីជូនប្រជាពលរដ្ឋធានាសុវត្ថិភាពកាន់កាប់ជាកម្មសិទ្ធិផ្ទាល់ខ្លួនបាន បើពុំមានការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាលទេនោះ ដីនេះនឹងត្រូវប្រើប្រាស់ជាដីព្រៃឈើ ដែលហាម ប្រើប្រាស់មុខងារក្រៅពីរក្សាទុកជាដីគម្របព្រៃឈើឡើងវិញ ។

### ច. ព្រៃជាមួយចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២

នៅក្នុងឃុំទ្រា ដីដែលបានកំណត់ការប្រើប្រាស់ជាដីព្រៃជាមួយចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ៣៤,៣៨ហិកតា ដែលបច្ចុប្បន្នជាក់ស្តែងជាដីព្រៃជាមួយចម្ការដដែល ។ ដីព្រៃជាមួយដីស្រែទាំងនេះស្ថិតនៅភាគខាងលិចនៃឃុំ នៅជាប់ព្រំប្រទល់ឃុំប្រឡាយ ជាដីសាធារណៈរបស់រដ្ឋ ។ នាពេលអនាគតទីតាំងដីដែលត្រូវបានកំណត់ជាដីព្រៃជាមួយដីចម្ការដដែល ដោយសារដីព្រៃបានធ្វើចម្ការដោយប្រជាពលរដ្ឋ មិនសូវមានដីជាតិមិនអំណោយផលដល់ការដាំដំណាំផ្សេងៗ ត្រូវបានប្រជាពលរដ្ឋរក្សាទុកជាព្រៃបៃតង និងឆ្លៀលធ្វើចម្ការបានតិចតួចប៉ុណ្ណោះ ចំណែកដីក្នុងគម្របព្រៃឈើឆ្នាំ២០០២ត្រូវរក្សាទុកជាដីព្រៃ សម្រាប់ជាគម្របព្រៃឈើឡើងវិញ ដើម្បីប្រើប្រាស់ជាតំបន់បៃតង ជួយផ្តល់ឧស្ម័នអុកស៊ីសែនដល់មនុស្សនិងស្រូបយកឧស្ម័នកាបូនិក ជាជម្រកសត្វព្រៃ ផ្តល់ខ្យល់អាកាសបរិសុទ្ធ ជួយទប់ទល់ខ្យល់ព្យុះនិងទឹកជំនន់ ជួយទាក់ទាញទឹកភ្លៀង ជួយរក្សាលំនឹងអាកាសធាតុ ។ល។

### ឆ. ព្រៃជាមួយដីស្រែ

នៅក្នុងឃុំទ្រា ដីដែលបានកំណត់ការប្រើប្រាស់សម្រាប់ដំណាំស្រូវ នាពេលអនាគត មានផ្ទៃដីសរុបទំហំ ៨៩០ហិកតា ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាក់ស្តែងជាដីព្រៃឃ្មៀល សម្រាប់ធ្វើស្រែនៅក្នុងគម្របព្រៃឈើឆ្នាំ ២០០២ ។ ដីព្រៃទាំងនេះ ស្ថិតនៅភាគកណ្តាលនៃឃុំភាគច្រើន និងមានតិចតួចនៅភាគកើតនៃឃុំជាប់ឃុំបន្ទាយស្ទោងហើយមានស្ថានភាពជាដីទម្រាលមធ្យមនិងខ្ពស់ព្រមទាំងមានប្រភេទដីកណ្តោងលាយល្បាប់(ពណ៌លឿង) និងខ្សាច់លាយកណ្តោង និងល្បាយខ្សាច់(សលាយក្រហម) ។ ដីព្រៃនេះត្រូវពឹងផ្អែកលើប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ស្ទឹង និងស្រះទឹក ។ នាពេលអនាគតទីតាំងដីដែលត្រូវបានកំណត់ការប្រើប្រាស់ ជាដីព្រៃលាយជាមួយដីស្រែដដែល ដោយសារដីនេះ មានស្ថានភាពជាដីជម្រាលខ្ពស់និងមធ្យម ដែលសមស្របសម្រាប់ដំណាំស្រូវទទួលបានផលិតផលផ្គត់ផ្គង់ សម្រាប់ការនាំចេញទៅរកទីផ្សារ ដែលជាការប្រសើរជាងនេះទៀតនោះផលិតផលទាំងនេះត្រូវធ្វើការកែច្នៃមុននឹងនាំចេញទៅរកទីផ្សារ ដែលនាំឱ្យឃុំទ្រា មានមូលដ្ឋានគ្រឹះកាន់តែរឹងមាំនៅក្នុងការអភិវឌ្ឍន៍នៅក្នុងឃុំខ្លួនឯងថែមទៀត ជាពិសេសនឹងនាំឱ្យកើនឡើងប្រាក់ចំណូលក្នុងគ្រួសារ ក៏ដូចជាបានចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។

### ជ. ព្រៃជាមួយដីស្រែក្នុងតំបន់ការពារសត្វខ្សឹបត្រួតគ្នាគម្របព្រៃឈើឆ្នាំ២០០២

នៅក្នុងឃុំទ្រា ដីដែលបានកំណត់ការប្រើប្រាស់សម្រាប់ដំណាំស្រូវ នាពេលអនាគត មានផ្ទៃដីសរុបទំហំ ៨៩០ហិកតាដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាក់ស្តែងជាដីព្រៃឃ្មៀលសម្រាប់ធ្វើស្រែដែលស្ថិតក្នុងតំបន់ការពារទំនាបខាងជើងទន្លេសាប (សត្វខ្សឹប) ត្រួតគ្នាជាមួយគម្របព្រៃឈើឆ្នាំ២០០២ ។ ដីព្រៃទាំងនេះ ស្ថិតនៅភាគកើតនៃឃុំជាប់ព្រំប្រទល់ជាមួយឃុំដូង ហើយមានស្ថានភាពជាដីទម្រាលមធ្យម និងខ្ពស់ ព្រមទាំងមានប្រភេទដីកណ្តោងលាយល្បាប់ (ពណ៌លឿង) និងខ្សាច់លាយកណ្តោង និងល្បាយខ្សាច់ (សលាយក្រហម) ។ ដីព្រៃនេះត្រូវពឹងផ្អែកលើប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ស្ទឹង និងស្រះទឹក ។ នាពេលអនាគត ទីតាំងដីដែលត្រូវបាន

កំណត់ការប្រើប្រាស់ជាដីព្រៃលាយជាមួយដីស្រែដដែល ដោយសារតែដីនេះមានស្ថានភាពជាដីជម្រាលខ្ពស់និងមធ្យម ដែលសមស្របសម្រាប់ដំណាំស្រូវទទួលបានផលិតផលផ្គត់ផ្គង់សម្រាប់ការនាំចេញទៅរកទីផ្សារ ដែលជាការប្រសើរជាងនេះទៀតនោះផលិតផលទាំងនេះ ត្រូវបានធ្វើការកែច្នៃមុននឹងនាំចេញទៅរកទីផ្សារ ដែលនាំឱ្យឃុំទ្រា មានមូលដ្ឋានគ្រឹះកាន់តែរឹងមាំក្នុងការអភិវឌ្ឍន៍ក្នុងឃុំខ្លួនឯងថែមទៀត ជាពិសេស នឹងនាំឱ្យកើនឡើងប្រាក់ចំណូលក្នុងគ្រួសារ ក៏ដូចជាបានចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។

### ឈ. ព្រៃល្បោះ

តំបន់ព្រៃល្បោះមាន ចំនួន៣កន្លែង មានទំហំ២៧៦,៩២ហិកតា ដែលស្ថិតនៅភូមិទំពេជ ។ តំបន់នេះសម្បូរទៅដោយឈើសំណង់លំនៅឋានដូចជា៖ ខ្លុងត្បែង ធ្នឹក សុក្រម ធ្នុង។ល។

នៅក្នុងឃុំទ្រា ដីដែលបានកំណត់ជាដីព្រៃល្បោះមានផ្ទៃដីទំហំ ២៨០ហិកតា ដែលបច្ចុប្បន្នជាក់ស្តែងជាដីព្រៃល្បោះដដែល ។ ដីព្រៃល្បោះទាំងនេះមានមួយផ្នែកធំស្ថិតនៅខាងជើងនៃឃុំ និងមួយផ្នែកទៀតមានពីរទីតាំងផ្សេងគ្នា ស្ថិតនៅខាងជើងឆៀងកើតនៃឃុំ ជាប់ព្រំប្រទល់ឃុំសាមគ្គី ។ ព្រៃល្បោះទាំងនេះសម្បូរទៅដោយខ្លុង ត្បែង ត្រសេក រាំង គ្រើល ។ល។ ដីព្រៃល្បោះនេះ នឹងត្រូវបានការពារ រៀបចំជាព្រៃសហគមន៍ព្រៃឈើ ជាដីកម្មសិទ្ធិឯកជនរបស់រដ្ឋដែលគ្រប់គ្រង ដោយរដ្ឋបាលព្រៃឈើនិងអាជ្ញាធរឃុំទ្រា ដែលត្រូវថែទាំនិងដាំកូនឈើរក្សាការពារទុកជាតំបន់បៃតង ដើម្បីឱ្យមានលំនឹងបរិស្ថានដូចជានឹងជួយផ្តល់ឧស្ម័នអុកស៊ីសែនដល់មនុស្ស និងស្រូបយកឧស្ម័នកាបូនិក ជាជម្រកសត្វព្រៃ ផ្តល់ខ្យល់អាកាសបរិសុទ្ធជួយទប់ទល់ខ្យល់ព្យុះ និងទឹកជំនន់ជួយទាក់ទាញទឹកភ្លៀង ជួយរក្សាលំនឹងអាកាសធាតុ។ល។

### ញ. ព្រៃតាមដងស្ទឹង

នៅក្នុងឃុំទ្រា ព្រៃតាមដងស្ទឹងមាននៅតាមដងស្ទឹងស្ទោង ដែលមានផ្ទៃដីទំហំ ០,០៧ហិកតា សម្បូរទៅដោយដើមឈើចំរុះដុះលាយឡំគ្នាដូចជា៖ ដើមភ្នំភ្លេង ត្រល់ កប្បាស់ព្រៃ ស្មាច់ និងដើមរាំងជាដើម ហើយដើមទាំងនេះ មានសារៈប្រយោជន៍ក្នុងការជួយការពារការហូរច្រោះបាក់ដី និងជាជំរកត្រីមួយយ៉ាងសំខាន់នៅរដូវត្រីពងកូន និងជាដីសាធារណៈរបស់រដ្ឋ ។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីព្រៃតាមដងស្ទឹងដដែល ដើម្បីប្រើប្រាស់បានជាប្រយោជន៍ក្នុងការជួយការពារពីការហូរច្រោះបាក់ដីនៅតាមមាត់ស្ទឹង ជាជម្រកត្រីពងកូន ផ្តល់ឈើសម្រាប់ប្រើប្រាស់ផ្សេងៗ ធ្វើឱ្យដីនៅក្នុងតំបន់នោះមានជីជាតិ ជួយផ្តល់ឧស្ម័នអុកស៊ីសែនដល់មនុស្ស និងស្រូបយកឧស្ម័នកាបូនិក ជាជម្រកសត្វព្រៃ ផ្តល់ខ្យល់អាកាសបរិសុទ្ធ ជួយទប់ទល់ខ្យល់ព្យុះ និងទឹកជំនន់ជួយទាក់ទាញទឹកភ្លៀង ជួយរក្សាលំនឹងអាកាសធាតុ ។ល។

### ដ. ស្ទឹងមានទឹកតាមរដូវ

ឃុំទ្រា ដីដែលបានកំណត់ការប្រើប្រាស់ជាដីស្ទឹងមានទឹកតាមរដូវ មានផ្ទៃដីទំហំ៦៧,១៥ហិកតា ដែលជាស្ទឹងស្ទោង ស្ថិតនៅភាគខាងកណ្តាលឆៀងលិចនៃឃុំ គឺជាដីសាធារណៈរបស់រដ្ឋ ដែលជាប្រភពទឹកដ៏សំខាន់សម្រាប់ស្រោចស្រពដំណាំស្រូវ និងដំណាំផ្សេងៗទៀត និងមានសម្បូរទៅដោយមច្ឆាជាតិជាច្រើន ។ នាពេលអនាគតស្ទឹងនេះជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីនជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ត្រូវការពារថែរក្សា ដោយហាមដាច់ខាតការកាប់រានកាន់កាប់ដីមាត់ស្ទឹង ប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ ខ្លួន ។

ឋ. ស្រះទឹក

នៅក្នុងឃុំទ្រា ដីដែលបានកំណត់ការប្រើប្រាស់ជាដីស្រះទឹកមានទំហំផ្ទៃដីសរុបចំនួន ២៩,៧៥ហិកតា ដែលបច្ចុប្បន្នជាក់ស្តែង ជាដីស្រះទឹកនៅរាយប៉ាយជាច្រើនកន្លែងនៅក្នុងឃុំ មានផ្ទៃដីសរុបទំហំ ២៧ហិកតា ស្ថិតនៅភាគខាងត្បូងឆៀងខាងលិចនៃឃុំ ជាដីកម្មសិទ្ធិឯកជន ដែលកាន់កាប់និងប្រើប្រាស់ដោយប្រជាពលរដ្ឋ លើកលែងតែដីស្រះទឹក ដែលស្ថិតក្នុងតំបន់គម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ១,៣៤ហិកតា ស្ថិតនៅភាគកណ្តាលឆៀងខាងលិចនៃឃុំ និងស្រះស្ថិតក្នុងតំបន់ទំនាបខាងជើងទន្លេសាប(សត្វខ្សឹប) ត្រួតគ្នាជាមួយគម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ១,៤១ហិកតា ស្ថិតនៅភាគកណ្តាលឆៀងខាងកើតនៃឃុំនៃឃុំ ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែអាស្រ័យផលប៉ុណ្ណោះ ។ នាពេលអនាគតស្រះទឹកទាំងនេះនឹងនៅតែជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់បានច្រើនយ៉ាងនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីនជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

## ៣.៣. ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី

ជាការពិត បច្ចុប្បន្នយើងបានរកឃើញនៅក្នុងឃុំទ្រាមានប្រជាពលរដ្ឋក្រីក្រខ្វះខាតដីលំនៅឋានចំនួន ២៦៨គ្រួសារ និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារពិតប្រាកដចំនួន ៣៣៧គ្រួសារ ដូចបានរកឃើញនៅក្នុងជំពូកទី១នៃរបាយការណ៍នេះ ដែលបច្ចុប្បន្នមួយចំនួនកំពុងរស់នៅលើចិញ្ចើមផ្លូវ ស្ទឹង លើដីចំណីប្រឡាយ និងមួយចំនួនទៀតរស់នៅក្នុងខ្ទមលើដីរបស់អ្នកដទៃ ដែលពួកគាត់ត្រូវស៊ីឈ្នួលឱ្យគេដើម្បីចិញ្ចឹមជីវិត ។ ដូច្នេះ ដើម្បីដោះស្រាយដីសម្រាប់សាងសង់លំនៅឋាន និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដែលអាចផ្តល់ឱកាសឱ្យពួកគាត់មានជម្រករស់នៅសមរម្យ និងបង្កើតឱកាសការងារដើម្បីទទួលបានប្រាក់ចំណូលជូនពួកគាត់បាន អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ត្រូវខិតខំដោះស្រាយតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ចនៅថ្នាក់ក្រោមជាតិ ដែលត្រូវផ្តួចផ្តើមឡើងដោយក្រុមប្រឹក្សាឃុំទ្រា ។ ដីធ្លីដែលត្រូវដោះស្រាយពួកគាត់ដូចបានធ្វើការវិភាគដោះស្រាយនៅក្នុងជំពូកទី២ ត្រង់ចំណុច ២.១.៣ ខាងលើគឺ ដីសម្រាប់លំនៅឋានមានទំហំ ៦៧ហិកតា និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារមានទំហំ៦៧៤ហិកតា ។

## ៣.៤. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

និរន្តរភាពនៃការប្រើប្រាស់ដី គឺជាការធានាឱ្យបាននូវគោលដៅ និងអត្ថប្រយោជន៍នៃការប្រើប្រាស់ដីទាំងនោះ ហើយការធានាទាំងអស់នេះ ត្រូវតែកើតមានឡើងជាបន្តបន្ទាប់ជារៀងរហូត ដោយពុំមានឈប់ឈរ ។ និរន្តរភាព គឺជាចំណុចស្នូលសម្រាប់ការប្រើប្រាស់ដីនៅគ្រប់តំបន់គោលដៅទាំងអស់តាមរយៈការកំណត់កត្តាចាំបាច់នានាសម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធិភាព និងធានាឱ្យមាននិរន្តរភាព ។

### ៣.៤.១.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ព្រមទាំងថែរក្សាការពារបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព ។ ដោយធាធានបានការផ្តត់ផ្តង់សេចក្តីត្រូវការ និងការទទួលខុសត្រូវចំពោះផលប្រយោជន៍របស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ននិងបន្តដល់កូនចៅរបស់ពួកគាត់ទៅជំនាន់ក្រោយទៀត ត្រូវតែយកចិត្តទុកដាក់

ដល់ការគ្រប់គ្រងទៅលើការប្រើប្រាស់ទាំងអស់នៅក្នុងឃុំដែលបានកំណត់រួច ។ តាមរយៈការខិតខំប្រឹងប្រែងអនុវត្ត ឱ្យសម្រេចបានទៅលើកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

ក. ការគ្រប់គ្រងប្រព័ន្ធកសិកម្ម

បើពិនិត្យទៅលើលក្ខណៈភូមិសាស្ត្រ និងសក្តានុពលនៃធនធានដែលមាននៅក្នុងឃុំទ្រា ដែលក្រុមការងារបានធ្វើការសិក្សាស្រាវជ្រាវរកឃើញ បានកំណត់ច្បាស់ថា ឃុំនេះមានគោលដៅអភិវឌ្ឍន៍ទៅថ្ងៃអនាគត ពឹងផ្អែកទៅលើវិស័យកសិកម្មជាចម្បង ដែលក្នុងនោះបានផ្តោតសំខាន់ទៅលើដំណាំស្រូវ។ ដូចនេះ ឃុំទ្រានឹងមានតួនាទីសំខាន់មួយ ក្នុងការធ្វើឱ្យសម្រេចបាននូវគោលនយោបាយជំរុញផលិតកម្មស្រូវ និងនាំចេញអង្កររបស់រាជរដ្ឋាភិបាល ដែលត្រូវចាំបាច់ទាមទារឱ្យមានការគ្រប់គ្រងប្រព័ន្ធកសិកម្មក្នុងឃុំឱ្យបានរឹងមាំ និងមាននិរន្តរភាពទៅថ្ងៃអនាគតត្រូវយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវ ដើម្បីបង្កើនទិន្នផលស្រូវឱ្យបានខ្ពស់អស់សក្តានុពល អាចមានលទ្ធភាពនាំស្រូវចេញបានច្រើនសល់ពីការហូបចុកឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋ ។

ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ឃុំដូចខាងលើត្រូវមានការគ្រប់គ្រងដីស្រែនៅក្នុងឃុំឱ្យបានច្បាស់លាស់ដោយរាល់ការសម្រេចចិត្តប្តូរមុខងារប្រើប្រាស់ដី ពីកសិកម្មទៅជាបម្រើឱ្យការសាងសង់និងបម្រើឱ្យការប្រើប្រាស់ផ្សេងទៀតត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ប្រកបទៅដោយតម្លាភាព ដោយអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងត្រូវមានការផ្សព្វផ្សាយជាចំហ ។ ទន្ទឹមនឹងការគ្រប់គ្រងដីស្រែចម្ការ ត្រូវគិតគូរពីទឹកស្រោចស្រពដំណាំស្រូវ ដោយធ្វើយ៉ាងណាអាចធ្វើស្រែបង្កើនរដូវ និងស្រែប្រាំងឱ្យបានបីដងក្នុងមួយឆ្នាំតាមរយៈការស្តារនូវប្រព័ន្ធប្រឡាយចាស់ៗ ដែលមានស្រាប់អាចនាំទឹកទៅស្រោចស្រពដីស្រែបានគ្រប់គ្រាន់ដោយទាញយកទឹកពីប្រភពសំខាន់គឺអាង៣០កញ្ញា ដែលស្ថិតក្នុងឃុំព្រះដំរី ក្នុងស្រុកស្វាង និងស្ទឹងស្វាង ហូរកាត់ភូមិសាស្ត្រឃុំ នៅភាគខាងកើត ដើម្បីអាចផ្តល់ទឹកមកតាមប្រព័ន្ធប្រឡាយមេ និងប្រឡាយរងជាច្រើនទៀតផងដែរ។ បន្ទាប់ពីកត្តាដី និងទឹកនៅមានកត្តាបច្ចេកទេសដាំដុះថែមទៀត ដោយត្រូវគិតគូរជំរុញការធ្វើស្រែបែបប្រពលវប្បកម្មទំនើបដូចមានលើកឡើងតាមការវិភាគក្នុងជំពូកទី២ ត្រង់ចំណុចការផ្តល់ឱកាស ដោយបច្ចេកវិទ្យាទំនើប ដែលកត្តានេះនឹងលើកទឹកចិត្តឱ្យយុវជនចូលរួមក្នុងការងារកសិកម្មបានច្រើនផងដែរ ពីព្រោះយុវជនតែងគិតថាការធ្វើស្រែ នាំឱ្យមានការនឿយហត់ ប្រឡាក់ប្រឡូកដីភក់ មិនស្អាតបាត ដែលជាការយល់ខុស គឺតាមពិតការធ្វើស្រែតាមបែបប្រពលវប្បកម្មទំនើប កសិករក៏អាចពាក់ក្រវ៉ាត់កប្រើប្រាស់កុំព្យូទ័រក្នុងបន្ទប់ម៉ាស៊ីនត្រជាក់បានដូចគ្នា។ ក្នុងការគ្រប់គ្រងប្រព័ន្ធកសិកម្មនៅឃុំទ្រាមិនមែនយកចិត្តទុកដាក់ តែនៅលើការជំរុញផលិតកម្មកសិកម្មដូចខាងលើប៉ុណ្ណោះទេ តែត្រូវខិតខំពង្រឹងការប្រមូលគ្នាចងក្រងជាសហគមន៍ កសិករដើម្បីជ្រើសរើសតំណាងអាចទៅចូលរួមកស៊ូមតិក្នុងការចរចារកទីផ្សារក៏ដូចជាមួយឈ្មួញ ដោយធានាការធ្វើ ស្រែបានផលស្រូវមានគុណភាពតាមស្តង់ដារតម្រូវទីផ្សារ និងធានាលំនឹងតម្លៃក្នុងទីផ្សារផងដែរ ។

តាមការគណនា ដែលផ្អែកទៅលើការការគិតគូរនៅក្នុងជំពូក២ ត្រង់ចំណុច ១.២.៣ អាចឱ្យយើងរំពឹងទុកអំពីបរិមាណផលស្រូវនាំចេញនាពេលអនាគតក្នុងអំឡុងពេល១៥ឆ្នាំខាងមុខដូចខាងក្រោមៈ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ប្រជាពលរដ្ឋកើនឡើងដល់ ២២ ៦៥១នាក់

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ដីស្រែកើនដល់ ៤៩៩៦,៨៧ ហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ទិន្នផលស្រូវ ៤ តោន ក្នុងមួយហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ធ្វើស្រែបាន៣ដងក្នុងមួយឆ្នាំ

**-ដូច្នេះក្នុងកំឡុងពេល១៥ឆ្នាំ(២០១៧-២០៣២)ផលិតផលស្រូវទទួលបានក្នុងមួយឆ្នាំជាមធ្យម៖**

**៤ ៩៩៦,៨៧ហិកតា x ៤តោន/ហិកតា x ៣ដង = ៥៩ ៩៦២,៤៤តោន/ឆ្នាំ**

-ប្រជាពលរដ្ឋ១នាក់ ត្រូវការអង្ករសម្រាប់ហូបក្នុងមួយឆ្នាំមានចំនួន ១៤៣គីឡូក្រាម ដែលបើគិតជាស្រូវត្រូវការចំនួន **២២៤ គីឡូក្រាម** ( **ផ្អែកតាមរបាយការណ៍ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ** )

-ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណស្រូវសម្រាប់ផ្គត់ផ្គង់ការហូបចុកក្នុងមួយឆ្នាំជាមធ្យម ៖

**២២ ៦៥១នាក់ x២២៤ គីឡូក្រាម = ៥ ០៧៣ ៨២៤គីឡូក្រាម/ឆ្នាំ ស្មើនឹង ៥ ០៧៣,៨២តោន/ឆ្នាំ**

-ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណពូជស្រូវក្នុងមួយឆ្នាំជាមធ្យម ៖

**៤ ៩៩៦,៨៧ហិកតា x ៣០០ គីឡូក្រាម =១ ៤៩៩ ០៦១គីឡូក្រាម/ឆ្នាំ ស្មើនឹង ១ ៤៩៩តោន/ឆ្នាំ**

-ដូច្នេះក្នុងអំឡុងពេល១៥ឆ្នាំខាងមុខ ផលិតផលស្រូវទទួលបានសម្រាប់ការនាំចេញក្នុងមួយឆ្នាំជាមធ្យម៖

**៥៩ ៩៦២,៤៤តោន/ឆ្នាំ - ៥ ០៧៣,៨២តោន/ឆ្នាំ - ១ ៤៩៩តោន/ឆ្នាំ = ៥៣ ៣៨៩,៦២តោន/ឆ្នាំ**

**-តែបើគិតជាអង្ករវិញអាចនាំចេញបានក្នុងមួយឆ្នាំជាមធ្យម:**

**៥៣ ៣៨៩,៦២តោន/ឆ្នាំ x ៦០%= ៣២ ០៣៤តោន/ឆ្នាំ**

### ខ. ការគ្រប់គ្រងព្រៃឈើ ជលផល និង ធនធានសំខាន់ៗផ្សេងៗទៀត

នាពេលអនាគតនៅក្នុងឃុំទ្រា មានដីព្រៃឈើទំហំសរុបប្រមាណ ១ ៦៩៤,៤៥ ហិកតា គឺ ស្មើនឹងប្រហាក់ប្រហែល ១៣,៧១ភាគរយនៃផ្ទៃដីសរុបក្នុងឃុំ ដែលនៅក្នុងនោះមានព្រៃល្បោះទំហំ ២៨០ហិកតា ព្រៃជាមួយចម្ការមានទំហំ ៣៤,៣៨ហិកតា ព្រៃជាមួយស្រែទំហំ ១ ៣៨០ហិកតា និងព្រៃតាមដងស្ទឹងទំហំ ០,០៧ហិកតា ។ ទំហំផ្ទៃដីព្រៃឈើ ១៣,៧១ភាគរយ គឺជាចំនួនដ៏ច្រើនដែលត្រូវមានវិធានការគ្រប់គ្រងថែរក្សាឱ្យបានគង់វង្ស ដោយចាំបាច់ត្រូវតែបង្កើតសហគមន៍ព្រៃឈើ ដែលមានការទទួលស្គាល់តាមផ្លូវច្បាប់ដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឱ្យសហគមន៍អាចថែរក្សាព្រៃឈើប្រកប ដោយនិរន្តរភាព និងធានាបាននូវការរក្សាសេវាកម្មបរិស្ថាន ដែលបានពីព្រៃឈើ ព្រមទាំងមានវិធានការការពារ និងទប់ស្កាត់ភ្លើងឆេះព្រៃដែលបង្កឡើងដោយសកម្មភាពមនុស្សផ្ទាល់ ដោយជនល្មើសនឹងត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើ ។ ទន្ទឹមនេះក៏ត្រូវពិនិត្យមើលដោយកចិត្តដាក់ពីការកាប់បំផ្លាញព្រៃឈើសម្រាប់ការកាន់កាប់យកដីធ្វើកសិកម្ម និងប្រើប្រាស់ផ្សេងៗ ដោយត្រូវនាំគ្នាគិតថា ការកាប់ព្រៃឈើមួយដើមហាក់ដូចជាបាត់បង់នូវជម្រកសម្រាប់មនុស្ស សត្វ អញ្ចឹងដែរ ពីព្រោះព្រៃឈើជាម្លប់សម្រាប់មនុស្ស សត្វ ដែលជាធនធានធម្មជាតិមនុស្ស សត្វមិនអាចខ្វះបាន ព្រមទាំងត្រូវពង្រឹងការប្រើប្រាស់ផលិតផលព្រៃឈើ និងព្រៃឈើឱ្យបានត្រឹមត្រូវ ហើយក៏ត្រូវជម្រុញការដាំដើមឈើឡើងវិញលើដីព្រៃដែលនៅក្នុងឃុំមានទាំងនេះរួមទាំងដាំនៅលើដីតាមទីសាធារណៈ តាមដងផ្លូវ ប្រឡាយទឹក ទីទួល ទីធ្លាសាលាឃុំទីធ្លាសាលារៀនទីធ្លា មណ្ឌលសុខភាព ទីធ្លានៅតាមវត្តអារាម និងនៅតាមលំនៅឋានជាដើម។ល។ ដើម្បីឱ្យមានដើមឈើពណ៌បៃតងនៅពាសពេញទូទាំងឃុំ បម្រើផលប្រយោជន៍នានាដូចជា ទាក់ទាញទឹកភ្លៀង បញ្ចុះសីតុណ្ហភាព ជួយយើងជៀសផុតពីការកើនឡើងនូវកម្តៅ ជាម្លប់ដ៏ត្រជាក់មានអាកាសធាតុបរិសុទ្ធ(ផ្តល់ខ្យល់អាកាសបរិសុទ្ធ)បញ្ចេញឧស្ម័នអុកស៊ីសែន (ស្រូបយកឧស្ម័នកាបូននិច និងបញ្ចេញឧស្ម័នអុកស៊ីសែនដល់មនុស្ស) ការពារគ្រោះធម្មជាតិ (ជួយទប់ទល់ខ្យល់ព្យុះទឹកជំនន់ជួយការពារការហូរច្រោះដី និងបាក់ដី) ធ្វើឱ្យដីមានជីជាតិ ជាតំបន់ទេសចរធម្មជាតិ ។ ចំណែកព្រៃលិចទឹកជាជម្រកត្រីពង ផ្តល់ជីជាតិដីសម្រាប់ធ្វើកសិកម្ម រក្សាជីវសាស្ត្រចម្រុះ ។

ចំណែកធនធានជលផលនៅក្នុងឃុំវិញ បច្ចុប្បន្ននេះមានតែតាមបែបធម្មជាតិនៅតាមស្ទឹង បឹង បួ ស្រះទឹក ប្រឡាយទឹក និងក្នុងស្រែនារដូវវស្សា ដែលអាចឱ្យប្រជាពលរដ្ឋនៅក្នុងឃុំអាចទទួលផលជាលក្ខណៈគ្រួសារបាន

តិចតួចតែប៉ុណ្ណោះ។ តែទៅថ្ងៃអនាគតក៏ត្រូវខិតខំយកចិត្តទុកដាក់ក្នុងការចិញ្ចឹមត្រីថែមទៀត ដើម្បីបានផលគ្រប់គ្រាន់ផ្តល់ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋនៅក្នុងឃុំទ្រា។ ចំពោះស្ថានភាពសមស្របក្នុងឃុំគួរចិញ្ចឹមត្រីតាមបែបចិញ្ចឹមក្នុងស្រះខ្នាតតូច ស្រះចិញ្ចឹមត្រីតាមគ្រួសារ និងកសិដ្ឋានចិញ្ចឹមត្រីក្នុងស្រែ ដែលជាទម្រង់មួយនៃការបង្កើនបរិមាណត្រីដោយអាចបង្កើនផលិតភាពផលផលតាមប្រពលវប្បកម្ម(តាមវាលស្រែ) ហើយមានប្រយោជន៍ក្នុងការប្រើត្រីសម្រាប់ទប់ទល់សត្វល្អិត និងដង្កូវហ្វូងក្នុងស្រែដែលបំផ្លាញផលដំណាំ ដូចបានលើកឡើងជាអនុសាសន៍នៅក្នុងជំពូកទី២នៃរបាយការណ៍នេះផងដែរ ។

ចំណែកធនធានសំខាន់ៗផ្សេងទៀតលើសពីការរៀបរាប់ខាងលើនេះ ពុំមានឃើញធនធានណាដែលគួរឱ្យកត់សម្គាល់ឡើយ ។

### ៣.៤.២.គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព

ដើម្បីមានមធ្យោបាយអាចធ្វើឱ្យសម្រេចបាននូវការគ្រប់គ្រងប្រព័ន្ធកសិកម្មនិងធនធានសំខាន់ៗសម្រាប់ការគាំទ្រដល់និរន្តរភាពនៃការអភិវឌ្ឍន៍ និងអភិរក្ស ដីធ្លីនិងធនធានធម្មជាតិក្នុងឃុំទ្រាចាំបាច់ត្រូវបង្កើតឱ្យមានគម្រោងគាំទ្រជាអាទិភាពមួយចំនួនដូចខាងក្រោម៖

- ជួសជុល និងស្តារប្រព័ន្ធធារាសាស្ត្រ
- ជួសជុល និងថែទាំផ្លូវ
- កសាងផ្លូវក្រាលកៅស៊ូ
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម
- បំផុសការចិញ្ចឹមត្រីតាមលក្ខណៈគ្រួសារ
- បណ្តុះបណ្តាលផលិតជីកំប៉ុស្ត
- បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី
- បណ្តុះបណ្តាលពីការដាំដំណាំស្រូវ
- តបណ្តាញទឹកស្អាតឱ្យដល់គ្រប់ភូមិ
- តបណ្តាញអគ្គិសនីឱ្យដល់គ្រប់ភូមិ
- បង្កើតទីលានចាក់សំរាម
- គម្រោងចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធ
- គម្រោងកៀរដីដោយប្រព័ន្ធឡាស៊ែ
- បង្កើតសហគមន៍កសិករ ដើម្បីជំរុញការអនុវត្តន៍ភូមិ១ ផលិតផល១
- ពង្រឹងក្រុមផលិតពូជស្រូវ
- បំផុសការចិញ្ចឹមត្រីតាមលក្ខណៈគ្រួសារ
- ដាក់លូបង្ហូរទឹកតាមមុខផ្ទះនៅជាប់ផ្លូវ
- ដោះស្រាយដីសម្បទានសង្គមកិច្ច
- ជំរុញធ្វើប័ណ្ណក្រីក្រឱ្យដល់ស្ត្រីគ្រប់រូប
- ផ្តល់អាហាររូបត្ថម្ភដល់ស្ត្រី និងកុមារ
- ផ្សព្វផ្សាយពីការចាក់វ៉ាក់សាំងការពារជំងឺដល់ស្ត្រីមានផ្ទៃពោះ និងកុមារ

- ពង្រឹងសេវាថែទាំសុខភាព និងព្យាបាលជំងឺជូនដល់ប្រជាពលរដ្ឋឱ្យបានល្អប្រសើរឡើង
- ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ
- ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់បទដ្ឋានគតិយុត្តនានា ជូនដល់ប្រជាពលរដ្ឋ

## ៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់ ២០៣២)

ផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំទ្រា នៅក្នុងឆ្នាំ ២០១៧ នេះបានឱ្យដឹងថា ឃុំទ្រាជាឃុំមួយក្នុងចំណោមឃុំ ១៣ របស់ស្រុកស្ទោង ខេត្តកំពង់ធំ មានភូមិចំនួន១៦ និងមានផ្ទៃដីសរុបចំនួន ១២ ៣៥៥,៤៣ហិកតា។ ក្នុងឆ្នាំ២០១៧ ឃុំទ្រា មានប្រជាជនចំនួន ២ ៨៧៤គ្រួសារ ប្រជាជនសរុប ១៤ ៨០៦នាក់ ក្នុងនោះស្ត្រី ៧ ១៧២នាក់ ហើយមានដង់ស៊ីតេប្រជាជន មធ្យម១០៤នាក់/គ.ម$^{២}$។ ឃុំទ្រា មានសណ្ឋានភាពដីជាជម្រាលធម្យម ហើយជាប្រភេទកណ្តេងលាយល្បាប់(ពណ៌លឿង) ដីខ្សាច់លាយ និង ល្បាយ (សលាយក្រហម) ត្រូវបានប្រើប្រាស់ជាដី ស្រែវស្សា និងដំណាំចម្ការ ដែលបានផ្តល់នូវមុខរបរសំខាន់ ដល់ប្រជាពលរដ្ឋភាគច្រើនរហូតដល់ប្រមាណ ៧៣,២ភាគរយ សេវាកម្ម ២៥,៨ភាគរយ និងសិប្បកម្មមាន ១ ភាគរយ ។

ទន្ទឹមនេះឃុំទ្រា មានប្រភពទឹកសំខាន់ៗដូចជាៈ ទឹកស្ទឹងស្ទោង អាង៣០កញ្ញា និងមានប្រឡាយសរុប ១៣ខ្សែ ប្រវែង ៣២ ១២២,៣៨ម៉ែត្រ ដែលក្នុងនោះប្រឡាយមេមានចំនួន២ខ្សែ ប្រវែង ១៣ ៣២៩,១០ម៉ែត្រ ប្រឡាយរងមានចំនួន ១ខ្សែ ប្រវែង ៦ ០២០,៤៧ម៉ែត្រ និងប្រឡាយតូច ១០ខ្សែ ប្រវែង ១២ ៧៧២,៨១ម៉ែត្រ។ បន្ថែមពីលើនេះ ឃុំទ្រាស្ថិតនៅជិតទីរួមស្រុកស្ទោងដែលមានផ្លូវជាលេខ៦ ឆ្លងកាត់ភ្ជាប់ពីភ្នំពេញទៅសៀមរាប គឺជាការផ្តល់ឱកាសឱ្យឃុំទ្រា អាចទាញយកប្រយោជន៍ពីការអភិវឌ្ឍន៍តាមផ្លូវនេះបាន ហើយឃុំនៅមានផ្លូវផ្សេង ទៀតគ្រប់គ្រាន់អាចភ្ជាប់ទំនាក់ទនងពីភូមិមួយទៅភូមិមួយក្នុងឃុំ និងអាចភ្ជាប់ទំនាក់ទំនងទៅឃុំ និងស្រុកផ្សេង រួមទាំងទីរួមខេត្តកំពង់ធំបានដោយងាយស្រួល។ ចំពោះកំណើនប្រជាជនវិញបានរកឃើញថា នៅក្នុងរយៈពេល ១៥ឆ្នាំ ទៅមុខរហូតដល់ឆ្នាំ២០៣២ នឹងមានប្រជាជនកើនឡើងរហូតដល់ ២២ ៦៥១នាក់ ដែលនឹងត្រូវយកចិត្ត ទុកដាក់គិតគូររកដំណោះស្រាយអំពីការប្រើប្រាស់ដី ដើម្បីឆ្លើយតបបានទៅនឹងតម្រូវការរបស់ប្រជាជនហើយក៏ បានរកឃើញ អំពីបញ្ហាប្រឈមមួយចំនួនទៅលើសកម្មភាពនៃការអភិវឌ្ឍន៍ឃុំទ្រាបច្ចុប្បន្នផងដែរ ដូចជា ការធ្វើ ស្រែដែលមានសក្តានុពលក្នុងការអភិវឌ្ឍន៍ឃុំ មិនទាន់ទទួលបាននូវផលស្រូវសមស្របអស់លទ្ធភាពនៅឡើយទេ ដោយសារដីស្រែទាំងនេះកាន់តែខ្សត់ជីជាតិ ខ្វះទឹកស្រោចស្រពសម្រាប់ផ្គត់ផ្គង់ទៅដល់ការធ្វើស្រែបង្កើនរដូវ ខ្វះ ចំណេះដឹងពីបច្ចេកទេសនៃការដាំដុះ ខ្វះចំណេះដឹងពីបច្ចេកទេសនៃការប្រើប្រាស់ជីគីមី និងថ្នាំពុលកសិកម្ម ប្រព័ន្ធប្រឡាយដែលមានស្រាប់បានរាក់ ខ្វះកម្លាំងពលកម្មដោយសារចំណាកស្រុកច្រើន គឺបាត់កម្លាំងពលកម្មជិត ពាក់កណ្តាលនៃកម្លាំងពលកម្មដែលមាន និងតម្លៃកសិផលមិនមានស្ថេរភាពដោយឈ្មួញជាអ្នកកំណត់តម្លៃ។ល។ ទន្ទឹមការរកឃើញបញ្ហាមួយចំនួនលើសកម្មភាពអភិវឌ្ឍន៍ឃុំ ក៏បានរកឃើញថា ជាទូទៅការប្រើប្រាស់ដីនៅក្នុងឃុំ បច្ចុប្បន្ននេះបានចំទិសដៅ និងមានភាពសមស្រប ដូចជាការប្រើប្រាស់ដី សម្រាប់លំនៅឋាន កសិកម្ម ប្រព័ន្ធផ្លូវ គមនាគមន៍ ប្រព័ន្ធធារាសាស្ត្រជាដើម ដែលទៅថ្ងៃអនាគត ក៏នៅតែរក្សាមុខងារប្រើប្រាស់ដីទាំងនោះឱ្យនៅដដែល ដោយគ្រាន់តែមានការកែប្រែតិចតួចទៅតាមតម្រូវការដីចាំបាច់ប្រមាណជា ៣,១៣ហិកតា ពីដីស្រែវស្សាទៅជាដី ទីលានចាក់សំរាម ស្របទៅនឹងតម្រូវការ និងភាពរីចម្រើននៅក្នុងឃុំប៉ុណ្ណោះ។ បន្ថែមពីលើនេះ ក៏បានរកឃើញវិធី ដោះស្រាយបញ្ហាផ្សេងៗទៀតផងដែរសម្រាប់អនាគត ដូចជាត្រូវសាងសង់បន្ទប់រៀនបន្ថែម ពង្រឹងការផ្តល់សេវា

សុខាភិបាលឱ្យបានកាន់ប្រសើរឡើង ជំរុញឱ្យប្រជាពលរដ្ឋហូបទឹកស្អាត និងប្រើប្រាស់បង្គន់អនាម័យ ជួសជុលផ្លូវ ស្ពារប្រឡាយទឹក ដាំដើមឈើនៅតាមទីសាធារណៈ ជំរុញការចិញ្ចឹមត្រីតាមស្រែ។ល។ ជាពិសេសការដោះស្រាយដីសម្រាប់លំនៅឋានភូមិ ដែលមានស្រាប់ដែលបច្ចុប្បន្ននៅទូលាយអាចផ្គត់ផ្គង់ការសាងសង់លំនៅឋានបាន។ ដើម្បីដោះស្រាយទៅនឹងកំណើនប្រជាជន ត្រូវពង្រឹងការធ្វើស្រែឱ្យបាន ៣ ដងក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ដើម្បីបង្កើនទិន្នផលស្រូវឱ្យបានខ្ពស់អស់សក្តានុពល សម្រាប់ផ្គត់ផ្គង់ការហូបចុក និងអាចមានលទ្ធភាពនាំស្រូវចេញបានចំនួន**៥៣ ៣៨៩,៦២តោន/ឆ្នាំ** ដើម្បីជួយផ្គត់ផ្គង់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងឃុំឱ្យបានកាន់តែប្រសើរឡើងស្របទៅនឹងកំណើនប្រជាពលរដ្ឋ ព្រមទាំងជួយជំរុញកំណើនសេដ្ឋកិច្ចក្នុងឃុំ។ ការរកឃើញភាពសមស្របនិងជម្រើសនៃការប្រើប្រាស់ដីនៅក្នុងឃុំទ្រានាពេលអនាគតនេះ បានមកពីការវាយតម្លៃដ៏ត្រឹមត្រូវ ដោយផ្អែកលើធនធានដី រយៈកម្ពស់ ទីជម្រាលធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនេះជាដើម ដើម្បីធានាថាការប្រើប្រាស់ដីនៅក្នុងឃុំទ្រា ទៅអនាគតប្រកប ដោយចីរភាព និងសមធម៌ ។

ដូច្នេះដើម្បីសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីនៅក្នុងឃុំទ្រា ស្របតាមស្ថានភាពដីជាក់ស្តែងនិងសក្តានុពលនៃធម្មជាតិ សម្រាប់ការគាំទ្រកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមប្រកបដោយចីរភាព និងសមធម៌ រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនាពេលអនាគតដូចបានរកឃើញមានចែងលម្អិតនៅក្នុងរបាយការណ៍បច្ចេកទេសនេះរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាឃុំដែលជាតំណាងប្រជាពលរដ្ឋនៅក្នុងឃុំទ្រា ហើយមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំត្រូវខិតខំអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំទ្រា ដែលបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួច ដោយបញ្ជ្រាបទៅនឹងផែនការអភិវឌ្ឍន៍ឃុំ ឱ្យបានប្រកបដោយប្រសិទ្ធិភាពខ្ពស់បំផុត ដើម្បីធានាភាពជោគជ័យផែនការនេះ ៕

លេខ៖ 155/២០

បានពិនិត្យ និង សូមគោរពជូន

**លោកអភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធានគណៈកម្មាធិការ**

**រៀបចំដែនដី នគរូបនីយកម្មស្រុកស្អាង មេត្តាពិនិត្យ និង សម្រេច។**

ថ្ងៃ.........ខែ.........ឆ្នាំ.........ព.ស. ២៥៦៤

ទ្រា ថ្ងៃទី.........ឆ្នាំ២០២០

មេឃុំទ្រា

មិន_ជាត

លេខ÷......០៧១/២០......

បានពិនិត្យ និង សូមគោរពជូន

**ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និង ជាប្រធានគណៈកម្មាធិការ**

**រៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ធំ មេត្តាពិនិត្យ និង សម្រេចដ៏ខ្ពង់ខ្ពស់ ។**

ថ្ងៃ....ព្រហ ១១ រោច.......ខែ មិគសិរ ឆ្នាំ....ជូត ទោស័ក ព.ស. ២៥៦៤

ស្ទោង ថ្ងៃទី......១០.........ខែ..ធ្នូ.....ឆ្នាំ ២០២០

**អភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធាន**

**គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកស្ទោង**

**ណែត សារី**

លេខ៖...៥៤៧/[illegible]........

**បានឃើញ និងឯកភាពសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ**

ថ្ងៃ..ព្រហស្បតិ៍ ៣ កើត....ខែ..ភទ្របទ.. ឆ្នាំ..ឆ្លូវ ត្រីស័ក.....ព.ស. ២៥៦៥

កំពង់ធំ ថ្ងៃទី......០៩..........ខែ....កញ្ញា......ឆ្នាំ ២០២១

**អភិបាលនៃគណៈអភិបាលខេត្ត និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ**

សុខ លុយ

# ឯកសារឧបសម្ព័ន្ធ

# ផែនទីហេដ្ឋារចនាសម្ព័ន្ធ ឃុំទ្រា




ផែនទីប្រព័ន្ធធារាសាស្ត្រ ឃុំទ្រា
ជ
ល
ក
ត
ឃុំពពក
ឃុំប្រឡាយ
ឃុំសាមគ្គី
ឃុំដូង
ផ្លោះទៅខេត្តសៀមរាប
ផ្លូវជាតិលេខ ៦
ឃុំកំពង់ចិនជើង
ឃុំបន្ទាយស្ទោង
ឃុំកំពង់ចិនត្បូង
ឃុំសំព្រោជ
មាត្រដ្ឋាន ១:៨៥ ០០០
0
២
៤
គីឡូម៉ែត្រ
សញ្ញាសម្គាល់
ព្រំប្រទល់ និងទីតាំងរដ្ឋបាល
សាលាឃុំ
ភូមិ
ព្រំប្រទល់រដ្ឋបាលឃុំ
ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន
មន្ទីរពេទ្យ មណ្ឌលសុខភាព
វត្ត
សាលារៀន
ស្ពាន
ទ្វារទឹក
ផ្លូវជាតិលេខ ៦
ផ្លូវចាក់កៅស៊ូ
ផ្លូវចាក់បេតុង
ផ្លូវគ្រួសក្រហម ឬក្រាលថ្ម
ផ្លូវដីស ឬផ្លូវរទេះ
ប្រឡាយមេ
ប្រឡាយរង
ប្រឡាយតូច
ស្ទឹងមានទឹកតាមរដូវ
ស្រះ

# ផែនទីប្រើប្រាស់ដីសាមញ្ញ ឃុំទ្រា



# ផែនទីគម្រោងវិនិយោគ ឃុំទ្រា




**សញ្ញាសម្គាល់**

**ព្រំប្រទល់ និងទីតាំងរដ្ឋបាល**

- សាលាឃុំ
- ភូមិ
- ព្រំប្រទល់រដ្ឋបាលឃុំ

**ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន**

- មន្ទីរពេទ្យ មណ្ឌលសុខភាព
- វត្ត
- សាលារៀន
- ស្ពាន
- ទ្វារទឹក
- ផ្លូវជាតិលេខ ៦
- ផ្លូវចាក់កៅស៊ូ
- ផ្លូវចាក់បេតុង
- ផ្លូវគ្រួសក្រហម ឬក្រាលថ្ម
- ផ្លូវដីស ឬផ្លូវរទេះ
- ប្រឡាយមេ
- ប្រឡាយរង
- ប្រឡាយតូច

**ប្រភេទប្រើប្រាស់ដីបច្ចុប្បន្ន**

- ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ
- ដីកសិកម្ម
- ដីព្រៃ/គម្របព្រៃ
- ផ្ទៃទឹក និងខ្សែទឹក

**គម្រោងវិនិយោគ**

- សាងសង់លូអមផ្លូវ
- សាងសង់ទ្វារទឹក
- កសាងផ្លូវចាក់កៅស៊ូ
- ជួសជុលផ្លូវលំដីស
- ជួសជុលផ្លូវគ្រួសក្រហម
- ជីកប្រឡាយតូច
- កសាងផ្លូវចាក់បេតុង
- ស្តារប្រឡាយតូច

**ប្រព័ន្ធកូអរដោនេ**

| | | |
|---|---|---|
| ចំណោលផែនទី | : | UTM |
| តំបន់ទី | : | 48N |
| ទិន្នន័យយោង | : | WGS 1984 |
| អេលីបសូអីត | : | WGS 1984 |

**ប្រភពទិន្នន័យ**

-ទីតាំងវិនិយោគ ប្រភពពីផែនការអភិវឌ្ឍឃុំរយៈពេល៥ឆ្នាំនិងអាជ្ញាធរមូលដ្ឋាន
-ទិន្នន័យទីតាំង និងព្រំប្រទល់រដ្ឋបាលប្រភពពីនាយកដ្ឋានភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគូរូបនីយកម្ម និងសំណង់ (២០១៩)
-ទិន្នន័យសំខាន់ៗផ្សេងទៀត ប្រភពពីមន្ទីរ/ស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត

**បញ្ជាក់**

-ព័ត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើងដោយថ្នាក់ជាតិនិងត្រូវបានកែសម្រួលដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន
-ព្រំប្រទល់រដ្ឋបាលទាំងនោះ មិនអាចចាត់ទុកជាផ្លូវការ និងខ្សែបន្ទាត់ព្រំដែននៃផែនទីនេះ ពុំមានតម្លៃជាផ្លូវការអន្តរជាតិឡើយ
-ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ................................. ឆ្នាំ២០.......

# ឯកសារឧបសម្ព័ន្ធ




សកម្មភាពក្រុមការងារចូលរួមប្រជុំទទួលការណែនាំពីនីតិវិធីរៀបចំផែនការប្រើប្រាស់ដីថ្នាក់ឃុំ ពីប្រធានគ្រប់គ្រងគម្រោងរបស់ក្រុមហ៊ុន




សកម្មភាពប្រមូលទិន្នន័យនៅតាមមន្ទីរជុំវិញខេត្តរបស់ក្រុមការងារក្រុមហ៊ុន SBK




កិច្ចប្រជុំពិភាក្សាអំពីផែនទីប្រើប្រាស់ដីបច្ចុប្បន្នឃុំទ្រា





សកម្មភាពក្រុមការងារចុះទីវាលស្រង់ទិន្នន័យបំពេញបន្ថែមលើ
ផែនទីប្រើប្រាស់ដីបច្ចុប្បន្នដែលមានស្រាប់ឃុំទ្រា





សកម្មភាពចូលរួមត្រួតពិនិត្យ ណែនាំ
ការអនុវត្តគម្រោងរបស់អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIO)





កិច្ចប្រជុំក្រុមប្រឹក្សាឃុំទ្រា ដើម្បីពិនិត្យ និងឯកភាពទៅលើសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំទ្រា




កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកស្ទោង ដើម្បីពិនិត្យ និងឯកភាពទៅលើសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំទ្រា




កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ
ដើម្បីពិនិត្យ និងឯកភាពទៅលើសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំទ្រា



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលស្រុកស្ទោង
ក្រុមប្រឹក្សាឃុំទ្រា

ថ្ងៃ............ខែ............ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
..............ថ្ងៃទី.......ខែ.......ឆ្នាំ២០......

សេចក្តីជូនដំណឹង
ស្តីពីការបិទផ្សាយជាសាធារណៈផែនការប្រើប្រាស់ដីអនាគតឃុំទ្រា

យោង: - កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB )។
- កិច្ចសន្យាលេខ CON-LUP/RICE-SDP/CLUP/MUMUPC/CS/ 09 ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៧ រវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន SBK Research & Development Co.,Ltd ។
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។
- តម្រូវការចាំបាច់នៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។

ខ្ញុំសូមបានជម្រាបជូនក្នុងសេចក្តីយោងខាងលើ និងស្របតាមការរៀបចំផែនការប្រើប្រាស់ដី និងលទ្ធផលការងារ ដែលសម្រេចបានទៅតាមនីតិវិធីនាពេលកន្លងមកក្រុមប្រឹក្សាឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ សូមគោរពជម្រាបជូនដល់គ្រប់ស្ថាប័ន អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់មេត្តាជ្រាបថា៖ នៅថ្ងៃទី.......ខែ.......ឆ្នាំ២០...... ដល់ថ្ងៃទី......ខែ.......ឆ្នាំ២០......ឃុំទ្រា ធ្វើការរៀបចំបិទផ្សាយជាសាធារណៈនូវឯកសារ និងផែនការប្រើប្រាស់ដីអនាគត ដែលសម្រេចបាន នៅទីតាំងសាលាឃុំខាងលើ ដើម្បីធ្វើការពិនិត្យ កែសម្រួល និងផ្តល់យោបល់។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ មេត្តាជួយផ្សព្វផ្សាយ និងចូលរួមពិនិត្យផ្តល់យោបល់អោយបានកុះករ កុំបីអាក់ខានឡើយ ។

សូមបងប្អូនជនរួមជាតិ មេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

ប្រធានក្រុមប្រឹក្សាឃុំ និងជា
មេឃុំទ្រា

មិន_ជាត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលស្រុកស្ទោង
ក្រុមប្រឹក្សាឃុំ ទ្រា

របាយការណ៍ការបូកសរុប
លទ្ធផល នៃការបិទផ្សាយជាសាធារណៈ នូវឯកសារផែនទី និង
សៀវភៅផែនការប្រើប្រាស់ដីនៅក្នុងឃុំ ទ្រា

យោង: - កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៣ រវាង រាជរដ្ឋាភិបាលកម្ពុជានិងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។
- កិច្ចសន្យាលេខ CON-LUP/RICE-SDP/CLUP/MUMUPC/CS/ ០១ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១៧ រវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន SBK Research & Development Co.,Ltd។
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។
- ក្រុមប្រឹក្សាឃុំទ្រា បានបិទផ្សាយជាសាធារណៈនៅទីតាំង សាលាឃុំទ្រា នូវឯកសារផែនទី និងសៀវភៅពង្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំទ្រា (បានប្រជុំអនុម័តថ្នាក់ស្រុកស្ទោង រួចរាល់ជាស្ថាពរ) ចាប់ពីថ្ងៃទី.......ខែ.......ឆ្នាំ ២០២០ ដល់ថ្ងៃទី.......ខែ.......ឆ្នាំ ២០២០ មានរយៈពេល ៤៥ ថ្ងៃ ជាលទ្ធផលមានដូចខាងក្រោម៖

១. ផែនទីប្រើប្រាស់ដីនៅក្នុងឃុំ ទ្រា
- បានធ្វើការបិទផ្សាយផែនទីប្រើប្រាស់ដីលម្អិតបច្ចុប្បន្ន មានទំហំជាខ្នាត A0
- បានធ្វើការបិទផ្សាយផែនទីប្រើប្រាស់ដីអនាគតសម្រាប់រយៈពេល ១៥ឆ្នាំ ២០១៧ ដល់ ២០៣២ មានទំហំជាខ្នាត A0
- ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន

២. សៀវភៅផែនការប្រើប្រាស់ដីនៅក្នុងឃុំ ទ្រា
- ជំពូក ១ ៖ ព័ត៌មានស្តីពី ស្ថានភាពឃុំទ្រា
  - ចាប់ពី ១.១. ស្ថានភាពទូទៅនៃឃុំ ១.១.១. ទីតាំងរដ្ឋបាលឃុំ រហូតដល់ ១.៤. ទីផ្សារ និង ខ្សែសង្វាក់ផលិតផល ១.៤.៣. ឧបសគ្គ និង ឱកាស។
  - ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន
- ជំពូក ២ ៖ ការវិភាគតម្រូវការ សក្តានុពល និង ឧបសគ្គសម្រាប់អនាគត
  - ចាប់ពី ២.១. តម្រូវការសម្រាប់អនាគត់ ២.១.១. ផែនការអភិវឌ្ឍន៍ឃុំ រហូតដល់ ២.៥. បញ្ហា មូលហេតុ និង ដំណោះស្រាយ។
  - ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន
- ជំពូក ៣ ៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគត ឆ្នាំ២០១៧ ដល់ ២០៣២
  - ចាប់ពី ៣.១. តម្រូវការ ស្ថានភាព និង សក្តានុពលជាក់ស្តែង ៣.១.១. តម្រូវការដីទៅតាមប្រភេទ រហូតដល់ ៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់ ២០៣២)
  - ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន

- **ការវាយតម្លៃ** : ផ្អែកតាមឯកសារភស្តុតាង និងទិន្នន័យជាក់ស្តែង ដែលប្រមូលបាន លទ្ធផលនៃការបិទផ្សាយសាធារណៈនូវឯកសារ ផែនទី និង សៀវភៅពង្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ ទ្រា សម្រាប់ឆ្នាំ ២០១៧ ដល់ ២០៣២ ជាយោបល់គួរដាក់ជូនគណៈកម្មាធិការរៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ធំ ដើម្បីពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

ថ្ងៃ.............ខែ.........ឆ្នាំ.........សក ព.ស. ២៥៦...
ទ្រា ថ្ងៃទី.......ខែ.......ឆ្នាំ ២០២...
ប្រធានក្រុមប្រឹក្សាឃុំ និងជា
មេឃុំទ្រា

មិន_ជាត

សកម្មភាពផ្សព្វផ្សាយជាសាធារណៈសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំទ្រា

# ឯកសារយោង

# ឯកសារយោង

១. ឯកសារព័ត៌មានស្ថានភាពឃុំទ្រាស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៣ របស់មន្ទីរផែនការខេត្ត
២. ឯកសារព័ត៌មានស្ថានភាពឃុំទ្រាស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៤ របស់មន្ទីរផែនការខេត្ត
៣. ឯកសារព័ត៌មានស្ថានភាពឃុំទ្រាស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៥ របស់មន្ទីរផែនការខេត្ត
៤. ឯកសារព័ត៌មានស្ថានភាពឃុំទ្រាស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦របស់មន្ទីរផែនការខេត្ត
៥. ឯកសារព័ត៌មានស្ថានភាពឃុំទ្រាស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៧ របស់មន្ទីរផែនការខេត្ត
៦. ផែនការអភិវឌ្ឍន៍ឃុំរយៈពេលប្រាំឆ្នាំ(២០១៨-២០២២)របស់ឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ
៧. កម្មវិធីវិនិយោគឃុំទ្រា ឆ្នាំ២០១៧ របស់ឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ
៨.របាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ_បរិស្ថាន ឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ ឆ្នាំ២០១៧
៩.ផែនការអភិវឌ្ឍន៍ស្រុករយៈពេលប្រាំឆ្នាំ(២០១៨-២០២២)របស់ស្រុកស្ទោង ខេត្តកំពង់ធំ
១០. អនុក្រឹត្យស្តីពីការកំណត់ដែនព្រៃលិចទឹក ៦៤៧,៤០៦ហិកតា ស្ថិតនៅក្នុងខេត្តទាំង៦ជុំវិញបឹងទន្លេសាប (កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប)
១១. អនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ៨៨.អនក្រ.បក ស្តីពីការបង្កើតតំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប ។